ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# របាយការណ៍បូកសរុបលទ្ធផល
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៥
# និងទិសដៅអនុវត្ត ឆ្នាំ ២០២៦

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

# សារលិខិត ថ្វាយព្រះពរ និងជូនពរ

ក្នុងឱកាសដ៏វិសេសវិសាល អបអរឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ដែលនឹងមកដល់ក្នុងពេលខាងមុខនេះ នាងខ្ញុំ សូមលំឱនកាយ ថ្វាយបង្គំ លើកហត្ថប្រណម្យ បួងសួង ដល់គុណព្រះរតនត្រ័យ ព្រមទាំងបារមីនៃទេវៈដ៏មានឫទ្ធិ និងវត្ថុសក្តិសិទ្ធក្នុងលោក សូមប្រោសប្រទានពរជ័យ សិរីមង្គលវិបុលសុខគ្រប់ប្រការ ថ្វាយចំពោះ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ថ្វាយ និងប្រគេន សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រះរាជាគណៈ ព្រះមន្ត្រីសង្ឃ និងព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ សូមទ្រង់មានព្រះជន្មាយុ យឺនយូរ ព្រះបញ្ញាឈ្លាសវៃ ព្រះកាយពលមាំមួន ដើម្បីគង់ជាម្លប់ នៃប្រជានុរាស្ត្រ និងពុទ្ធសាសនិកទាំងឡាយ ឲ្យស្ថិតក្នុងភាពសុខុដុមរមនា និងសម្បូររុងរឿង!



សូមប្រសិទ្ធពរជ័យ សិរី បវរមហាប្រសើរ គោរពជូនសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន ប្រធាន ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត សម្តេចអគ្គមហាពញា ចក្រី ហេង សំរិន និងលោកជំទាវ សម្តេច មហារដ្ឋសភាធិការ ឃួន សុដារី ប្រធានរដ្ឋសភា សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងលោកជំទាវបណ្ឌិត សម្តេចក្រឡាហោម ស ខេង និងលោកជំទាវ សម្តេចវិបុលសេនា ទៀ បាញ់ និងលោកជំទាវ សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា និងលោកជំទាវ ព្រមទាំងសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ក្នុងស្ថាប័នកំពូលទាំងបី ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល គ្រប់ឋានានុក្រម ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វីរៈយុទ្ធជន យុទ្ធនារី វីរៈនគរបាល កងរាជអាវុធហត្ថ និងកងកម្លាំងការពារជាតិគ្រប់ប្រភេទ សូមទទួលបាននូវ តេជះ បញ្ញាញាណ កម្លាំងពលំ និងវ័យវឌ្ឍនាការយូរអង្វែង ដើម្បីរួមគ្នាជាកម្លាំងជាតិដ៏រឹងមាំ ថែទាំរក្សា ទឹកដី វប្បធម៌ សាសនា មរតកជាកេរ្តិ៍ដំណែលដូនតា ឲ្យបានគង់វង់ និងប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស បានសេចក្តីសុខ អស់កាលជាអង្វែងតរៀងទៅ!

សូមគោរពជូនពរ ចំពោះ **វីរៈយុទ្ធជន យុទ្ធនារី វីរៈនគរបាល កងរាជអាវុធហត្ថ និងកងកម្លាំងការពារជាតិគ្រប់ប្រភេទ** ដែលបាន និងកំពុងឈរជើងការពារបូរណភាពដែនដីពីខ្មាំងឈ្លានពាន ចំពោះ**គ្រប់កម្លាំងមហាសាមគ្គីជាតិខ្មែរ** ពីគ្រប់**ទិសទី ដៃគូជាតិ និងអន្តរជាតិ** ដែលមានឆន្ទៈ និងគោលដៅដូចគ្នា និងដែលបានរួមសហការគ្នា ឧបត្ថម្ភគាំទ្រដោយឥតសំចៃ ដោយស្មារតីស្នេហាជាតិ មាតុភូមិ លះបង់កម្លាំងកាយចិត្ត អាយុជីវិត មិនខ្លាចនឿយហត់ សូមមានសេចក្តីសុខ និងជោគជ័យគ្រប់ភារកិច្ច សូមស្មារតីជាតិដ៏រឹងមាំនេះ ស្ថិតនៅក្នុងក្រអៅបេះដូងខ្មែរគ្រប់ជំនាន់ជានិច្ចនិរន្តរ៍!

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ឋានានុក្រម នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមប្តេជ្ញាចិត្ត រក្សានូវស្មារតីសាមគ្គី ឯកភាព សហការ ប្រកបដោយឆន្ទៈ និងការទទួលខុសត្រូវ ដើម្បីព្រះរាជាណាចក្រកម្ពុជាបន្តមានសន្តិភាពពេញបរិបូណ៌ កម្ចាត់អស់នូវបទល្មើស និងឧបាយកលខ្មៅងងឹត ដែលបង្ករគ្រោះមហន្តរាយដល់ប្រជាជន និងមាតុភូមិកម្ពុជា ដើម្បីជាឱកាសក្នុងការអភិវឌ្ឍន៍ជាតិឲ្យរីកចម្រើនជាយូរអង្វែង តរៀងទៅ!

*ថ្ងៃ អង្គារ ១កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦*

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា




“រាជរដ្ឋាភិបាលនីតិកាលទី៧មានជំហរមោះមុតបន្តការប្តេជ្ញាចិត្តប្រឆាំងដាច់ខាតអំពើជួញដូរមនុស្សគ្រប់ទម្រង់។ ខ្ញុំសូមអំពាវនាវ ដល់គ្រប់ភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ចាំបាច់ត្រូវសហការគ្នាកាន់តែខ្លាំងដើម្បីរួមគ្នាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន តាមដានស៊ើបអង្កេត បង្ក្រាប និងផ្តន្ទាទោសជនល្មើសតាមច្បាប់។ ជនរងគ្រោះទាំងឡាយត្រូវទទួលបាននូវយុត្តិធម៌និងការគាំពារឲ្យបានត្រឹមត្រូវ។ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច មន្ត្រីឈរជើងតាមព្រំដែន ត្រូវរួមកម្លាំងគ្នាគ្រប់គ្រង ត្រួតពិនិត្យលំហូរទេសន្តរប្រវេសន៍ឲ្យបានជាក់លាក់ ដើម្បីការពារសុវត្ថិភាពសិទ្ធិ និងផលប្រយោជន៍ជូនប្រជាពលរដ្ឋយើង។”

## ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ



“គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងរាជរដ្ឋាភិបាល នីតិកាលទី៧នេះ បាននិងកំពុងបង្កើនការយកចិត្តទុកដាក់ ក្នុងការពង្រឹងសន្តិសុខ សុវត្ថិភាពសង្គម លើកកម្ពស់សិទ្ធិ និងផលប្រយោជន៍ជូនប្រជាពលរដ្ឋគ្រប់ស្រទាប់ គ្រប់មជ្ឈដ្ឋាន ដោយបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជំនាញជួរមុខគ្រប់វិស័យ ដើម្បីបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងរាល់បទល្មើសក្នុងសង្គម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព ជាពិសេស អំពើជួញដូរមនុស្សគ្រប់ទំរង់ រួមទាំងការឆបោកតាមប្រព័ន្ធអនឡាញ ដើម្បីកាត់បន្ថយឈាន
ទៅលុបបំបាត់ភាពរងគ្រោះរបស់ ប្រជាពលរដ្ឋ។”

# អារម្ភកថា



សម្តេច ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ស្ថាប័នកំពូលរបស់ជាតិ ថ្នាក់ដឹកនាំគ្រប់ឋានានុក្រម និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កងកម្លាំងគ្រប់ប្រភេទ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងបងប្អូនជនរួមជាតិជាទីគោរពរាប់អាន!

ឆ្នាំ២០២៥ កន្លងទៅនេះ គឺជាមេរៀនប្រវត្តិសាស្ត្រដ៏មានតម្លៃមហាសាលដែលដាស់ស្មារតីកូនខ្មែរគ្រប់រូបទាំងក្នុង និងក្រៅប្រទេសឱ្យចងចាំជានិច្ច តកូនចៅ ដោយប្រុងស្មារតីឱ្យរឹងមាំ ត្រៀមគ្រប់លក្ខណៈដើម្បីទប់ទល់នឹងមហន្តរាយទាំងឡាយ ដែលកើតឡើងដោយផ្ទាល់ ពីប្រទេសដែលមានមហិច្ឆិតាឈ្លានពាន និងពីផលប៉ះពាល់ដោយប្រយោលនៃវិបត្តិនយោបាយ និងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ យើងទាំងអស់គ្នា ត្រូវអត់ធ្មត់រួមសាមគ្គីឯកភាពគ្នាជាធ្លុងមួយក្រោមការដឹកនាំដ៏ឈ្លាសវៃ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលព្យាយាមដោះស្រាយបញ្ហាដោយប្រុងប្រយ័ត្ន បត់បែន ទន់ភ្លន់ ដើម្បីរក្សាឱ្យបានដាច់ខាតនូវស្ថេរភាពនយោបាយ កំណើនសេដ្ឋកិច្ច និងអធិបតេយ្យភាពបូរណភាពទឹកដីឱ្យស្ថិតស្ថេរគង់វង្សជានិច្ចនិរន្តរ៍សម្រាប់កូនចៅជំនាន់ក្រោយ។

ក្នុងស្ថានភាពដ៏ប្រឈមនេះអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើពាក់ព័ន្ធទាំងឡាយនៅគ្រប់តំបន់បានកើនឡើងគួរឱ្យកត់សម្គាល់ ហើយទម្រង់នៃបទល្មើសក៏កាន់តែស្មុគស្មាញ ប្របូកប្រឋល់ ពិបាកកំណត់ថាអ្នកណាជាជនល្មើសពិត និងជាជនរងគ្រោះពិត។ អំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបានក្លាយទៅជាបញ្ហាក្តៅគគុកដែលប្រទេសទាំងឡាយក្នុងតំបន់និងក្នុងពិភពលោកបាននិងកំពុងតែចូលក្នុងអន្ទាក់នៃបទល្មើសបង្កឡើងដោយឧក្រិដ្ឋជន។ដើម្បីដោះស្រាយបញ្ហានេះប្រទេសទាំងឡាយចាំបាច់ត្រូវសហការគ្នាដោះស្រាយបញ្ហារួមជាជាងការចង្អុលដាក់គ្នា។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរដោយស្មោះនូវស្មារតីលះបង់របស់គ្រប់វិស័យពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងបងប្អូនជនរួមជាតិដែលមានការយោគយល់ និងស្មារតីស្នេហាជាតិដ៏ជ្រាលជ្រៅ តស៊ូ អត់ធ្មត់ រួមគ្នាប្រឆាំង និងបោសសម្អាតបទល្មើស ដែលកើតមានក្នុងព្រះរាជាណាចក្រកម្ពុជា និងលើប្រជាជនកម្ពុជានៅក្រៅប្រទេសបានយ៉ាងល្អប្រសើរ។ ជាការពិតណាស់ដែលថាបទល្មើសទាំងអស់នេះមិនអាចផុតរលត់អស់ភ្លាមតាមការចង់បានឡើយប៉ុន្តែការព្យាយាមរបស់យើងនឹងធ្វើឱ្យបទល្មើសទាំងអស់នេះថមថយមិនមានឥទ្ធិពល និងមិនបង្កហានិភ័យខ្ពស់ដល់ប្រជាពលរដ្ឋ និងសង្គមជាតិ ប្រជាពលរដ្ឋនឹងកាន់តែបានយល់បានចូលរួមនិងពង្រឹងភាពខ្លាំងរបស់យើងដើម្បីប្រយុទ្ធប្រឆាំងបទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ឱ្យទទួលបានជោគជ័យជាស្ថាពរ។

ខ្ញុំសូមអំពាវនាវ បងប្អូនជនរួមជាតិ ជាពិសេស យុវជន យុវនារី នាំគ្នាប្រើបច្ចេកវិទ្យាវៃឆ្លាត ដើម្បីបម្រើឱ្យភាពខ្លាំងនៃការអភិវឌ្ឍន៍សមត្ថភាពនៃមូលធនមនុស្សដែលជាសេចក្តីត្រូវការចាំបាច់របស់ប្រទេសជាតិយើងនិងកែប្រែស្ថានភាពដែលប្រកបដោយហានិភ័យឱ្យក្លាយជាសក្តានុពលក្នុងសន្តិសុខសុវត្ថិភាពនិងមិនចូលរួមដាច់ខាតរាល់សកម្មភាពដែលបង្កើតជាឱកាសងាយស្រួលឱ្យជនល្មើសបំផ្លាញយើងបានឡើយ។

*សូមចងចាំ! សត្រូវរួមរបស់យើង គឺរាល់សកម្មភាព ដែលបំផ្លាញសន្តិភាព និងគោលដៅអភិវឌ្ឍន៍ជាតិរបស់យើង!*

ថ្ងៃ អង្គារ ១កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**អភិសន្តិបណ្ឌិត ស សុខា**

# មាតិកា


I. សេចក្តីផ្តើម ........ ១

II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ........ ៣

ក. ការបង្ការ ទប់ស្កាត់ ........ ៣

ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់ ........ ៣

ក.២.ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់ ........ ៩

ក.៣.ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ ........ ១៦

ក.៣.១.ការធ្វើអធិការកិច្ចការងារ ........ ១៦

ក.៣.២.ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់ ........ ១៦

ក.៣.៣.ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ........ ១៦

ក.៣.៤.ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស ........ ១៧

ក.៤. ការបញ្ជូន និងទទួលពលករទេសន្តរប្រវេសន៍ដោយស្របច្បាប់ ........ ២០

ក.៥. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ........ ២០

ក.៦. ការលើកកម្ពស់ជីវភាព ........ ២២

ក.៧. ការសិក្សាស្រាវជ្រាវ ........ ២៤

ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ........ ២៥

ខ.១. ការងារអនុវត្តច្បាប់ ........ ២៥

ខ.២.កិច្ចការយុត្តិធម៌ ........ ២៦

គ. កិច្ចការពារជនរងគ្រោះ ........ ២៧

គ.១.ការទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ ក្នុងប្រទេស និងពីក្រៅប្រទេស ... ២៧

គ.២.ការផ្តល់សេវាគាំទ្រនិងស្តារនីតិសម្បទា ........ ២៨

គ.៣.ការធ្វើសមាហរណកម្មជនរងគ្រោះ ........ ២៨

គ.៤.ការធ្វើមាតុភូមិនិវត្តន៍ ........ ២៩

គ.៥.ការតាមដានជនរងគ្រោះ ........ ២៩

គ.៦.ការបិទករណីជនរងគ្រោះ ........ ២៩

ឃ. ការងារច្បាប់ គោលនយោបាយ សន្ធិសញ្ញា កិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ........ ២៩

ឃ.១. លិខិតបទដ្ឋានគតិយុត្ត ........ ២៩

ឃ.២. កិច្ចសហប្រតិបត្តិការ ........ ២៩

III.ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល ....................................................................៣២
ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា ....................................................................................៣២
ក.១. ការបណ្តុះបណ្តាល ....................................................................................................៣២
ក.២.សិក្ខាសាលា ..........................................................................................................៣៤
ខ. សន្និសីទ កិច្ចប្រជុំ ជំនួបពិភាក្សា និងទស្សនកិច្ច ....................................................................៣៥
ខ.១. កិច្ចប្រជុំ ...............................................................................................................៣៥
ខ.២.ទស្សនកិច្ច ..........................................................................................................៣៧
ខ.៣. ជំនួបពិភាក្សា ........................................................................................................៣៨
គ. ការងារសម្របសម្រួល ............................................................................................................៤០

IV. ការសន្និដ្ឋានវាយតម្លៃ ..............................................................................................................៤២
ក.ចំណុចខ្លាំង .........................................................................................................................៤២
ខ. ចំណុចខ្វះខាត ឬភាពប្រឈម .............................................................................................៤២
គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ ............................................................................................៤៣

V. ទិសដៅអនុវត្តបន្ត .....................................................................................................................៤៤

- ឧបសម្ព័ន្ធ
- សម្រង់រូបភាព

# របាយការណ៍
# ស្ដីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២៦

## I. ស្ថានភាពទូទៅ

វិបត្តិសេដ្ឋកិច្ចជាសកល បម្រែបម្រួលអាកាសធាតុ រួមទាំងផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងជាបន្តបន្ទាប់ជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ សង្គ្រាមបង្ហូរឈាមរវាងប្រទេស និងប្រទេស ក៏ដូចជាវិបត្តិនយោបាយ បន្តពីឆ្នាំមុន នៅតែក្លាយជាបញ្ហាចោទចំពោះប្រជាពលរដ្ឋ និងមិនអាចឆ្លើយតបបាន ថាតើពេលណាទើបបញ្ចប់?។ មនុស្សរាប់លាននាក់ ត្រូវបង្ខំចិត្តចាកចេញពីកន្លែងធ្លាប់រស់នៅ ទាំងមិនដឹងថា ត្រូវទៅទីណាដែលមានសុវត្ថិភាព។ ការធ្វើចំណាកស្រុកក្នុងស្ថានភាពបែបនេះ ប្រឈមនឹងកង្វះឯកសារគតិយុត្ត ខ្វះការគ្រប់គ្រង និងការធានាសុវត្ថិភាពពីការរំលោភបំពាន អំពើហិង្សា ការកេងប្រវ័ញ្ច ការលួចធក់ប្លន់ និងអំពើជួញដូរមនុស្ស ដែលបង្កឡើងដោយឧក្រិដ្ឋជន និងជនឆ្លៀតឱកាស ពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ ។

ប្រព័ន្ធផ្សព្វផ្សាយកាន់តែសម្បូរបែប កាន់តែទំនើប គួបផ្សំនឹងសេរីភាពនៃព័ត៌មានកាន់តែទូលំទូលាយ តែពិបាកនឹងជឿទុកចិត្ត ព្រោះសម្បូរតែព័ត៌មានមិនពិត បំផ្លើស និងការបោកបញ្ឆោត។ ទន្ទឹមនេះ វេទិកា(platform) ទម្រង់នានា ដែលប្រើបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត AI បាននឹងកំពុងទាញយករូបភាព និងឯកសារផ្សេងៗ ទៅសិក្សាកាន់តែស៊ីជម្រៅ ដែលធ្វើជនល្មើសមានឱកាសប្រើប្រាស់ប្រព័ន្ធនេះ ក្នុងគោលបំណងកេងប្រវ័ញ្ចគ្រប់រូបភាពកាន់តែងាយស្រួល ។ ការប្រកួតប្រជែងខាងសេដ្ឋកិច្ច នយោបាយ និងការដណ្តើមភូមិសាស្ត្រនយោបាយ ដើម្បីមហិច្ឆតាជាបងធំក្នុងតំបន់ ឬក្នុងពិភពលោក ធ្វើឱ្យពិភពលោកច្របូកច្របល់ ពុលនឹងសកម្មភាព ឬព័ត៌មានដែលជាការប្រទាញប្រទង់ដណ្តើមយកការគាំទ្រ ទាំងពិត និងមិនពិត។ ប្រទេសកម្ពុជា នៅតែប្រកាន់ជំហរ ឈរលើភាពត្រឹមត្រូវ និងសច្ចធម៌ បើទោះបីជាមានការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលចង់បង្វែរការពិត ទៅជាការបោកបន្លំយ៉ាងណាក៏ដោយ ព្រោះការពិត នៅតែជាការពិត។ កម្ពុជា ជាប្រទេសដែលរងគ្រោះ ដោយសារតែការប៉ុនប៉ងបំផ្លាញសន្តិសុខ កេរ្តិ៍ឈ្មោះ និងសេដ្ឋកិច្ច ព្រោះកម្ពុជាបាននិងកំពុងតែបោះជំហានទៅមុខឥតឈប់ឈរ។ ក្រុមឧក្រិដ្ឋជនប្រទេសអមិត្តមួយចំនួន បានរៀបចំកលល្បិចបំផ្លាញសន្តិសុខប្រទេសកម្ពុជា ដោយបានមកលបលួចឃុបឃិត បោះទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរូបភាពស្កេមអនឡាញ (Scame Online) និងប្រើកលល្បិចបោកបញ្ឆោតគ្រប់រូបភាព ទាក់ទាញពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋពីបណ្តាប្រទេសមួយចំនួន ឱ្យចូលមកប្រព្រឹត្តបទល្មើសនៅ កម្ពុជា ហើយធ្លាក់ចូលក្នុងភាពរងគ្រោះដោយការប្រើហិង្សា ធ្វើការងារដោយបង្ខំ ទទួលការកេងប្រវ័ញ្ច ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដោយពួកឧក្រិដ្ឋជនទាញយកផលប្រយោជន៍យ៉ាងមហាសាល ពីការបោកប្រាស់មនុស្សទាំងឡាយនៅក្រៅប្រទេស។ សកម្មភាពទាំងនេះ បានជះឥទ្ធិពលជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះ ព្រះរាជាណាចក្រកម្ពុជា យ៉ាងធ្ងន់ធ្ងរថា ជាប្រទេសដែលមានឧក្រិដ្ឋកម្ម ស្កេមអនឡាញ (Scame Online) និងគ្មានសុវត្ថិភាព ។

ចាប់ពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ទំនាស់ព្រំដែនដែលបង្កឡើងដោយរដ្ឋាភិបាល និងយោធាសៀមឈ្លានពាន បានក្លាយជាសង្គ្រាមបង្ហូរឈាម សង្គ្រាមសេដ្ឋកិច្ច និងសង្គ្រាមនយោបាយការទូត យ៉ាងស្វិតស្វាញ គួបផ្សំនឹងក្រុមជាតិនិយមជ្រុល ដែលយាយីរំខានពលករកម្ពុជា ដោយការរើសអើងពូជសាសន៍ ការប្រើហិង្សាលើរូបរាងកាយ ការជេរប្រមាថ បណ្តេញ កេងប្រវ័ញ្ចមិនបើកប្រាក់ឈ្នួល គួបផ្សំនឹងការគំរាមបិទព្រំដែនជាប្រេកសេដ្ឋកិច្ចជាដើម បានជំរុញឱ្យពលករកម្ពុជា មិនអាចទ្រាំទ្រឬរស់នៅ និងធ្វើការក្នុងប្រទេសថៃ

បាន ហើយត្រូវបង្ខំចិត្តរត់គេចចេញពីប្រទេសថៃ ដោយបានយកតាមខ្លួនត្រឹមតែសម្ភារៈតិចតួចជាប់ខ្លួន រហូតដល់ទៅ ជាងប៉ែតសិបម៉ឺននាក់ ក្នុងចំណោមពលរដ្ឋខ្មែរវិលត្រឡប់ប្រមាណ មួយលាននាក់ ក្នុងរយៈពេលតែប្រមាណជិតបួនខែប៉ុណ្ណោះ។ នៅមានពលករខ្មែរ ប្រមាណជាង សែសិបម៉ឺននាក់ទៀត ដែលភាគច្រើន ធ្វើការនៅលើផ្នែកកសិកម្ម ឧស្សាហកម្ម សំណង់ និងតាមរោងចក្រសហគ្រាសមួយចំនួន។ ដោយឡែក អាជីវករ និងពាណិជ្ជករមួយចំនួន ដែលមានទំនាក់ទំនងសេដ្ឋកិច្ច ក្នុងការនាំទំនិញ ចេញចូលពីប្រទេសថៃ ក៏ត្រូវទទួលរងផលប៉ះពាល់ពីការបិទព្រំដែនដែរ។ បន្ថែមលើសពីនេះ អំពើឈ្លានពានដ៏សាហាវ យង់ឃ្នង និងខុសច្បាប់ ដែលបង្កឡើងដោយកងទ័ពថៃ តាំងតែពីថ្ងៃទី ០៧ រហូតមកដល់ចុងខែធ្នូ ឆ្នាំ២០២៥ មកលើបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយបើកវាយប្រហារយ៉ាងខ្លាំងក្លា និងដោយឥតរើសមុខ ដោយប្រើប្រាស់ កាំភ្លើងធំធុនធ្ងន់ យន្តហោះចម្បាំងគ្រប់ប្រភេទ F-16 និង T-50TH ព្រមទាំងអាវុធដទៃទៀត មកលើប្រជាជនស៊ីវិល នៅតាមបណ្តាខេត្តជាប់ព្រំដែន ដែលបណ្តាលឱ្យមានជនភៀសសឹកជាងកន្លះលាននាក់ ត្រូវបានជម្លៀសចេញពីលំនៅដ្ឋាន រួមមានទាំងស្ត្រី និងកុមារផងដែរ។

នៅក្នុងស្ថានភាពដ៏លំបាក និងឥតព្រាងទុកនេះ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ ក្រោមការដឹកនាំដ៏ឈ្លាសវៃ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ស្របតាមគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** បានដាក់ចេញនូវវិធានការគន្លឹះជាបន្ទាន់ ដើម្បីដោះស្រាយជីវភាពពលករខ្មែរ ដែលបានវិលត្រឡប់ ដោយការបង្កើនឱកាសការងារ និងមុខរបរ ដែលអាចស្រូបទាញដោយ រោងចក្រ សហគ្រាស ក្រុមហ៊ុន ដែលបានវិនិយោគនៅកម្ពុជា និងការបង្កលក្ខណៈក្នុងការបង្កើតមុខរបរខ្នាតតូច ឬមធ្យម ទៅតាមកម្រិតវ័យ មុខជំនាញ ចំណង់ចំណូលចិត្ត និងសមត្ថភាព ឬទេពកោសល្យ និងដោះស្រាយការលំបាករបស់ប្រជាពលរដ្ឋខ្មែរដែលជាជនភៀសសឹកដោយសារអំពើឈ្លានពានដ៏សាហាវ យង់ឃ្នង និងខុសច្បាប់ បង្កឡើងដោយកងទ័ពថៃ ដែលបានបំផ្លាញ វត្ត សាលា ផ្ទះសំបែងជាច្រើនខ្នង សិស្សសាលា ក្មេងចាស់ ប្រុសស្រី ត្រូវបង្ខំចិត្តភៀសខ្លួនរកទីកន្លែងមានសុវត្ថិភាពបណ្តោះអាសន្នភ្លាមៗ។ បញ្ហាប្រឈមជាច្រើន ត្រូវបានដោះស្រាយ អាស្រ័យដោយមានការចូលរួមជាធ្លុងមួយ ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការដៃគូនានា ទៅតាមវិស័យជំនាញរៀងៗខ្លួនយ៉ាងសកម្ម និងស្រុះដៃគ្នា ជាពិសេសសាមគ្គីឯកភាពជាតិនៃប្រជាពលរដ្ឋខ្មែរ។ នេះជាមោទនភាពរបស់ប្រជាជាតិខ្មែរ ដែលមានការជឿទុកចិត្ត រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទ្រោលសភាពការណ៍ដ៏លំបាកនេះ។

ដោយឡែក ការបង្ក្រាបបទល្មើសស្តេមអនឡាញ ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ក៏ត្រូវបាន សម្តេចមហាបវរធិបតី ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដាក់ចេញនូវវិធានការមុតស្រួច ដោយប្រគល់ភារកិច្ចជូនអភិបាលរាជធានី-ខេត្ត ដឹកនាំការអនុវត្តវិធានការបង្ក្រាបបទល្មើសស្តេមអនឡាញនេះ ដោយផ្ទាល់ក្នុងដែនដីដែលទទួលខុសត្រូវរៀងៗខ្លួនផងដែរ និងទទួលបានលទ្ធផលល្អគួរឱ្យកត់សម្គាល់ ពោល គឺក្នុងរយៈពេលត្រឹមតែបួនខែ គិតចាប់ពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ បានបង្ក្រាបទីតាំងសង្ស័យរហូតដល់ទៅ ៩២ទីតាំង ក្នុង១៨រាជធានី ខេត្ត និងឃាត់ខ្លួនជនសង្ស័យបាន ៧៥នាក់ ក្នុង១០សំណុំរឿង ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមអនឡាញ ឃាតកម្ម និងអំពើជួញដូរមនុស្ស ។

សរុបមក ក្នុងឆ្នាំ២០២៥ នេះ បើទោះបីជាបទល្មើសជួញដូរមនុស្ស បទល្មើសឆបោកតាមប្រព័ន្ធអនឡាញ និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន កើនឡើងគ្រប់ទីកន្លែងអាស្រ័យដោយស្ថានភាព

ប្រែប្រួលពិបាកប៉ាន់ស្មាននៃវិបត្តិនយោបាយ សេដ្ឋកិច្ច សន្តិសុខ និងគ្រោះធម្មជាតិ ដែលកើតមានចំពោះព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និងក្នុងពិភពលោកក្តី ក៏គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព នៅថ្នាក់ជាតិ និងរាជធានី-ខេត្ត និងមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធផង បានធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការទាំងឡាយ ដែលបានធ្វើឡើងតាមយុទ្ធសាស្ត្រដែលបានកំណត់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រព្រឹត្តទៅយ៉ាងសកម្ម និងឆ្លើយតបបានទាន់សភាពការណ៍គួរឱ្យមោទនៈ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

**ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា** អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០២៥នេះ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយដោយផ្ទាល់ ដល់ប្រជាពលរដ្ឋបានយល់ដឹងអំពីច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កលល្បិចជនល្មើស ការប្រែប្រួលនៃទម្រង់បទល្មើស ការបង្ការទប់ស្កាត់ភាពរងគ្រោះដោយប្រព័ន្ធបច្ចេកវិទ្យា អ៊ីនធឺណិតអនឡាញ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព... ការធ្វើយុទ្ធនាការផ្សព្វផ្សាយតាមរយៈការប្រារព្ធ ទិវាសុវត្ថិភាពអ៊ីនធឺណិត ទិវាជាតិអន្តរសាសនា ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទិវាអន្តរជាតិសម្រាប់ពលករទេសន្តរប្រវេសន៍ពិពណ៌ការងារ និងផលិតផលជាតិ យុទ្ធនាការ «តើអ្នកមើលឃើញខ្ញុំទេ» ការផ្សព្វផ្សាយនៅតាមគ្រឹះស្ថានសិក្សារដ្ឋ ឯកជន និងការអប់រំក្រៅប្រព័ន្ធ ការផ្សព្វផ្សាយរបាយការណ៍ វេទិកាសាធារណៈ ការអនុវត្ត គោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" និងវេទិកាផ្សព្វផ្សាយដោយមន្ទីរអង្គភាពថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងតាមកម្មវិធីផ្សេងៗ សរុបចំនួន **២៤៥.៦៣៣**លើក មានអ្នកចូលរួមសរុបចំនួន **១៣.៨៨៩.៤៣៤**នាក់ ស្រី **៦.៥៤៥.៧៨៧**នាក់ (ធៀបនឹង ឆ្នាំ២០២៤ មានចំនួន **៩.៣៣៣.៩៦៩**នាក់) គឺមានការកើនឡើងចំនួន **៤.៥៥៥.៤៦៥**នាក់ ស្មើនឹង **៤៨,៨០%** ដូចមានក្នុងតារាងខាងក្រោម៖

*(__សម្គាល់៖__ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងៗទៀតឡើយ)*

***តារាងទិន្នន័យសរុបការផ្សព្វផ្សាយ***

| | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស | ០១ | ២.៤៨៥ | ៧០៩ |
| | -សៀមរាប | ០១ | ៣០០ | ១១៧ |
| | -ស្វាយរៀង | ០១ | ៣១២ | ៧៨ |
| ២ | ទិវាជាតិអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ០១ | ៦៦.១៥៨ | ៣០.២១៥ |
| ៣ | ទិវាអន្តរជាតិសម្រាប់ពលករទេសន្តរប្រវេសន៍ | ០១ | ២២០ | ៨៣ |
| ៤ | ពិពណ៌ការងារ និងផលិតផលជាតិ | ០១ | ៩៥.៥២២ | ០០ |
| ៥ | យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ | ០២ | ៧០៥ | ៣៥៥ |
| ៦ | យុទ្ធនាការ «តើអ្នកមើលឃើញខ្ញុំទេ» សៀមរាប | ០៤ | ៦៧៥ | ៣៧៨ |
| ៧ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ២៣៧.៤៦៧ | ១៣.៣៨៤.៩៦៦ | ៦.៣៤៤.៦៥០ |
| ៨ | ការបញ្ជ្រាបតាមកម្មវិធីផ្សេងៗ | ៨.១៥៤ | ៣៣៨.០៩១ | ១៦៩.២០២ |
| | សរុប | ២៤៥.៦៣៣ លើក | ១៣.៨៨៩.៤៣៤ នាក់ | ៦.៥៤៥.៧៨៧ នាក់ |

❖ **ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ២០សីហា លើកទី៩ ឆ្នាំ២០២៥ ក្រោមប្រធានបទ «**សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា**» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** និង**លោកជំទាវ** ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងបានសហការជាមួយ ក្រសួងធម្មការនិងសាសនា និងមេដឹកនាំនិកាយសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជាមានសាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រីស្ត ព្រមទាំងមានការចូលរួមគាំទ្រពី អង្គការការីតាសកម្ពុជា និងអង្គការ ERIKS ការដង្ហែរក្បួនព្យុហយាត្រាក្រោមប្រធានបទ «**សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា**» នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ ដោយអញ្ជើញចូលរួម ពីសមាជិកព្រឹទ្ធសភា រដ្ឋសភា ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាល អង្គទូតនានាដែលមាននិវេសនដ្ឋានកម្ពុជា មេដឹកនាំសាសនា និងសាសនិក នៃនិកាយសាសនាធំៗ ក្រុមប្រឹក្សា អភិបាលរាជធានី ខេត្ត ខណ្ឌ សង្កាត់ មន្ត្រីរាជការ យុវជន យុវនារី កងកម្លាំងគ្រប់ប្រភេទ និងអង្គការដៃគូជាតិ អន្តរជាតិ សរុបប្រមាណ **២.៤៨៥**រូប ស្រី **៧០៩**រូប។

▪ **លេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តស្វាយរៀង ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ** បានរៀបចំទិវាអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា» ដោយមានការអញ្ជើញចូលរួម មេដឹកនាំសាសនា និងសាសនិកនៃនិកាយសាសនាធំៗ និងតំណាងមន្ទីរអង្គភាព ស្ថាប័ន គណៈ អភិបាលក្រុង ស្រុក ចៅសង្កាត់ និងអង្គការដៃគូជាតិ អន្តរជាតិ សរុបប្រមាណ **៣១២**រូប ស្រី **៧៨**រូប និងខេត្តសៀមរាប **៣០០**រូប ស្រី **១១៧**នាក់។

▪ **ទិវាជាតិអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានរៀបចំទិវាជាតិអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៨ ឆ្នាំ២០២៥ ក្រោមប្រធានបទ «TVET បង្កើតឱកាសការងារ សាងក្តីសង្ឃឹមដល់យុវជន» ក្រោមអធិបតីភាព **ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដែលមានអ្នកចូលរួមសរុបចំនួន **៦៦.១៥៨**នាក់ ស្រី **៣០.២១៥**នាក់។

▪ **ទិវាអន្តរជាតិសម្រាប់ពលករទេសន្តរប្រវេសន៍ ក្រុមការងារទេសន្តរប្រវេសន៍ នៃគ.ជ.ប.ជ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានរៀបចំទិវាអន្តរជាតិសម្រាប់ពលករទេសន្តរប្រវេសន៍ ឆ្នាំ២០២៥ ក្រោមប្រធានបទ «ផ្តល់តម្លៃដល់ពលករទេសន្តរប្រវេសន៍ និងគាំទ្រដល់ការវិលត្រឡប់និងសមាហរណកម្មដោយជោគជ័យ» ក្រោមអធិបតីភាព **ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ដោយសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO), អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM), ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) និងសហភាពអឺរ៉ុប (EU) ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ សហជីព សមាគមនិយោជក សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ទី

ភ្នាក់ងារជ្រើសរើសឯកជន ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិជាដៃគូ និងអតីតពលករទេសន្តរប្រវេសន៍ ដែលមានសមាសភាពចូលរួមសរុបចំនួន **២២០**នាក់ ស្រី **៨៣**នាក់។

▪ **ពិព័រណ៍ការងារ និងផលិតភាពជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានរៀបចំពិព័រណ៍ការងារ និងផលិតភាពជាតិ ក្នុងគោលបំណងសំខាន់ៗរួមមាន៖ (១)បង្កើតជាវេទិកាជំនួបដ៏ធំរវាង អ្នកស្វែងរកការងារ និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ដើម្បីដាក់ពាក្យស្វែងរកការងារ ជ្រើសរើសបុគ្គលិក ផ្សព្វផ្សាយព័ត៌មានឱកាសការងារ វគ្គអប់រំបណ្តុះបណ្តាល និងប្រឹក្សាយោបល់អាជីព ការងារ និងវិជ្ជាជីវៈ។ (២)បង្កើនការយល់ដឹង បណ្តុះផ្នត់គំនិត និងផ្សព្វផ្សាយពីការបង្កើនផលិតភាពការងារ ក្នុងន័យជំរុញឱ្យអ្នកចូលរួមមើលឃើញខ្លួនឯងជាផ្នែកមួយដ៏សំខាន់នៃកម្លាំងពលកម្ម ដែលកំពុងជំរុញផលិតភាព និងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា តាមរយៈកិច្ចពិភាក្សាស្តីពីការចែករំលែកបទពិសោធដោយ វាគ្មិនដែលមានបទពិសោធន៍ក្នុងវិស័យការងារនិងបច្ចេកវិទ្យា និង(៣)បង្កើតជាវេទិកាតភ្ជាប់បណ្តាញទំនាក់ទំនងក្នុងចំណោម ក្រសួង ស្ថាប័ន និងក្រុមហ៊ុន ដែលមានអ្នកចូលរួមចំនួន **៩៥.៥២២**នាក់។

❖ **យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥**

▪ **អគ្គលេខាធិការដ្ឋាន** នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** ព្រមទាំងមានការសហការឧបត្ថម្ភពីអង្គការ APLE, OneChild, Terre des Hommes, Childhood, ម្លប់តាប៉ាង និងក្រុមហ៊ុនស្មាតអាស៊ីតា បានប្រារព្ធកម្មវិធីអបអរសាទរយុទ្ធនាការគាំទ្រ **«ទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥»** ចំនួន **០២លើក** ក្រោមប្រធានបទ «កុមារឆ្លាតវៃយល់ដឹងពីសុវត្ថិភាព និងចេះការពារខ្លួនតាមអនឡាញ» នៅវិទ្យាស្ថានជាតិអប់រំ និងសាលាប៊ែលធីអន្តរជាតិ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គលេខាធិការរង អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន តំណាងអង្គការដៃគូជាតិ អន្តរជាតិ តំណាងក្រុមហ៊ុនឯកជន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស សរុបប្រមាណ **៧០៥**នាក់ ស្រី **៣៥៥**នាក់។

❖ **យុទ្ធនាការ "តើអ្នកមើលឃើញខ្ញុំទេ?"**

▪ **ខេត្តសៀមរាប៖** បានសហការជាមួយមន្ទីរអប់រំយុវជន និងកីឡាខេត្ត វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, សាកលវិទ្យាល័យអង្គរ, អង្គការមូលនិធិអេ២១ និងអង្គការសម្ព័ន្ធចាប់ដៃ រៀបចំយុទ្ធនាការ **"តើអ្នកមើលឃើញខ្ញុំទេ"** ដោយបានចាក់បញ្ចាំងខ្សែភាពយន្តអប់រំ ចំណងជើង **"សន្យា" និង " ស្នេហ៍តាមអនឡាញ"** ដើម្បីបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ ជូនដល់សិស្ស និស្សិត នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប សាកលវិទ្យាល័យអង្គរ និងសាកលវិទ្យាល័យបៀលប្រាយសាខាខេត្តសៀមរាប បានចំនួន **០៤លើក** ដែលមានសិស្ស និស្សិតចូលរួមសរុប **៦៧៥**នាក់ ស្រី **៣៧៨**នាក់។

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ ឃុំ-សង្កាត់ មានសុវត្ថិភាព**

ក្នុងឆ្នាំ២០២៥ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូមួយចំនួន បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋរួមគ្នា និងដោយឡែកពីគ្នាតាមរយៈការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ វេទិកាសាធារណៈ និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ/សង្កាត់ មានសុវត្ថិភាព" សរុបចំនួន **២៣៧.៤៦៧**លើក មានអ្នកចូលរួមសរុបចំនួន **១៣.៣៨៤.៩៦៦**នាក់ ស្រី **៦.៣៤៤.៦៥០**នាក់ (ធៀបនឹង ឆ្នាំ២០២៤ មានអ្នកចូលរួម

ចំនួន **៩.០៨១.២៧៣**នាក់ គឺមានការកើនឡើងចំនួន **៤.៣០៣.៦៩៣**នាក់ ស្មើនឹង **៤៧,៣៩%**) ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ/ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **អន្តរក្រសួង** | | | | | | | |
| ១ | ក្រសួងកិច្ចការនារី | | | | ០២ | ២២៦ | ២២៦ |
| ២ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១៧ | ៦៨៩.៥៥៣ | ១១.៣៥៩ | | | |
| ៣ | ក្រសួងអប់រំ យុវជន និងកីឡា | ០១ | ២៥៧ | ១៣៨ | | | |
| ៤ | ក្រសួងអភិវឌ្ឍន៍ជនបទ | ០៤ | ២៣៩ | ៨៥ | | | |
| ៥ | ក្រសួងទេសចរណ៍ | ១០ | ១.៥៣១ | ៩៧០ | | | |
| ៦ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ៤៥ | ២.៧១៥ | ១.២០៤ | | | |
| ៧ | កាកបាទក្រហម | ៨១ | ៤.២២៣ | ២.២១២ | | | |
| | **សរុប** | **១៥៨** | **៦៩៨.៥១៨** | **១៥.៩៦៨** | **០២** | **២២៦** | **២២៦** |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ២២.១៧៣ | ២.០៧២.៣៧២ | ១.០៨៩.១៧៧ | ១.៨៨៣ | ១០២.៦៥៨ | ៥១.៣២៤ |
| ២ | ខេត្តកណ្ដាល | ៤.៦៩៩ | ៣៤៤.៤០៩ | ១៧៦.១៤៩ | ២.១១៧ | ៣៧.៨០០ | ២៦.៥៧១ |
| ៣ | ខេត្តបាត់ដំបង | ១០.៦១៣ | ៥២៨.៥០៣ | ២៩៣.២៨៤ | ៧.៨៣៧ | ២៥៧.៩៩៨ | ១៤៨.៩៥២ |
| ៤ | ខេត្តពោធិ៍សាត់ | ៦.២៣៣ | ៥៩៦.១១៣ | ២៧៤.៥៥៤ | ៣.៥៧៦ | ១៤៥.៩៨៩ | ៧០.៦៧៥ |
| ៥ | ខេត្តសៀមរាប | ៩.១៥៧ | ៦៥៥.៤៨៩ | ៣៨៩.៣៨៩ | ៧.៩៧៦ | ២៩៩.៣៣៩ | ១៩១.៧៦៦ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៩.១០៤ | ៣៤៥.៨៧៩ | ១៨៨.៥៧១ | ៤.៥១០ | ១៦២.៧០០ | ៨៧.៩២៣ |
| ៧ | ខេត្តកំពង់ចាម | ១២.០២១ | ៦៨៥.០៤៩ | ៣៤៦.០៧៤ | ២២ | ១.៧៥៦ | ៩៥៩ |
| ៨ | ខេត្តព្រះសីហនុ | ៣.៤១៩ | ១០៦.៥៩៩ | ៤៨.៦៦៨ | ១.៣៩៧ | ៤៥.៥៨៨ | ២២.០៧៩ |
| ៩ | ខេត្តព្រះវិហារ | ២៤៤ | ៣១.២៦៩ | ១៧.២៦១ | ១៧ | ១.៧១២ | ៥៣៨ |
| ១០ | ខេត្តស្វាយរៀង | ១.៩៦៨ | ៩៦.៨០១ | ៥៦.២១៦ | ២.៥១៨ | ៩៣.៩០៧ | ៥៨.៦៧៥ |
| ១១ | ខេត្តប៉ៃលិន | ០០ | ០០ | ០០ | ១.១៣៨ | ៤៩.២១០ | ២៤.៣៧០ |
| ១២ | ខេត្តកោះកុង | ១៣.៧៩១ | ២២៦.៩៦៧ | ១០៣.០១០ | ៤.០៣៦ | ៦៨.៧០៤ | ៣១.៨៩៣ |
| ១៣ | ខេត្តកំពត | ០០ | ០០ | ០០ | ១៣.១៨១ | ៦៥៨.៣៣៩ | ៣៥៧.១២៨ |
| ១៤ | ខេត្តកំពង់ធំ | ៨.៣៤៤ | ១.៦៦៧.២១៤ | ៣៩១.៦០៣ | ២.៦៤៩ | ១១៣.០១៧ | ៦៤.២៨២ |
| ១៥ | ខេត្តតាកែវ | ៣.៦៨០ | ១៨៧.៨៧១ | ៨៦.១០៣ | ០០ | ០០ | ០០ |
| ១៦ | ខេត្តក្រចេះ | ៧២៧ | ២៣.០៣០ | ១២.៤៤៧ | ០០ | ០០ | ០០ |
| ១៧ | ខេត្តកែប | ៦៣៣ | ១២០.៨៤៣ | ៤៦.៩១៨ | ១.២៧៧ | ៥៣.១៨៤ | ២៩.៦៧៧ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៤.៦៨៦ | ២៧៥.៣៥៦ | ១៤១.០៥២ | ៨១៧ | ៤៣.២៣៥ | ២២.០៤០ |
| ១៩ | ខេត្តស្ទឹងត្រែង | ២.៨៨៥ | ១៦៦.១០៨ | ៨៨.១៤៦ | ២.១១៥ | ៦៥.៤៤៣ | ៤១.៧៩៦ |
| ២០ | ខេត្តរតនគិរី | ៦.៩៨៩ | ៣១៧.៦៥០ | ១៥៤.៦៥៣ | ៣.៦១៦ | ១៨០.២៥៦ | ៨៦.៨៥៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២១ | ខេត្តព្រៃវែង | ១២.៤៩៩ | ៧៣៣.៤៥០ | ៥០៤.៨៦៥ | ៩.១៤៦ | ៣០៥.៦៨៧ | ១៦៧.១៦១ |
| ២២ | ខេត្តត្បូងឃ្មុំ | ៣៨២ | ៣៨.៥០០ | ៣០.៨៣២ | ៨២៣ | ២៣.៣៥៩ | ១០.៣៦៨ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១៣.៥៤៣ | ២៤៤.៨៣៧ | ១៤៣.០៤៦ | ១៤.១៤២ | ២៦៣.១០៨ | ១៥០.០២១ |
| ២៤ | ខេត្តឧត្តរមានជ័យ | ១.៦៨៨ | ៩៣.៤៤០ | ៤៨.៦៧០ | ១៨៤ | ១២.៩៧៦ | ៧.២៣៩ |
| ២៥ | ខេត្តមណ្ឌលគិរី | ២.៥៣៩ | ១០៤.៩៨១ | ៣៥.២២១ | ៣១៣ | ៣៧.៥២៧ | ១០.២៥៧ |
| សរុប រាជធានី-ខេត្ត | | ១៥២.០១៧ | ៩.៦៦២.៧៣០ | ៤.៦៦៥.៩០៩ | ៨៥.២៩០ | ៣.០២៣.៤៩២ | ១.៦៦២.៥៤៧ |
| សរុបរួម | | ២៣៧.៤៦៧ លើក | | ១៣.៣៨៤.៩៦៦ នាក់ | | ៦.៣៤៤.៦៥០ នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) សហការជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ បានផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរតាមរយៈកម្មវិធីផ្សេងៗ ដូចជា៖

១-គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ឆ្នាំ២០២៤ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ។

២-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ៖ ទិវាវប្បធម៌ជាតិ ៣មីនា ឆ្នាំ២០២៥ សិក្ខាសាលា ការប្រជុំផ្សព្វផ្សាយ (ផ្ទៃក្នុងនិងផ្ទៃក្រៅ)។

៣-ក្រសួងធម្មការ និងសាសនា៖ កម្មវិធីគ្រប់គ្រងនិងបណ្តុះបណ្តាល កម្មវិធីទស្សនាទានព្រះពុទ្ធសាសនាពង្រឹង និងពង្រីកកម្មវិធីបញ្ជ្រាប គុណធម៌ សីលធម៌ ដោយផ្សារភ្ជាប់ព្រះពុទ្ធសាសនាទៅក្នុងសង្គម និងកម្មវិធីនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម

៤-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ការត្រៀមរៀបចំទិវាអន្តរជាតិនារី៨ មីនា ឆ្នាំ២០២៥ កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងទិសដៅការងារបន្ត របស់សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ កិច្ចប្រជុំបូកសរុបការងារវេទិកាសាធារណៈ បញ្ហាប្រឈម និងទិសដៅបន្ត របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន

៥-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល មន្ត្រីទទួលបន្ទុកការងារទេសន្តរប្រវេសន៍ និងគ្រូបង្គោលនៅថ្នាក់ក្រោមជាតិ ការរៀបចំទិវាពលកម្មអន្តរជាតិ ទិវាពិភពលោកប្រឆាំងពលម្មកុមារ

៦-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ បានបញ្ជ្រាបការយល់ដឹងពីការបង្ការ និងទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងទិវាជ័យជម្នះ ៧មករា ឆ្នាំ២០២៥, ទិវាអន្តរជាតិនារី ៨មីនា, កិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់សាខាសមាគមនារីដើម្បីសន្តិភាពនិងអភិវឌ្ឍន៍, កម្មវិធីដាក់ពិន្ទុប្រកួតពានរង្វាន់សហគ្រិនស្ត្រីឆ្នើមក្នុងសេដ្ឋកិច្ចបៃតង ឆ្នាំ២០២៥ និងកិច្ចប្រជុំបូកសរុបការងារវេទិកាសាធារណៈ។

៧-ក្រសួងទេសចរណ៍ រៀបចំពិធីអបអរសាទរ ខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៥ ក្រោមប្រធានបទ "បញ្ឈប់អំពើហិង្សាលើកុមារប្រកបដោយចីរភាព និងលើកកម្ពស់ការងារសមរម្យ សម្រាប់កម្មករ និយោជិតវ័យក្មេងនៅគ្រប់ចង្វាក់ផលិតកម្ម ដើម្បីជានាក់ំណើនប្រកបដោយចីរភាព និងភាពធន់

សរុបបានចំនួន ៨.១៥៤លើក មានអ្នកចូលរួមចំនួន **៣៣៨.០៩១**នាក់ ស្រី **១៦៩.២០២**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ក្រសួង/ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| | **ថ្នាក់ជាតិ** | | | |
| ១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤៥១ | ១៣.២៩២ | ៥.២៩៩ |
| ២ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៣៥ | ១៣.១១៤ | ១.៤៣៦ |
| ៣ | ក្រសួងធម្មការ និងសាសនា | ១៤ | ២.៧២៩ | ៩៥៩ |
| ៤ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ០៦ | ៣៥៦ | ១៩៧ |
| ៥ | ក្រសួងទេសចរណ៍ | ០២ | ៥១២ | ០០ |
| | **ថ្នាក់ក្រោមជាតិ** | | | |
| ១ | រាជធានីភ្នំពេញ | ២.៩២២ | ១០៣.៤៤៣ | ៥១.៥១៦ |
| ២ | កណ្តាល | ៦៥០ | ៤៤.០៨០ | ១៦.៤៩៦ |
| ៣ | ប៉ៃលិន | ១៥ | ៥.៦៩៥ | ៣.០៤៦ |
| ៤ | សៀមរាប | ២.៣០៥ | ៥១.៤២៧ | ២៩.៥៨៥ |
| ៥ | កំពង់ឆ្នាំង | ១៦៦ | ៩៤៤ | ៥០៧ |
| ៦ | កំពង់ធំ | ២៧ | ២.២០៣ | ១.២៧៦ |
| ៧ | កំពង់ចាម | ៣៩ | ២.៣១៨ | ១.២៤៦ |
| ៨ | ព្រះវិហារ | ១៥ | ២.៨៧៥ | ១.០៨៨ |
| ៩ | ព្រៃវែង | ០៩ | ១.២៩៧ | ៦៦៨ |
| ១០ | ត្បូងឃ្មុំ | ១៧ | ១.១៤៩ | ៦១៤ |
| ១១ | កំពត | ៦១ | ១.៤០៥ | ១.០០៣ |
| ១២ | ឧត្តរមានជ័យ | ០៩ | ១១៥ | ៣៥ |
| ១៣ | ក្រចេះ | ២១ | ៣.៦០៩ | ១.៨៥២ |
| ១៤ | បន្ទាយមានជ័យ | ១០៩ | ១៥.៦២៤ | ៩.៣៨០ |
| ១៥ | ស្ទឹងត្រែង | ៧១០ | ២.៨៧៧ | ១.៦០៤ |
| ១៦ | មណ្ឌលគិរី | ១៦ | ៣.១៣៧ | ១.៤៨៩ |
| ១៧ | តាកែវ | ០៩ | ៩៤៧ | ៤១០ |
| ១៨ | កំពង់ស្ពឺ | ១៤៤ | ១០.៨២៧ | ៥.៩៣៥ |
| ១៩ | កោះកុង | ៨៩ | ២៧០ | ២៤០ |
| ២០ | កែប | ០៦ | ២.៣៩៨ | ៣២៥ |
| ២១ | រតនគិរី | ១៦ | ២២៤ | ១៥៩ |
| ២២ | ស្វាយរៀង | ១៨ | ៨០៣ | ៤៩៣ |
| ២៣ | បាត់ដំបង | ២០ | ១.១០៨ | ៤៦២ |
| ២៤ | ព្រះសីហនុ | ១១៤ | ៦.៦៤៤ | ៣.៤៨៨ |
| ២៥ | ពោធិ៍សាត់ | ០០ | ០០ | ០០ |
| ២៦ | អង្គការសេរីភាពកម្ពុជាអូស្ត្រាលី សហការជាមួយអង្គការ Terre des Hommes | ០១ | ១៣០ | ០០ |
| ២៧ | អង្គការអន្តរជាតិខាងការងារ (ILO) | ១១ | ២៤.៦៧៧ | ១៨.៤៤៣ |
| ២៨ | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) | ០៧ | ៨.៥០៦ | ៤.១៨៣ |

| | | | | |
|---|---|---|---|---|
| ២៩ | អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) | ១០ | ៧៨៨ | ៥៨៨ |
| ៣០ | អង្គការមូលនិធិហាការ (HAGAR) | ១០៤ | ៧.៨៧៤ | ៤.៩០៧ |
| ៣១ | អង្គការប្រិយសម្ពន្ធគ្រីស្ទបរិស័ទកម្ពុជា (ភ្នំពេញ, ពោធិ៍សាត់, កំពង់ឆ្នាំង) | ០៦ | ៦៩៤ | ២៧៨ |
| សរុបរួម | | ៨.១៥៤ លើក | ៣៣៨.០៩១ នាក់ | ១៦៩.២០២ នាក់ |

## ក.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ **ការផលិត និងចែកផ្សាយ សម្ភារៈផ្តល់ព័ត៌មាននិងអប់រំ** (IEC: Information Education Communication Materials)

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

-បានដាក់ឱ្យដំណើរការទូបញ្ជរសេវាសាធារណៈចល័ត (Mobile Public Service Counter) ឬកម្មវិធីក្នុងទូរស័ព្ទដៃដែលមានឈ្មោះ "MLVT Services" កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ ដើម្បីបង្កើនភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋខ្មែរ ដែលមានបំណងចង់ដាក់ពាក្យទៅធ្វើការនៅបរទេស ដែលមាននៅតាមទីតាំងមួយចំនួនដូចជា ទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ផ្សារទំនើប AEON បណ្តាសាកលវិទ្យាល័យមួយចំនួន ហាងកាហ្វេ Starbucks និង Brown និងទីតាំងមួយចំនួនទៀត ដើម្បីបង្កើនភាពងាយស្រួលសម្រាប់បងប្អូនប្រជាពលរដ្ឋដែលមានបំណងចង់ដាក់ពាក្យទៅធ្វើការនៅក្រៅប្រទេស

-ផលិតវីដេអូអំពីនីតិវិធីដាក់ពាក្យទៅធ្វើការនៅប្រទេសថៃ តាមរយៈបញ្ជរសេវាសាធារណៈចល័តចំនួន **៣៣**វីដេអូ

-បានផលិតវីដេអូ ស្តីពីភាពជោគជ័យរបស់ពលករទេសន្តរប្រវេសន៍ខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ចំនួន **០២**វីដេអូ

-ផលិតវីដេអូ ផ្សព្វផ្សាយមាតិកាអំពីសេវាផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន **៤៥៩**វីដេអូ

-បានបោះពុម្ពផ្សព្វផ្សាយខិត្តប័ណ្ណកម្មវិធី បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ចំនួន **៥៨៤,៩៩២**សន្លឹក

-បានផ្សព្វផ្សាយចល័តតាមសហគមន៍ រោងចក្រ សហគ្រាស ផ្សារ ទីប្រជុំជន និងតាមខ្នងផ្ទះ ស្តីពីកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ចំនួន **៤,៧៩៣**លើក ដែលមានអ្នកចូលរួមសរុបចំនួន **៣៧៩.០០២**នាក់ ស្រី **១៩០.០៣៨**នាក់

-បានបញ្ចប់ការរៀបចំសៀវភៅណែនាំតម្រង់ទិសពលករទេសន្តរប្រវេសន៍ខ្មែរ មុនចេញដំណើរទៅធ្វើការនៅប្រទេសថៃ និងបានដាក់ QR Code នៅលើសៀវភៅដើម្បីអាចចូលទៅក្នុងប្រព័ន្ធរបស់ក្រសួងដូចជាប្រព័ន្ធតាមដានពលករទេសន្តរប្រវេសន៍ App MLVT Service ក្រុមតេឡេក្រាម សម្រាប់ពលករទេសន្តរប្រវេសន៍

▪ **ភាកបាទក្រហមកម្ពុជា** បានចែកខិត្តប័ណ្ណ អំពីព័ត៌មានការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋនៅតាមគោលដៅ និងនៅតាមច្រកព្រំដែនចំនួន **៥០,០០០**សន្លឹក។

▪ **លេខាធិការដ្ឋាន គ.ជ.ប.ជ/គ.ខ.ប.ជ** មន្ទីរ/អង្គភាពពាក់ព័ន្ធ អាជ្ញាធរក្រុង/ស្រុក និងអង្គការដៃគូបានបិទបដាពាក្យស្លោកនៅតាមទីសាធារណៈ សាលារៀន កម្មវិធីផ្សេងៗ និងចែកខិត្តប័ណ្ណ ស្តីពីការបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព សៀវភៅណែនាំតូចៗ និងសម្ភារអប់រំផ្សេងៗ ដល់ពលករ និងប្រជាពលរដ្ឋ ដូចខាងក្រោម៖

| ល.រ | រាជធានី/ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|
| ១ | ខេត្តសៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ២៤២.៧៩៧សន្លឹក | ១១៥.៦៧២ | ៥.២០០ |
| ២ | ខេត្តបាត់ដំបង | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៣១.៣៥៧សន្លឹក | ៩.៧៥៧ | ៩០៦ |
| ៣ | ខេត្តបន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៦.១៨៦សន្លឹក | ៦.១៨៦ | ២.៤៣១ |
| ៤ | ខេត្តព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ<br>-តេលេក្រាម ហ្វេសប៊ុក | ១៤៣សន្លឹក | ៥.៥៤០ | ១.៤៨៤ |
| ៥ | ខេត្តឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៦.៧៧០សន្លឹក | ៦.០៤៩ | ១.២០៩ |
| ៦ | ខេត្តស្ទឹងត្រែង | -ចងបដាផ្សព្វផ្សាយ | ១៨បដា | ២៦១.៧៧៦ | |
| ៧ | ខេត្តកំពង់ចាម | -ចងបដាផ្សព្វផ្សាយ<br>-ប៉ាណូ | ៣៩បដា<br>១៨ផ្ទាំង | | |
| ៨ | ខេត្តស្វាយរៀង | -ចងបដាផ្សព្វផ្សាយ | ១០បដា | | |
| ៩ | ខេត្តកំពង់ឆ្នាំង | -ចងបដាផ្សព្វផ្សាយ | ០៨បដា | | |
| | ខេត្តប៉ៃលិន | -ខិត្តប័ណ្ណផ្សព្វផ្សាយ<br>-បដាផ្សព្វផ្សាយ | ១៥,៤៥០សន្លឹក<br>១០បដា | ១២.៣៣០ | ៤.២១៥ |
| | ខេត្តព្រះសីហនុ | -បដាផ្សព្វផ្សាយ | ០៨បដា | | |
| ១០ | អង្គការសាម៉ារីតាន់ភីស (បាត់ដំបង) | -ដំឡើងប៉ាណូផ្សព្វផ្សាយ<br>-ខិត្តប័ណ្ណផ្សព្វផ្សាយ | ១៩ផ្ទាំង<br>៣៣,២៨៣សន្លឹក | | |
| ១១ | អង្គការម៉ារីស៊ី | -ខិត្តប័ណ្ណផ្សព្វផ្សាយ<br>-ចងបដាផ្សព្វផ្សាយ | ៥.០៦៧សន្លឹក<br>៥១៥បដា | | |
| ១២ | អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី (LSCW) | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៧,០០០សន្លឹក | ៥.០០០ | |
| ១៣ | អង្គការសាម៉ារីតាន់ភីស (បន្ទាយមានជ័យ) | | | ២០.០១២ | ៨.៥៣៧ |
| ១៤ | អង្គការម៉ារីស៊ី (ភ្នំពេញ) | -ខិត្តប័ណ្ណផ្សព្វផ្សាយ<br>-ដំឡើង ប៉ាណូ<br>-ចងបដាផ្សព្វផ្សាយ | ១៥.១១៤សន្លឹក<br>៥៥ផ្ទាំង<br>០៥បដា | | |
| | សរុប | | - ៣៦៣.១៦៧ សន្លឹក<br>- ៦១៣ បដា<br>- ៦៤ ផ្ទាំង | ៤៤២.៣២២ នាក់ | ២៣.៩៨២ នាក់ |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិចត្រូនិក**

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន គ.រ.ប.ជ/គ.ខ.ប.ជ មន្ទីរអង្គភាព សហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង នៅតាមបណ្តាស្ថានីយវិទ្យុ ទូរទស្សន៍ តាមបណ្តាញសង្គម ការផលិតស្ព័ត វីដេអូអប់រំខ្លីៗ ទទួលបានលទ្ធផលដូចខាងក្រោម៖

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- ផលិត និងផ្សព្វផ្សាយមាតិកាថ្មីអំពីសេវាការងារសាធារណៈលើគេហទំព័រការងារ កម្មវិធីការងារលើទូរស័ព្ទដៃឆ្លាត និង Facebook ចំនួន ៣១៧ដង
- ប្រជាពលរដ្ឋ សិស្សនិស្សិត បានចូលប្រើប្រាស់គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារ ចំនួន ៣.៣៧២.១០៣លើក

- បានផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារការងារតាមរយៈទំព័រ Facebook ដោយមានអ្នកទទួលព័ត៌មានសរុបចំនួន ១.០៦៤.៩២៩នាក់ និងព័ត៌មានតាមរយៈ TikTok ចំនួន ២.៤៩២.៨៦៣លើក
- ការផលិតស្ព័តកម្មវិធីនាទីទីផ្សារការងារ និងមុខរបរ ចំនួន ១២ស្ពត និងធ្វើការចាក់ផ្សាយតាមស្ថានីយទូរស្សន៍ និងបានផលិតស្ព័តជាសំឡេង ស្តីពីសេវាការងារ និងព័ត៌មានទីផ្សារការងារ ចំនួន ៣៧ស្ព័ត និងធ្វើការចាក់ផ្សាយបានចំនួន ៣.៧០០ដង
- អ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទវៃឆ្លាតសរុបចំនួន ៦.៥៩៤នាក់
- បានផ្សព្វផ្សាយអំពីការផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ដល់សាធារណជន សិស្សានុសិស្ស និស្សិត ជាពិសេស យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ តាមរយៈវិទ្យុ ៣៨៤ដង ទូរទស្សន៍ចំនួន ១២១ដង សារព័ត៌មានចំនួន ១២២ដង វេបសាយចំនួន ១.០០៦ដង និងតាមបណ្តាញសង្គម (Facebook) ចំនួន ៣៦.១៥៧ដង ដែលមានអ្នកចូលមើលសរុបចំនួន ៩៤.៤០១.០៥២លើក និងចែករំលែកបន្តចំនួន ៣៧១.៥០៩លើក
- បានរៀបចំបញ្ញើសារអេឡិចត្រូនិកខ្លី (Pushing Message) ស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាពតាមបណ្តាញទូរស័ព្ទដៃ
- បានផ្សព្វផ្សាយសារអំពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ តាមរយៈសារអេឡិចត្រូនិចខ្លី (Pushing Message)
- ដាក់ឱ្យដំណើរការប្រព័ន្ធ Hotline លេខ១១២៩៧ ដោយដាក់ឱ្យមានអ្នកប្រចាំការ ៧ថ្ងៃ/សប្តាហ៍ ដើម្បីផ្តល់ព័ត៌មានទៅសហគ្រាស ក្រុមហ៊ុន រោងចក្រ
- បង្កើនការផ្សព្វផ្សាយប្រព័ន្ធ Hotline ១២៩៧ និងប្រព័ន្ធ Telegram Bot ដោយបានដំឡើងផ្ទាំងប៉ាណូផ្សព្វផ្សាយបន្ថែមនៅតាមផ្លូវជាតិសំខាន់ៗ

▪ **ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ នៃគ.ជ.ប.ជ** សហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) ជំរុញក្រុមហ៊ុនទូរស័ព្ទធ្វើការផ្សព្វផ្សាយសារអប់រំដល់ប្រជាពលរដ្ឋ តាមរយៈទូរស័ព្ទចល័ត ចំនួន ០៤លើកៈ

- កម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាព អ៊ីនធឺណិត ឆ្នាំ២០២៥ ដែលមានខ្លឹមសារ «កុមារឆ្លាតវៃយល់ដឹងពីសុវត្ថិភាព និងចេះការពារខ្លួនតាមអនឡាញ»។
- ទិវាកុមារអន្តរជាតិ ខួបលើកទី៧៦ ឆ្នាំ២០២៥ ដែលមានខ្លឹមសារ «រួមគ្នាការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានគ្រប់ទម្រង់ ជាពិសេសតាមប្រព័ន្ធអនឡាញ»។
- ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស លើកទី០៩ ឆ្នាំ២០២៥ ដែលមានខ្លឹមសារ «២០ សីហា សុខដុមនីយកម្មសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស»។
- ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ដែលមានខ្លឹមសារ «រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ»។

▪ **លេខាធិការដ្ឋានរាជធានី-ខេត្ត៖**

| ល.រ | រាជធានី/ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក/ដង | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | -វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក | ២៥.៤២១ | |
| ២ | ខេត្តសៀមរាប | -វិទ្យុ<br>-ផលិតវីដេអូអប់រំខ្លី ស្តីពីការធ្វើទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព និងស្របច្បាប់<br>-សម្តែងរឿងអប់រំខ្លី | ១,៩៧២<br>០៣<br><br>០៣ | <br>៥០<br><br>៤០០ |
| ៣ | ខេត្តព្រៃវែង | -វិទ្យុជាតិ | ៦០០ | |
| ៤ | កំពង់ចាម | -វិទ្យុជាតិ៖ ចាក់ស្ប៉ត អប់រំខ្លីៗ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០៦ស្ប៉ត។ | ៤៥០ | |
| ៥ | ខេត្តត្បូងឃ្មុំ | -វិទ្យុជាតិ ចាក់ផ្សាយរឿងអប់រំខ្លីៗ | ៩៦ | |
| ៦ | ខេត្តបន្ទាយមានជ័យ | -វិទ្យុជាតិ | ៨០ | |
| ៧ | ខេត្តប៉ៃលិន | -វិទ្យុជាតិ | ៥,៩៥២ | |
| ៨ | ខេត្តកំពង់ស្ពឺ | -វិទ្យុជាតិ | ៥,៤០០ | |
| ៩ | ខេត្តកំពង់ឆ្នាំង | -ផលិតរឿងខ្លីមួយរឿង ត្រៀមផ្សព្វផ្សាយ ទិវា១២ធ្នូ | | |
| ១០ | ខេត្តព្រះសីហនុ | -វិទ្យុជាតិ ចាក់ផ្សាយឃ្លីបអប់រំខ្លីៗ ចំនួន ០៦ឃ្លីប | ៤,៣២០ | |
| ១១ | អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) | -វីដេអូខ្លី | ០១ | ៥.៩៥៣ |
| | សរុប | | ៤៤,២៩៨ លើក | ៦.០០៣ នាក់ |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីនានា**

| ល.រ | ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | វិទ្យុ ទូរទស្សន៍ និងផ្សេងៗ | ចំនួនលើក |
|---|---|---|---|
| ១ | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | ១-លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានផ្តល់៖<br>-បទសម្ភាសជាមួយសារព័ត៌មានខ្មែរថាម ស្តីពីស្ថានភាពអំពើជួញដូរមនុស្សនៅកម្ពុជា និងផែនការរបស់ គ.ជ.ប.ជ ឆ្នាំ២០២៥។<br>-កិច្ចសម្ភាសន៍ ជូនអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន ក្រោមប្រធានបទ យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៥ "កុមារឆ្លាតវៃយល់ដឹងពីសុវត្ថិភាព និងចេះការពារខ្លួនតាមអនឡាញ"។<br>-បទសម្ភាសន៍ជាមួយសារព័ត៌មាន Fresh News ស្តីពី"ការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ" ដើម្បីផ្សព្វផ្សាយ។<br>-ចូលរួមកម្មវិធី "Matter Podcast" ក្រោមប្រធានបទ "ស្ត្រីក្នុងភាពជាអ្នកដឹកនាំ នៃដំណើរការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស" ដើម្បីអបអរសាទរ និងចូលរួមចែករំលែកបទពិសោធន៍ ក្នុងទិវានារីអន្តរជាតិខួបលើកទី១១៤។<br>២-លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញផ្តល់កិច្ចសម្ភាស ជូនអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន ក្រោមប្រធានបទ "សារអប់រំសម្រាប់ស្ត្រី និងក្មេងស្រីដើម្បីការពារខ្លួនពី អំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងការរំលោភបំពានថ្មីគ្រប់ទម្រង់" នាឱកាសអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៤ ឆ្នាំ២០២៥។<br>-ចូលរួមកម្មវិធីសន្ទនាមតិ«គំនិតយើង សង្គមយើង» នៅវិទ្យុជាតិ លើប្រធានបទ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង បានផ្តល់បទសម្ភាសជូនអង្គការ Terre des Hommes Netherland ពាក់ព័ន្ធយន្តការបង្ការ ទប់ស្កាត់អំពើ | ០៦ |

| | | | |
|---|---|---|---|
| | | ជួញដូរមនុស្ស ជាពិសេសការងារប្រយុទ្ធប្រឆាំងការបោកបំពាន និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ | |
| ២ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | -កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា លើប្រធានបទ៖<br>១-នីតិវិធីធ្វើការដោយស្របច្បាប់នៅប្រទេសថៃ និងយន្តការទទួលដោះស្រាយបណ្តឹង<br>២-កិច្ចពិភាក្សាពិសេស ស្តីពីការឆ្ពោះទៅពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២៥<br>៣-កិច្ចសម្ភាសន៍ពិសេស ស្តីពី វេទិកាការងារតាមបណ្តា ២៥រាជធានី-ខេត្ត<br>៤-បណ្តឹងអនាមិកសម្រាប់កែលម្អការផ្តល់សេវារបស់ ប.ស.ស. និងមូលដ្ឋានសុខាភិបាលដៃគូ ប.ស.ស<br>៥-នីតិវិធីទៅធ្វើការស្របច្បាប់នៅប្រទេសថៃ<br>៦-យន្តការនៃការពង្រឹងសមត្ថភាពគ្រូបច្ចេកទេសដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាស គ្រឹះស្ថានក្រុមហ៊ុន<br>៧-កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកូនមានអាយុដល់ ២ឆ្នាំ<br>៨-អត្ថប្រយោជន៍នៃការបណ្តុះបណ្តាលសុវត្ថិភាពនិងសុខភាពការងារដល់កម្មករនិយោជិតនៅកន្លែងធ្វើការ<br>៩-បង្កើនភាពជាដៃគូជាមួយផ្នែកឯកជន ដើម្បីបញ្ជូនសិស្សចុះហាត់ការ កម្មសិក្សាទស្សនកិច្ច និងឱកាសការងារ<br>១០-កិច្ចសហការជ្រើសរើសបុគ្គលិករវាងក្រុមហ៊ុន ស្មាតអាស្យាតា និង NEA<br>១១-ភាពតានតឹងដោយកម្តៅនៅកន្លែងធ្វើការ<br>១២-ជំនាញទន់បានផ្តល់ឱ្យអ្នកបច្ចេកទេស និងជំនាញវិជ្ជាជីវៈកាន់តែមានទីផ្សារខ្ពស់<br>១៣-វឌ្ឍនភាព នៃការអនុវត្តកម្មវិធីផ្តល់ជំនាញបច្ចេកទេសដល់យុវជនចំនួន ១លាន ៥សែននាក់<br>១៥-ឱកាសការងារ និងបណ្តុះបណ្តាលជំនាញបច្ចេកទេសជូនពលករនៅក្រៅប្រទេសដែលមានបំណងវិលត្រឡប់មករកការងារនៅស្រុកកំណើតវិញ<br>១៦-វឌ្ឍនភាពនៃការផ្តល់ជូន និងប្រើប្រាស់ប័ណ្ណ ប.ស.ស. នៅកម្ពុជា<br>១៧-វិធានការកាត់បន្ថយភាពតានតឹងផ្លូវចិត្តនៅកន្លែងធ្វើការ<br>១៨-វឌ្ឍនភាពនៃការវិលត្រឡប់ និងឱកាសការងារសម្រាប់ពលករវិលមកពីប្រទេសថៃ<br>១៩-អត្ថប្រយោជន៍ និងភាពរឹងមាំនៃវិស័យរោងចក្រ សហគ្រាសនៅកម្ពុជា<br>២០-ការលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យកសិកម្ម<br>២១-ឆ្ពោះទៅពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២៥<br>២២-វឌ្ឍនភាពយុទ្ធនាការពិព័រណ៍ការងារសន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អតីតពលករមកពីក្រៅប្រទេស<br>២៣-ចង្វាក់ផលិតកម្ម និងទំនើបកម្ម នៅរោងចក្រ ម៉ារ៉ៃល ហ្គាមិន<br>២៤-ខេត្តកំពង់ស្ពឺ ប្រែក្លាយពីតំបន់សមរភូមិ មកជាកន្លែងស្រូបទាញកម្លាំងពលកម្មរាប់ម៉ឺននាក់<br>២៥-ចង្វាក់ផលិតកម្ម សេវាកម្ម និងទំនើបកម្ម ក្នុងវិស័យរោងចក្រសហគ្រាសនៅកម្ពុជា<br>២៦-ជីវិតថ្មីលើដីកំណើតរបស់អតីតពលករមកពីប្រទេសថៃ<br>២៧-ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញកាត់ដេរជូនបងប្អូនអតីតពលករត្រឡប់មកពីថៃ។<br>-ស្ថានីយវិទ្យុABC លើប្រធានបទ នីតិវិធីធ្វើការនៅបរទេសដោយស្របច្បាប់។<br>-ស្ថានីយទូរទស្សន៍ BTV កម្មវិធី "អាជីពខ្ញុំ" លើប្រធានបទ៖<br>១-កំណើនតម្រូវការកម្លាំងពលកម្មគិតត្រឹមពាក់កណ្តាលឆ្នាំ ២០២៥<br>២-ការត្រៀមរៀបចំពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២៥<br>៣-កម្មវិធីពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២៥ | ៣៦ |

| | | | |
|---|---|---|---|
| | | ៤-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងរៀបចំពិព័រណ៍ការងារនៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដើម្បីជួយស្វែងរកការងារដល់ពលករខ្មែរត្រឡប់ចូលប្រទេសវិញ។<br>-ស្ថានីយទូរទស្សន៍ Fresh News កិច្ចសម្ភាសន៍ពិសេស៖ ពិព័រណ៍ការងារជាតិឆ្នាំ២០២៥ មិនត្រឹមតែជាឱកាសស្វែងរកការងារទេ ប៉ុន្តែជាទីបណ្តុះកម្លាំងចិត្ត និងជំនាញសម្រាប់អនាគតយុវជនកម្ពុជា។<br>-ស្ថានីយទូរទស្សន៍ PNN កម្មវិធី ព័ត៌មានព្រឹកនេះ លើប្រធានបទ "ការរៀបចំពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២៥<br>-វិទ្យុជាតិកម្ពុជា AM918KHz និងវិទ្យុវត្តភ្នំ FM 105.70MHz លើប្រធានបទ ស្តីពី TVET បង្កើតឱកាសការងារ និងសាងក្តីសង្ឃឹមដល់យុវជន<br>-AMF economy ក្រោមកិច្ចសហការ SDC ជាមួយ MFE លើប្រធានបទ ស្តីពីជំនាញខ្ពស់ ចំណូលខ្ពស់ | |
| ៣ | ខេត្តសៀមរាប | • ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួមជា វាគ្មិនចែករំលែកទស្សនទានក្នុង ប្រធានបទ «ការដាក់ចេញនូវវិធានការក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនិង ក្មេងស្រី» នៅក្នុងវេទិកាជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច បានចំនួន១ លើក នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ រាជធានីភ្នំពេញ។<br>• មន្ទីរអប់រំយុវជន និងកីឡាខេត្ត មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត វិទ្យាស្ថានពហុបច្ចេកទេសតេជោសែន សៀមរាប បានចូលរួមជាគណៈកម្មការវាយតម្លៃផ្នែកខ្លឹមសារ ក្នុងកម្មវិធីជជែកដេញដោលយុវជនថ្នាក់ខេត្តឆ្នាំ២០២៥ វគ្គផ្តាច់ព្រ័ត្រ លើប្រធានបទ "ការផ្តល់អាទិភាពសំខាន់ដល់ជំនាញស្តែម (STEM) មានផលប៉ះពាល់ដល់តម្លៃវប្បធម៌ជាតិ" ដែលមានបេក្ខភាពក្រុមស្របសិស្សានុសិស្សមកពីវិទ្យាល័យអង្គរជុំ ស្រុកអង្គរជុំ និងបេក្ខភាពក្រុមបដិសេធ សិស្សានុសិស្សមកពីវិទ្យាល័យដំដែក ស្រុកសូទ្រនិគម។<br>• មន្ទីរកិច្ចការនារី មន្ទីរអភិវឌ្ឍន៍ជនបទ រដ្ឋបាលស្រុកពួក អង្គរជុំ និងរដ្ឋបាលស្រុកក្រឡាញ់ ស្តីពី ការស្វែងយល់ពីអាពាហ៍ពិពាហ៍ក្នុងសង្គមខ្មែរ- ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី ដើម្បីទាំងអស់គ្នា - ការផ្តល់កម្ចីឥណទានសម្រាប់បង្កើនមុខរបរដល់ពលករចំណូលស្រុក - ការគាំទ្រស្ត្រីឱ្យមានការងារក្រោយវិលមកពីក្រៅប្រទេស និងការជួយសម្របសម្រួលដល់ជនភៀសសឹកនៅក្នុងស្រុក<br>• មជ្ឈមណ្ឌលយុវជនជាតិកម្ពុជាខេត្តសៀមរាប ១. បានចូលរួមជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាលគំនិតអាជីវកម្មបែបឌីជីថល នៃកម្មវិធីយុវជន២១ (Youth 21) ឆ្នាំ២០២៥ ដែលរៀបចំដោយនាយកដ្ឋានអប់រំយុវជន និងកុមារ នៃអគ្គនាយកដ្ឋានយុវជន ក្រសួងអប់រំ យុវជន និងកីឡា នៅមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា។<br>• ក្រុមការងារលេខាធិការដ្ឋាន និងមន្ទីរ អង្គភាពពាក់ព័ន្ធ បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ១០៣MHz ចំនួន ស្តីពី៖<br><br>-វិធានការ បង្ក្រាបបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព<br>-ការពារខ្លួនពីការឆបោកតាមប្រព័ន្ធអនឡាញ<br>-ការផ្សព្វផ្សាយពី អំពើកេងប្រវ័ញ្ច និងការជួញដូរមនុស្ស<br>-ការពង្រឹងការផ្សព្វផ្សាយច្បាប់ និងវិធានការបង្ក្រាបបទល្មើសរំលោភសេពសន្ថវៈ ក្នុងខេត្តសៀមរាប។<br>-ការអនុវត្តគោលនយោបាយ និងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពក្នុងឆ្នាំ២០២៤ និងទិសដៅបន្តឆ្នាំ២០២៥ | ២២ |

| | | | |
|---|---|---|---|
| | | -ការជំរុញឱ្យអាណាព្យាបាលបញ្ជូនកូនចុះឈ្មោះចូលរៀន<br>-វិធានការទប់ស្កាត់ការជក់បារីគ្រប់ប្រភេទនៅតាមសាលារៀន<br>-ការជំរុញ និងលើកទឹកចិត្តដល់កុមារមានពិការភាពទទួលបានការអប់រំ<br>-ការលើកទឹកចិត្តដល់ពលករ ដែលទើបវិលត្រឡប់មកពីប្រទេសថៃ<br>-ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងចិញ្ចឹមសត្វ និងដាំបន្លែដល់ពលករដែលវិលត្រឡប់មកពីក្រៅប្រទេស<br>-គាំទ្រផលិតផលក្នុងស្រុកជួយបង្កើនសេដ្ឋកិច្ចកសិករក្នុងខេត្តសៀមរាប។<br>-ការបណ្តុះ បណ្តាលជំនាញ ដល់យុវជនមកពីគ្រួសារក្រីក្រ និងរងហានិភ័យ<br>- ការជ្រើសរើសជំនាញសិក្សារបស់សិស្ស ក្រោយការប្រឡងមធ្យមសិក្សាទុតិយភូមិ។<br>-ការ ត្រៀមស្វែងរកការងារ ដល់ពលករវិលត្រឡប់មកពីប្រទេសថៃ<br>-ការផ្តល់ឱកាសការងារក្នុងស្រុក ដើម្បីកាត់បន្ថយហានិភ័យចំពោះការចំណាកស្រុកនៅក្រៅប្រទេសអំឡុងពេលមានបញ្ហាព្រំដែន<br>-ការផ្សព្វផ្សាយពី ប្រធានបទការផ្តល់ឱកាសការងារសម្រាប់ស្ត្រីដែលត្រឡប់មកពីក្រៅប្រទេសបានចំនួន ១លើក<br>-អង្គការមូលនិធិអេ២១ បានចូលរួមជាវាគ្មិន ក្នុងកម្មវិធី "យើងធ្វើបាន" របស់វិទ្យុជាតិនគរភ្នំ១០៣MHz ស្តីពី បច្ចេកវិទ្យា និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងក្មេងស្រី។<br>-អង្គការមជ្ឈមណ្ឌលធនធានស្ត្រី បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីយើងធ្វើបាន របស់វិទ្យុFM ជាតិនគរភ្នំ១០៣MHz ស្តីពី រួមគ្នាទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ១លើក។ | |
| ៤ | ខេត្តកំពង់ចាម | • ក្រុមការងារជំនាញនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត និងមន្ទីរ អង្គភាពពាក់ព័ន្ធ បាន៖<br><br>- **មន្ទីរព័ត៌មានខេត្ត** ៖បានផ្សព្វផ្សាយតាមរយៈវិទ្យុក្នុងកម្មវិធីសន្ទនាមតិចំនួន១១លើក ក្រោមប្រធានបទ ៖<br>១-ដំណើរការអនុវត្តគោលនយោបាយភូមិឃុំសង្កាត់មានសុវត្ថិភាព<br>២-ទប់ស្កាត់អំពើជួញដូរមនុស្ស បង្ការ និងទប់ស្កាត់ពលកម្មកុមារខុសច្បាប់<br>៣-ការចំណាកស្រុកដោយស្របច្បាប់។<br>៤-ផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម និងចាក់ស្ប៉ត អប់រំខ្លីៗស្តីពីចំណាកស្រុកដោយសុវត្ថិភាព ៥ ដងក្នុងមួយថ្ងៃ ។<br>៥-ផលិតព័ត៌មានទាក់ទងនឹងការងារប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយបាន ២០អត្ថបទ រូបភាព ព្រមទាំងចុះផ្សព្វផ្សាយផ្ទាល់តាមបណ្តាសាលារៀន សហគមន៍ នៅតាមក្រុង ស្រុក ទាំង១០ រយៈពេល១ខែ បានចំនួន២១លើក។<br>-**ស្នងការនគរបាលខេត្ត**បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ របស់វិទ្យុជាតិ ខេត្តកំពង់ចាម ចំនួន០៣លើក ក្រោមប្រធានបទ៖<br>១-ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ<br>២-ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋការពារនូវអំពើជួញដូរមនុស្ស<br>៣-ការផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋអំពីការចំណាកស្រុកដោយសុវត្ថិភាព<br>-**មន្ទីរការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមជាវាគ្មិនចំនួន ០៣លើក ក្រោមប្រធានបទ៖<br>១-ដំណើរការ ទទួលនិងត្រៀមកន្លែងការងារសម្រាប់ពលករមកពីប្រទេសថៃ។<br>២-ផលប៉ះពាល់លើកុមារដោយសារការចំណាកស្រុករបស់គ្រួសារ<br>៣-ចំណាកស្រុកដោយសុវត្ថិភាព<br>-**មន្ទីរកិច្ចការនារីបានចូលរួមជាវាគ្មិន**ចំនួន ០៣លើក ក្រោមប្រធានបទ៖<br>១-ការបណ្តុះបណ្តាលជំនាញដល់ស្ត្រីនៅតាមមូលដ្ឋាន ដើម្បីបង្កើនជីវភាពគ្រួសារ | ២២ |

| | | | |
|---|---|---|---|
| | | ២-ការចូលរួមការកាត់បន្ថយអត្រាមរណៈភាពមាតា និងទារក<br>៣- តួនាទីស្ត្រីក្នុងសង្គម<br>-**មន្ទីរអប់រំ យុវជន និងកីឡា បានចូលរួមជាវាគ្មិន**ចំនួន ០២លើក ក្រោមប្រធានបទ៖<br>១-បានផ្សព្វផ្សាយសេចក្តីជូនដំណឹង របស់គណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធ បច្ចេកវិទ្យា ស្តីពីការអនុវត្តនិយាមបត្តិក្នុងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (scams online)។ | |
| ៥ | ខេត្តបាត់ដំបង | -តំណាងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ វាគ្មិនកិត្តិយសក្នុងវេទិកាសាធារណៈ ស្តីពីហិង្សាផ្លូវភេទ អំពើជួញដូរមនុស្ស និងសុវត្ថិភាពពីការធ្វើចំណាកស្រុក ២លើក<br>-ជាវាគ្មិន នៅស្ថានីយវិទ្យុជាតិកម្ពុជា ស្តីពីការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ និងការផ្តល់ជំនាញវិជ្ជាជីវៈដល់យុវជន ក្នុងឱកាសស្វែងរកការងារ ១លើក | ០៥ |
| ៦ | ខេត្តបន្ទាយមានជ័យ | -លោក ចាន់ សុភាព អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានអញ្ជើញចូលរួមធ្វើបទបង្ហាញក្នុងកម្មវិធីអប់រំ និងផ្សព្វផ្សាយស្តីពី "ការទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ " នៅក្នុងបរិវេណវិទ្យាល័យស្វាយចេក ស្រុកភ្នំស្រុក ផ្សារគំរូថ្មីថ្មពួក ស្រុកថ្មពួក ។<br>-ប្រធានមន្ទីរ បានចូលរួមធ្វើបទបង្ហាញ ស្តីពីការសង្គ្រោះផ្តល់កិច្ចគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅថ្នាក់ក្រោមជាតិ ក្នុងអង្គសន្និបាតប្រចាំឆ្នាំ ២០២៤ និងទិសដៅអនុវត្តបន្ត របស់ក្រសួងស.អ.យ។ | ០៤ |
| ៧ | ខេត្តកំពង់ឆ្នាំង | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមវេទិកាផ្សព្វផ្សាយ និងបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារ ចំនួន ២០លើក (ក្នុងស្រុកចំនួន ៥ និងក្រុង ១) មានអ្នកចូលរួមសរុប ៤ ៣១០នាក់ (ស្រី ២ ២២៨នាក់)។ | |

## ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ក.៣.១. ការធ្វើអធិការកិច្ចការងារ

▪ **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានចុះធ្វើអធិការកិច្ចការងារសរុបចំនួន **១៣,៥០០**លើក ក្នុងនោះរាជធានីភ្នំពេញ **៦,៤០៥**លើក និងតាមបណ្តាខេត្ត **៧,០៩៥**លើក និងបានចាត់វិធានការអធិការកិច្ច ដោយបានដាក់កំហិត **១,០៨៣**សហគ្រាស និងបានចេញលិខិតផាកពិន័យ **១០១**សហគ្រាស។

▪ **ក្រសួងទេសចរណ៍៖** បានចុះធ្វើអធិការកិច្ចលើមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ចំនួន **១៤**ខេត្ត រួមមាន៖ ខេត្តព្រះសីហនុ កោះកុង កំពត កែប កំពង់ស្ពឺ កំពង់ឆ្នាំង ស្ទឹងត្រែង ក្រចេះ ព្រៃវែង ស្វាយរៀង មណ្ឌលគិរី រតនគិរី សៀមរាប និងបាត់ដំបង ដើម្បីពិនិត្យ និងបង្ការទប់ស្កាត់ការជួញដូរមនុស្ស លើមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍សរុបចំនួន **១៤៦**ទីតាំង។

### ក.៣.២. ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកដែលគ្មានឯកសារស្របច្បាប់តាមបន្ទាត់ព្រំដែនកម្ពុជា ថៃ ចំនួន **៣៤**លើក មនុស្សចំនួន **២៩០**នាក់ ស្រី **១៣៦**នាក់ អនីតិជន **១៣**នាក់ ដោយបានធ្វើកិច្ចសន្យាអប់រំណែនាំ និងឱ្យត្រឡប់ទៅភូមិកំណើតវិញ។

### ក.៣.៣.ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

▪ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសជនបរទេស ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ នៅ

ក្រសួងមហាផ្ទៃ ចំនួន **២.១១៨**នាក់(ស្រី**៩៤**នាក់) មាន**៤១**សញ្ជាតិ ក្នុងនោះមាន៖ កូរ៉េខាងត្បូង៤១៣នាក់(ស្រី៤១), អាម៉េរិក២១០នាក់(ស្រី២៧), ចិន១,២៦៧នាក់(ស្រី០១), អូស្ត្រាលី៣២នាក់(ស្រី០៧), កាណាដា២៤នាក់(ស្រី០២), បារាំង៤៩នាក់(ស្រី០២), សឹង្ហបុរី០១នាក់, ជប៉ុន១១នាក់(ស្រី០១), ស៊ុយអែត០១នាក់, អាឡឺម៉ង់០៧នាក់, ថៃ០១នាក់ស្រី, ម៉ាឡេស៊ី២៨នាក់(ស្រី០១), ឆេក០២នាក់, វៀតណាម១៦នាក់(ស្រី០៣), ឥណ្ឌា០១នាក់, អង់គ្លេស០៤នាក់(ស្រី០២), ណូវែលសេឡង់០៣នាក់, ប៊ែលហ្សិក០១នាក់, ទួគី០២នាក់, ឥណ្ឌូណេស៊ី០៩នាក់, ក្រូអាត០១នាក់, បង់ក្លាដេស០១នាក់, ស៊ែប៊ី០១នាក់, អ៊ីស្រាអែល០១នាក់, ហុងគ្រី០១នាក់, ប៉ូឡូញ០១នាក់, នីហ្សេរីយ៉ា០១នាក់, ហ្វីលីពីន០១នាក់, ហូឡង់០៤នាក់(ស្រី០១), ស្វីស០៤នាក់, ប៉ាគីស្ថាន០២នាក់, ឡាវ០៦នាក់(ស្រី០៤), នេប៉ាល់០២នាក់, ម៉ល់ន៍០១នាក់, ស្រីលង្កា០២នាក់, រុស្ស៊ី០២នាក់(ស្រី០១), អាហ្វ្រិកខាងត្បូង០១នាក់, ហ្វាំងឡង់០២នាក់, អៀរឡង់០១នាក់, អូទ្រីស០១នាក់ ***និងវាយតម្លៃបញ្ជូនឱ្យក្រុមការងារប្រេកចេញចូលតែមួយបានចំនួន ២.០៦១នាក់ ស្រី១១១នាក់។***

### ក.៣.៤.ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

➢ **ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ**

▪ **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត** បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងត្រឡប់ពីក្រៅប្រទេសវិញ ទូទាំងរាជធានី-ខេត្តទាំង២៥ ៖

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មករា | ២០៩.៣៤៩ នាក់ | ៩៣.៣៣៨ នាក់ | ៦.០៤២ នាក់ | ២.០១៥ នាក់ |
| កុម្ភៈ | ១៤១.៥០៨ នាក់ | ៦២.៦២៦ នាក់ | ៤.១៣១ នាក់ | ១.៣៣៧ នាក់ |
| មីនា | ១៤១.៧២៤ នាក់ | ៦៤.១៩៣ នាក់ | ៤.៥៦៦ នាក់ | ១.៤៣២ នាក់ |
| មេសា | ១៤១.៧២៤ នាក់ | ៦៤.១៩៣ នាក់ | ៤.៥៦៦ នាក់ | ១.៤៣២ នាក់ |
| ឧសភា | ១៤១.៩៩៣ នាក់ | ៦៣.៧៣៧ នាក់ | ៤.១៣៧ នាក់ | ១.៣០៣ នាក់ |
| មិថុនា | ១៣៨.០៣៧ នាក់ | ៦២.៤២៥ នាក់ | ៤.៧៣៨ នាក់ | ១.៤៨៥ នាក់ |
| កក្កដា | ១២៩.៧២២ នាក់ | ៥៨.០៥៦ នាក់ | ៥.១១៦ នាក់ | ១.៦២៥ នាក់ |
| សីហា | ១១៧.៧៤៩ នាក់ | ៥១.០៦៨ នាក់ | ៤.៩២៧ នាក់ | ១.៥២៧ នាក់ |
| កញ្ញា | ១០៥.១៤៩ នាក់ | ៤៦.០០៨ នាក់ | ៣.៩០៩ នាក់ | ១.១៨៦ នាក់ |
| តុលា | ៩៦.១៧៣ នាក់ | ៤២.២១៧ នាក់ | ៣.៨១០ នាក់ | ១.១៥៣ នាក់ |
| វិច្ឆិកា | ៥៦.២៦៩ នាក់ | ២៣.៧០៨ នាក់ | ៤២៥ នាក់ | ៨៧ នាក់ |
| ធ្នូ | ៤៩.៤៩៣ នាក់ | ២០.១៦៤ នាក់ | ២៩០ នាក់ | ៩៤ នាក់ |

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មករា | ១៣.៨២៣ នាក់ | ៥.៥៦៩ នាក់ | ២១៦ នាក់ | ៨៥ នាក់ |
| កុម្ភៈ | ១៤.៦២៩ នាក់ | ៦.០០៨ នាក់ | ១៨៦ នាក់ | ៧៥ នាក់ |

| | | | | |
|---|---|---|---|---|
| មីនា | ១៤.៧៤៣ នាក់ | ៦.១១៤ នាក់ | ២១៧ នាក់ | ៨៣ នាក់ |
| មេសា | ១៤.៧៤៣ នាក់ | ៦.១១៤ នាក់ | ២១៧ នាក់ | ៨៣ នាក់ |
| ឧសភា | ២០.៣០៩ នាក់ | ៨.៨០៣ នាក់ | ១៩២ នាក់ | ១០៥ នាក់ |
| មិថុនា | ១៧.៨៨២ នាក់ | ៧.៦៤២ នាក់ | ២២៨ នាក់ | ៨៦ នាក់ |
| កក្កដា | ១៤.៦៨៤ នាក់ | ៦.០១៩ នាក់ | ២១២ នាក់ | ៧៩ នាក់ |
| សីហា | ២៧.២៨០ នាក់ | ១២.៧២៦ នាក់ | ៦៧៧ នាក់ | ២១៥ នាក់ |
| កញ្ញា | ១១៣.២៤៨ នាក់ | ៥០.៧៣៥ នាក់ | ៣.០៤៧ នាក់ | ៧៤១ នាក់ |
| តុលា | ៨០.៧២៤ នាក់ | ៤២.១៩៨ នាក់ | ១.៦២៣ នាក់ | ៦៣២ នាក់ |
| វិច្ឆិកា | ៥១.៩៣៧ នាក់ | ២៣.៣៦៥ នាក់ | ៨៧៧ នាក់ | ៣៤៤ នាក់ |
| ធ្នូ | ២១.៥៦៤ នាក់ | ៩.០០៧ នាក់ | ៣៥៩ នាក់ | ១៣៨ នាក់ |

▪ **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ៖** បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេស ដែលបានវិលត្រឡប់មកពីក្រៅប្រទេសវិញ ខេត្តទាំង២៤៖

| ល.រ | រាជធានី ខេត្ត | ចំនួនពលករវិលត្រឡប់ពីក្រៅប្រទេស មករា-មិថុនា | | | | ចំនួនពលករវិលត្រឡប់ពីក្រៅប្រទេស កក្កដា-ធ្នូ | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនពលករ | | អនីតិជន | | ចំនួនពលករ | | អនីតិជន | |
| | | សរុប | ស្រី | ប្រុស | ស្រី | សរុប | ស្រី | ប្រុស | ស្រី |
| ១ | រាជធានីភ្នំពេញ | | | | | ២.៥០០ | ១.៣៨១ | | |
| ២ | កណ្ដាល | | | | | ៤.៧៨៧ | ១.៣៥០ | ៤០២ | ២១៥ |
| ៣ | ព្រៃវែង | ៩១៣ | ២៨៩ | ០៣ | | ២៣.៥៦៧ | ៦.៩៥០ | ១៤៥ | ៧០ |
| ៤ | ស្វាយរៀង | ៤.០៤៧ | ១.៦៥០ | | | ៤.២៩៤ | ២.៤០១ | | |
| ៥ | កំពត | | | | | ៦៣១.៨០០ | ២៩៤.១០០ | | |
| ៦ | តាកែវ | | | | | ២៣.៨២៨ | ១១.៦១៧ | ១៦១ | ៨២ |
| ៧ | កែប | | | | | ១៤១ | ៧១ | | |
| ៨ | កោះកុង | | | | | ២៩៣ | ១៥៨ | ៤០ | ៣៧ |
| ៩ | ព្រះសីហនុ | ៩៣ | ៤៨ | | | ១.៤៣៣ | ៧៤១ | | |
| ១០ | ក្រចេះ | | | | | ២.០៥០ | ៨៨៨ | ៨៧ | ៣៥ |
| ១១ | កំពង់ចាម | | | | | ១៥.៥០៥ | ៧.២០៦ | | |
| ១២ | ត្បូងឃ្មុំ | ១.០៦៦ | ៦១៥ | ៦៣ | ៤០ | ៥.៥៧២ | ៣.២៣១ | ៤៣៤ | ២៤៤ |
| ១៣ | ស្ទឹងត្រែង | | | | | ៣២៨ | ១៣៣ | | |
| ១៤ | ឧត្តរមានជ័យ | ១០៧.១៣៦ | ៥៣.៧៦២ | ១០៩ | ០៨ | ១១.១៦៤ | ៥.២៦៤ | | |
| ១៥ | បន្ទាយមានជ័យ | ៣.៧០៤ | ១.៨៤៤ | | | ៦៨.៤១១ | ៣១.៦៩៧ | ១៧ | ០៥ |
| ១៦ | ប៉ៃលិន | ៤៥.១១៣ | ៤៦.១០១ | | | ៥.០៩២ | ៤.២៤៤ | | |
| ១៧ | បាត់ដំបង | ១.១២៧ | ៥០៩ | ០៥ | | ៦៥.២៥១ | ៣៨.៤៣៧ | ១.៦៩៩ | |
| ១៨ | ពោធិ៍សាត់ | | | | | ១៣.១៦១ | ៦.០៣៧ | ៥៦ | ២៦ |
| ១៩ | កំពង់ឆ្នាំង | ១.០៥៤ | ១១៧ | | | ៣.៥៤៨ | ១.៥១២ | | |
| ២០ | ព្រះវិហារ | | | | | ១.២៤០ | ៥៣៤ | | |
| ២១ | សៀមរាប | ៨.៥៣៦ | ៤.១៣៧ | ១៦៥ | ៨៥ | ៤៤.២៣៧ | ១៨.១០៣ | ៩៧៣ | ៧៧៧ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២២ | កំពង់ធំ | ១៣.៨២៥ | ៦.១៣៦ | | | ១៣.៨៣០ | ៦.១៣៨ | | |
| ២៣ | មណ្ឌលគិរី | ២៩ | ១៦ | ០៧ | ០៥ | ១៥២ | ៦០ | ២៣ | ១០ |
| ២៤ | រតនៈគិរី | | | | | ៥៤០ | ២៣៧ | ២៥ | |
| ២៥ | កំពង់ស្ពឺ | ៤៣០ | ២០១ | | | ២.៩២៥ | ១.៣៤២ | | |
| | **សរុបរួម** | ១៨៧.០៧៣ | ១១៥.៤២៥ | ៣៥២ | ១៣៨ | ៩៤៥.៦៤៩ | ៤៤៣.៨៣២ | ៤.០៦២ | ១.៥០១ |

➢ **ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន**

▪ **ខេត្តបាត់ដំបង៖** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ នៃស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយសមត្ថកិច្ចថៃ ទទួលប្រជាពលរដ្ឋខ្មែរ គ្មានលិខិតឆ្លងដែនត្រឡប់មកវិញចំនួន **៤១** លើក មានពលករចំនួន ៨៤៨នាក់ ស្រី **៤១៧**នាក់ អនីតិជន **៧៧**នាក់។

▪ **ខេត្តកោះកុង៖** ក្រុមការងារលេខាធិការដ្ឋានប្រចាំ ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករដែលភាគីថៃចាប់បញ្ជូនមកមិនស្របច្បាប់ ចំនួន **៦៥**លើក មនុស្ស **១៥១**នាក់ ស្រី **២៤**នាក់។

▪ **ខេត្តស្វាយរៀង៖** ក្រុមការងារជំនាញនៃ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលប្រជាពលរដ្ឋខ្មែររស់នៅតាមទីសាធារណៈនៅប្រទេសវៀតណាម និងប្រជាពលរដ្ឋដែលត្រូវចាញ់បោកមេខ្យល់ឆ្លងដែនទៅប្រទេសចិន ត្រូវបានអាជ្ញាធរវៀតណាមចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញចំនួន **១៨**លើក មានចំនួន **៦១គ្រួសារ** មនុស្សរួម **៩៦**នាក់ ស្រី **៦៨**នាក់ កុមារ **៣៩**នាក់ កុមារី **២០**នាក់។

➢ **ការទទួលពលករខ្មែរនៅតាមមណ្ឌលទទួលពលករ**

▪ **មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត** បានទទួលពលករខ្មែរចំណាកស្រុក ដែលត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញតាមច្រកអន្តរជាតិប៉ោយប៉ែត សរុបចំនួន ៧.៩៩០នាក់ (ប្រុស **៤.៣៦៩**នាក់ ស្រី **២.៦៧៦**នាក់ កុមារា ៤៧៦នាក់ កុមារី ៤៦៩នាក់)។

▪ **មណ្ឌលទទួលពលករកំរៀង៖** បានទទួលពលករសរុបចំនួន **៣.៤៦៩**នាក់ (ស្រី**១.២០៥**នាក់) ដោយក្នុងនោះស្ត្រីមានកូនតូចមកជាមួយមានចំនួន **២០៥**នាក់ និងស្ត្រីមានផ្ទៃពោះមានចំនួន **៣៥**នាក់ (អនីតិជនចំនួន **១៩៥**នាក់ ស្ត្រី ៨៩នាក់) និងជនមានពិការភាពចំនួន **១៤**នាក់(ស្ត្រី០២នាក់)។ ***បានកំណត់អត្តសញ្ញាណបឋមជាបុគ្គលសង្ស័យថារងគ្រោះចំនួន ៧២នាក់ (ស្រី ១៤នាក់)*** ។

➢ **ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពជនបរទេសចំណូលស្រុក និងចូលមកធ្វើការនៅកម្ពុជា**

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖**

+ <u>ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាស្របច្បាប់</u> **៖ ការផ្តល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍**

បានផ្តល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍ឱ្យជនបរទេសអន្តោប្រវេសន្ត ចំនួន **២១.០៧០**ប័ណ្ណ ក្នុងនោះ ស្នើសុំលើកដំបូង ចំនួន ៨៩៦ប័ណ្ណ និងបានបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍០២ឆ្នាំម្តង លើកទី១ ចំនួន ១.៦១៣ប័ណ្ណ លើកទី២ ចំនួន ១២.៥៩៣ប័ណ្ណ លើកទី៣ ចំនួន ៤.២៦៣ប័ណ្ណ លើកទី៤ ចំនួន ១.៦៨៥ប័ណ្ណ និងលើកទី៥ ចំនួន ១៩ប័ណ្ណ និងទុតិយតា ០១ប័ណ្ណ។

+ <u>ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាដោយមិនស្របច្បាប់ និងបង្រ្កាបបទល្មើស</u>

មន្ត្រីនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិ រកឃើញ និងបង្រ្កាបបទល្មើសអន្តោប្រវេសន៍ និងបទល្មើសព្រហ្មទណ្ឌ សរុបចំនួន **៤.០២២**លើក មានជនល្មើសចំនួន **៧.៥៧៣**នាក់ ក្នុងនោះ៖

**១-បទល្មើសអន្តោប្រវេសន៍ សរុបចំនួន ៣.៧១៨លើក មនុស្សចំនួន ៦.២៧៣នាក់ ៖**

- លួចឆ្លងដែនដោយខុសច្បាប់ ចំនួន **៤២៤**លើក មនុស្ស **៩៨៧**នាក់ មាន ៣០សញ្ជាតិ

- ស្នាក់នៅ និងធ្វើការខុសច្បាប់ ចំនួន ៣៧៨លើក មនុស្ស ២.៣៧៤នាក់ មាន ៣៨សញ្ជាតិ
- ស្នាក់នៅលើសទិដ្ឋាការ ចំនួន២.៩១២លើក មនុស្ស ២.៩១២នាក់ មាន ៦១សញ្ជាតិ
- រៀបអាពាហ៍ពិពាហ៍ខុសច្បាប់ ចំនួន ០៤លើក មនុស្ស ០៤នាក់ សញ្ជាតិចិន។

**២-បទល្មើសព្រហ្មទណ្ឌ៖ សរុបចំនួន ៣០៤លើក ជនល្មើស ១.៣០០នាក់។**

**ការឃាត់ខ្លួន និងបណ្តេញចេញជនបរទេសល្មើសច្បាប់**

បានរៀបចំតាមនីតិវិធីបណ្តេញចេញជនបរទេសល្មើសច្បាប់នានា ពីព្រះរាជាណាចក្រកម្ពុជា ចំនួន ៧៤៥លើក មនុស្ស ចំនួន១០.៣៥៤នាក់ មាន៦០សញ្ជាតិ (ចិន៣.៧៦០នាក់ វៀតណាម២.៧៨០នាក់ ឥណ្ឌូនេស៊ី១.១៥១នាក់ ថៃ៤៣៧នាក់ ឡាវ០៧នាក់ ឥណ្ឌា២៧៩នាក់ បង់ក្លាដេស១២៦នាក់ តៃវ៉ាន់៣២២នាក់ កូរ៉េខាងត្បូង៩២នាក់ ម៉ាឡេស៊ី១៦២នាក់ មីយ៉ាន់ម៉ា១៧៥នាក់ លីប៊ី៧៣នាក់ ប៉ាគីស្ថាន៦០០នាក់ នេប៉ាល់៣២នាក់ នីហ្សេរីយ៉ា២៨នាក់ ហ្វីលីពីន១៧៨នាក់ អង់គ្លេស១២នាក់ អាម៉េរិក០៧នាក់ និងមាន៤១សញ្ជាតិទៀត។

**ការគ្រប់គ្រងទិន្នន័យជនបរទេសដែលចូលមកធ្វើការនៅកម្ពុជា**

គ្រប់គ្រងជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន និងហត្ថពលករបរទេស៖ តាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្រុមហ៊ុនវិនិយោគបរទេសដែលបានចុះបញ្ជីមានចំនួនសរុប ៣.៥៩៧ក្រុមហ៊ុន មាន ៤៥សញ្ជាតិ ក្នុងនោះ វិស័យរោងចក្រ សហគ្រាស ៣.០៤៤ក្រុមហ៊ុន វិស័យកសិកម្ម ២៦២ក្រុមហ៊ុន វិស័យទេសចរណ៍ ១២៨ក្រុមហ៊ុន និងវិស័យហេដ្ឋារចនាសម្ព័ន្ធ ១៦៣ក្រុមហ៊ុន) ដែលបានផ្តល់ការងារដល់ពលករបរទេស-ខ្មែរ សរុប ៣.៨១១.៨៥១កន្លែង។

## គ.៤.ការបញ្ជូន និងទទួលពលករទេសន្តរប្រវេសន៍ដោយស្របច្បាប់

▪ **ក្រុមការងារទេសន្តរប្រវេសន៍ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានបញ្ជូនពលករទេសន្តរប្រវេសន៍ទៅធ្វើការនៅបរទេសដោយស្របច្បាប់ តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុញ្ញាតមុខរបរ EPS (Employment Permit System) បានចំនួន ២៣.៤៣៥នាក់ ស្រី ៨.៩៥៩នាក់ ដូចមានក្នុងតារាងខាងក្រោម៖

**ទិន្នន័យបញ្ជូនពលករទេសន្តរប្រវេសន៍ខ្មែរទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់**

| ល.រ | ប្រទេសគោលដៅ | ចំនួនរួម | ស្រី |
|---|---|---|---|
| ១ | ថៃ | ១០.៨០៣ | ៤.៧៤៥ |
| ២ | ជប៉ុន | ៧.៧២៧ | ២.៧៣៤ |
| ៣ | សាធារណរដ្ឋកូរ៉េ | ៥.៨៨៥ | ១.៤៦០ |
| ៤ | សិង្ហបុរី | ២០ | ២០ |
| | សរុប | ២៣.៤៣៥ នាក់ | ៨.៩៥៩ នាក់ |

## គ.៥. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

❖ **ការផ្សព្វផ្សាយ**

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

- បានរៀបចំពិធីបើកយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិនៅខេត្តសៀមរាប ដោយមានការអញ្ជើញចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានី ខេត្ត ក្រុមការងារលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ សហព័ន្ធសហជីព អង្គការដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន កម្មករ និយោជិតជាអាណាព្យាបាល និងកុមារ និងបានធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម ចំនួន ៤៤៣ទីតាំង

ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន អាណាព្យាបាលដែលជាកម្មករនិយោជិតសរុបចំនួន ១២.០៨២នាក់ (ស្រី ៤.៩២៩នាក់) ដើម្បីផ្លាស់ប្តូរផ្នត់គំនិតពាក់ព័ន្ធនឹងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ការងារដោយបង្ខំ និងជំរុញចលនាសហគមន៍ ឆ្ពោះទៅការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ

-បានផលិតវីឌីអូស្ពតស្តីពី ការប្តេជ្ញាចិត្តចូលរួមបញ្ចប់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារនៅកម្ពុជា វីដេអូស្ពត ស្តីពីសារសម្ភាសន៍ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ និងសារសម្ភាសន៍របស់ឯកឧត្តម លោកជំទាវ នៃក្រសួងស្ថាប័នពាក់ព័ន្ធ សារនាយកអង្គការអន្តរជាតិខាងការងារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និងផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម ផេកផ្លូវការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផេក HENG SOUR រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានអ្នកចូលទស្សនាសរុបចំនួន ១២.៨០០នាក់

- បានផលិតបដាសម្រាប់ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យផលិតឥដ្ឋក្បឿង និងកសិឧស្សាហកម្មសរុបចំនួន ១.២០០ផ្ទាំង ដើម្បីចងនៅគ្រប់សហគ្រាសផលិតឥដ្ឋក្បឿង និងកសិឧស្សាហកម្មទូទាំងប្រទេស

- បានផ្សព្វផ្សាយសារអំពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ តាមរយៈសារអេឡិចត្រូនិចខ្លី (Pushing Message)

- បានរៀបចំពិធីចែកសម្ភារសិក្សា និងមធ្យោបាយធ្វើដំណើរជូនកុមារដែលបានទប់ស្កាត់ពីការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស ផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម តាមរយៈកិច្ចអន្តរាគមន៍ស្នូល ឆ្នាំ២០២៥ ចំនួន៧ខេត្ត រួមមានខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ ដែលមានអ្នកចូលរួមសរុប ១ ៦៤៣នាក់(ស្រី៧៤៧នាក់)

-បានរៀបចំផលិតវីដេអូស្តីពី សកម្មភាពនៃការអនុវត្តកិច្ចអន្តរាគមន៍ស្នូល នៅតាមសហគ្រាស គ្រឹះស្ថានផលិតឥដ្ឋ ក្បឿង ឆ្នាំ២០២៥ ក្នុងខេត្តគោលដៅទាំង៧ រួមមានខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ ដើម្បីឆ្លុះបញ្ចាំងវឌ្ឍនភាព និងដំណោះស្រាយបញ្ហាពលកម្មកុមារ

-បានបណ្តុះបណ្តាលដល់មន្ត្រីអធិការការងារ និងមន្ត្រីមូលដ្ឋានរាជធានីខេត្ត ក្រុង-ស្រុក ឃុំ-សង្កាត់ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថាន ផលិតឥដ្ឋក្បឿង ចំនួនសរុប ៤៨៩នាក់ ស្រី ១០៦នាក់

-អនុវត្តគម្រោងកិច្ចអន្តរាគមន៍ស្នូលក្នុងការទប់ស្កាត់ ការពារ និងបន្តការគាំពារ ដែលជាសេវាឆ្លើយតបជួយកុមារងាយរងគ្រោះ និងធ្លាក់ចូលទៅក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ តាមរយៈការផ្តល់ឱកាសអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងការលើកកម្ពស់ជីវភាពគ្រួសារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម ក្នុងខេត្តគោលដៅ ចំនួន ០៧ រួមមានៈ ខេត្តកណ្តាល ខេត្តត្បូងឃ្មុំ ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តកំពង់ធំ

-បានសហការជាមួយគណៈកម្មការប្រឆាំងពលកម្មកុមាររាជធានី-ខេត្តទាំង២៥ លេខាធិការដ្ឋាន គ.ជ.ប.ព/គ.ខ.ប.ជ មន្ទីរ/អង្គភាពពាក់ព័ន្ធ អជ្ញាធរក្រុង/ស្រុក បានចុះផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម សិប្បកម្មទឹកពិសារដប តាមបណ្តាស្ថានីយ៍/អនុស្ថានីយ៍ និងបានចងបដាផ្សព្វផ្សាយ បានចំនួន **៤៤៣**លើក/កន្លែង មានអ្នកចូលរួម **១២.០៨២**នាក់ ស្រី ៤.៩២៩នាក់។

❖ **ការធ្វើអធិការកិច្ច**

▪ **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះធ្វើអធិការកិច្ចការងារ សរុបចំនួន ១៣.៥០០លើក ក្នុងនោះការចុះអធិការកិច្ចការងារនៅតាមសិប្បកម្មផលិតឥដ្ឋ ក្បឿង ចំនួន ២៩៩លើក ដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងបានធ្វើលិខិតជានាអះអាង ស្តីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារជាមួយនិយោជកចំនួន ៩៦លិខិត និងកិច្ចសន្យារវាងអាណាព្យាបាល និងនិយោជក ស្តីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារចំនួន ៤៦៩កិច្ចសន្យា។

## ក.៦. ការលើកកម្ពស់ជីវភាព

❖ **ការផ្តល់ព័ត៌មានការងារ និងបង្កើតកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ**

▪ **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** **១**-បានផ្តល់ការណែនាំតម្រង់ទិសពលករ មុនចេញដំណើរទៅធ្វើការនៅបរទេសចំនួន ៦៧៥លើក ដែលមានពលករចំនួន ១៨.៤៨៥នាក់(ស្រី ៦.៨៤០នាក់)។ **២**-ប្រមូលនិងផ្សព្វផ្សាយព័ត៌មាន អំពីឱកាសការងារនិងឱកាសកម្មសិក្សាការងារ ពីគ្រប់ប្រភពចំនួន ៨២៣.៦៧៤កន្លែង។ **៣**-បានប្រមូលនិងផ្សព្វផ្សាយអំពីវគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ពីគ្រប់ប្រភពចំនួន ២.៦៩៥វគ្គ។ **៤**-បានរៀបចំពិព័រណ៍ចល័តតាមរយៈមជ្ឈមណ្ឌលការងារដែលមានស្រាប់ និងមជ្ឈមណ្ឌលការងារ ចល័តនៅតាមមូលដ្ឋាន ទីប្រជុំជន និងគ្រឹះស្ថានសិក្សាចំនួន ១.៣៤០ដង អ្នកចូលរួមចំនួន ១៩៤.៨៦៥នាក់ (ស្រី ១០៦.២៩០នាក់)។ **៥**-បានរៀបចំវេទិកាការងារ កម្មសិក្សាការងារ និងកិច្ចសម្ភាសន៍ការងារប្រចាំសប្តាហ៍ចំនួន ៧៧០ដង មានអ្នកចូលរួមចំនួន ១៦៩.១៦៥នាក់ (ស្រី ៨០.៨១៥នាក់)។ **៦**-បានបង្កើតកម្មវិធីតម្រង់ទិសវិជ្ជាជីវៈ នៅតាមសាលាមធ្យមសិក្សាចំណេះដឹងទូទៅចំនួន ៤០០សាលា មានសិស្សសរុបចំនួន ៩១.៥៤៧នាក់ (ស្រី ៥៤.២៥៥នាក់)។ **៧**-បានបង្កើតកម្មវិធីសិស្សានុសិស្សមកទស្សនកិច្ចសិក្សា នៅតាមគ្រឹះស្ថាន អ.ប.វ. ចំនួន ៦៣គ្រឹះស្ថាន មានសិស្សសរុប ៥.៤៨២នាក់ (ស្រី ៣.០៤២នាក់)។ **៨**-បានផ្តល់សេវាប្រឹក្សាយោបល់អាជីព ការងារ និងវិជ្ជាជីវៈ ដល់សិស្ស និស្សិត និងអ្នកស្វែងរកការងារធ្វើចំនួន ៥៤.៩១៩នាក់ (ស្រី ២៧.៥៤៦នាក់)។ **៩**-បានរៀបចំការធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព(Recognition of Prior Learning-RPL) ដើម្បីផ្តល់វិញ្ញាបនបត្របញ្ជាក់កម្រិតសមត្ថភាពដោយឥតគិតថ្លៃលើជំនាញការងារផ្នែកសំណង់ ដល់បងប្អូនកម្មករនិយោជិកជាអតីតពលករខ្មែរ និងអ្នកមានបទពិសោធន៍ការងារ ប៉ុន្តែមិនទាន់មានលិខិតបញ្ជាក់ជំនាញ សម្រាប់យកទៅប្រើប្រាស់ក្នុងការស្វែងរកឱកាសការងារថ្មី និងទទួលបានប្រាក់ចំណូលសមរម្យតាមកម្រិតជំនាញ។ **១០**-គិតត្រឹមឆ្នាំ២០២៥ តាមរយៈកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដល់យុវជន មកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (កម្មវិធី TVET 1.5M) មានសិស្សបញ្ចប់ការសិក្សាចំនួន ៧៩.២៨៥នាក់ (មានប័ណ្ណសមធម៌ ឬប័ណ្ណងាយរងហានិភ័យ ចំនួន ៣៩.១៩៩នាក់) និងកំពុងសិក្សាចំនួន ៧.៤៤៥នាក់ (មានប័ណ្ណសមធម៌ ឬប័ណ្ណងាយរងហានិភ័យ ចំនួន ៣.១៤៤នាក់)។

▪ **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** បានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនតាដល់សិស្សមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ សរុបចំនួន **២៥១**នាក់ (សិស្សចុះឈ្មោះចូលរៀនដំបូង) លើជំនាញចំនួន១៤ ដូចជា ឧកស្មាច់ ចម្លាក់ប្រាក់ស្ពាន់ តម្បាញសូត្រ តម្បាញក្រមាពណ៌ត្រុំ កុលាលភាជន៍ សាជី ឧកម្រ័ក្សណ៍ ដេរប៉ាក់ ចម្លាក់ស្បែក ចម្លាក់ថ្ម តម្បាញកន្ទេលផ្អាវ តម្បាញអំបោះ ចម្លាក់ពុម្ព និងគំនូរបុរាណ។

▪ **ក្រសួងកិច្ចការនារី៖** មជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសហគ្រិនភាពស្ត្រី ក្នុងភាពជាដៃគូជាមួយសមាគមសហគ្រិនស្ត្រីកម្ពុជានិងដៃគូពាក់ព័ន្ធ បានបន្តផ្តល់សេវាគាំទ្រអភិវឌ្ឍអាជីវកម្ម ការពង្រីកឱកាសទីផ្សារនិងចំណេះដឹង ឌីជីថលនិងហិរញ្ញវត្ថុ ជូនស្ត្រីជាសហគ្រិននិងអាជីវករ ចំនួន ៣៩៧រូប។ បន្ថែមលើនេះទៀត គម្រោងមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសហគ្រិនភាពស្ត្រី មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ទាំង១៤ និងមន្ទីរកិច្ចការនារីខេត្ត បានធ្វើពិពិធកម្មមុខងារ និងបានបណ្តុះបណ្តាលដល់ស្ត្រី ចំនួន៣.៨០៨នាក់ លើជំនាញវិជ្ជាជីវៈជូនតា ជំនាញផ្ទុចផ្តើម

និងអភិវឌ្ឍន៍អាជីវកម្ម ចំណេះដឹងឌីជីថល ការអភិវឌ្ឍមុខរបរ និងបានបន្តគាំទ្រដំណើរការក្រុមផលិតសិប្បកម្ម និងក្រុមសន្សំប្រាក់ ចំនួន ៨៨ក្រុម ក្នុងចំនួន៨៣៣គ្រួសារ កំពុងដំណើរការនៅតាមសហគមន៍។

▪ **ខេត្តសៀមរាប៖** បានរៀបចំវេទិកាការងារ ពិព័រណ៍ការងារចល័ត សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីឱកាសការងារ នៅតាមមូលដ្ឋាន បានចំនួន ១០១ដង ដែលមានអ្នកចូលរួមសរុប **២៤.៩៤៣**នាក់ ស្រី **១២.៥១២**នាក់។ បានប្រមូលព័ត៌មានអំពីការជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព បានចំនួន ៤,១០០ កន្លែង។ បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើ សរុបចំនួន **៧.៤៣៧**នាក់ ស្រី **៣.៩៩៥**នាក់ ក្នុងនោះពលករ **៦.០៤៩**នាក់ ស្រី **២.៨៣៩**នាក់។ បានផ្គូរផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជកសរុប **៤.៨២៥**នាក់ ស្រី **២.២៥៣**នាក់ (ពលករ **៣.៩៧០**នាក់ ស្រី **១.៨៧៦**នាក់) ក្នុងនោះអ្នកទទួលបានការងារធ្វើ ចំនួន **២.៣៨០**នាក់ ស្រី **១.៣០៤**នាក់ និងអ្នកទទួលបានកម្មសិក្សា ចំនួន **៦៦**នាក់ ស្រី **៣៣**នាក់។ បានផ្តល់ការប្រឹក្សាយោបល់អំពីអាជីព ការងារ និងវិជ្ជាជីវៈទៅអ្នកស្វែងរកការងារធ្វើ បានចំនួន **១.៩៨៤**នាក់ ស្រី **១.០៩៤**នាក់។ អ្នកទទួលបានព័ត៌មានទីផ្សារការងារតាមរយៈខិត្តប័ណ្ណ/កម្មវិធី **៤៧ ៨៥០** នាក់។

▪ **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយអាជ្ញាធរទីភ្នាក់ងារជាតិមុខរបរ និងការងារ ប.ស.ស និងវិទ្យាស្ថានពហុបច្ចេកទេសខេត្ត ចុះផ្សព្វផ្សាយ និងចុះឈ្មោះពលករខ្មែរ រកការងារធ្វើសរុបចំនួន **២.២៧១**នាក់ ស្រី **១.០១៧**នាក់ ក្នុងនោះអ្នកមានការងារធ្វើ និងប្រកបមុខរបរដោយផ្ទាល់ខ្លួន **១.៥៨៨**នាក់ ស្រី **៧០៧**នាក់ និងមានពលករ **២៨**នាក់ ស្រី **១២**នាក់ ចុះឈ្មោះចូលរៀនជំនាញបច្ចេកទេសវិជ្ជាជីវៈ។

▪ **ខេត្តប៉ៃលិន** បានចុះស្រង់ស្ថិតិតាមសហគ្រាស គ្រឹះស្ថាន ដែលកំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិតក្នុងខេត្ត និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងពលករចំនួន ១២លើក ក្នុងនោះបច្ចុប្បន្នមានសហគ្រាស គ្រឹះស្ថានចំនួន ៥៦ កំពុងមានតម្រូវការកម្មករនិយោជិតសរុប **១.៧០៨**នាក់ ស្រី **៩៤៩**នាក់។

▪ **ខេត្តព្រះសីហនុ៖** បានផ្សព្វផ្សាយសម្របសម្រួលពីតម្រូវការនិងការផ្គត់ផ្គង់កម្លាំងពលកម្ម ១៣ សហគ្រាស មាន ៣១៦កន្លែង។ បានជួយសម្របសម្រួលក្នុងការចុះឈ្មោះស្វែងរកការងារធ្វើ បន្តផ្សព្វផ្សាយឱកាសការងារតាមរយៈស្កេន QR Code ឬ តាមរយៈលេខ ១២៩៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចំនួន **២៩៨**នាក់ ស្រី **១២៨**នាក់។ សម្របសម្រួលជាមួយមជ្ឈមណ្ឌលការងារខេត្ត (NEA) រៀបចំវេទិកាការងារនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេសខេមបូឌាន ចេជាង ហ្វ៉ូដើមានពលករវិលត្រឡប់មកពីព្រះរាជាណាចក្រថៃបានចូលរួមចំនួន **២៩៨**នាក់ ស្រី **១២៨**នាក់។ សម្របសម្រួលទទួលបងប្អូនពលករចំណាកស្រុក ដែលវិលត្រឡប់ពីព្រះរាជាណាចក្រថៃ មកព្រះរាជាណាចក្រកម្ពុជា និងស្វែងរកការងារចំពោះមុខជូនពួកគាត់តាមសមត្ថភាព និងជំនាញបានចំនួន **៥៤៦**នាក់ ស្រី **២៤៨**នាក់ ក្នុងនោះមានពលករដែលរស់នៅក្នុងខេត្តព្រះសីហនុផ្ទាល់ចំនួន ៣៤៥នាក់ ស្រី១៦៣នាក់ និងពលករឆ្លងខេត្តផ្សេងៗចំនួន **២០១**នាក់។

▪ **ខេត្តព្រះវិហារ៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្សព្វផ្សាយឱកាសការងារដល់បងប្អូន ប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើ តាមរយៈហ្វេសប៊ុកផេក គ្រុបតេឡេក្រាម និងចែកប័ណ្ណផ្សព្វផ្សាយចំនួន ១៤៣លើក មានចំនួន ១៤៣ប័ណ្ណ អ្នកទទួលបាន ៥.៥៤០នាក់ ស្រី ១.៤៨៤នាក់។

### ❖ ការបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត

▪ **រាជធានី-ខេត្ត មន្ទីរ អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ៖** បានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត ផ្នែកជួសជុលម៉ូតូ ជួសជុលគ្រឿងយន្តកសិកម្ម អ៊ុតសក់ ផាត់មុខ កុំព្យូទ័រ រដ្ឋបាល ភាសាអង់គ្លេស បច្ចេកទេសដាំដំណាំ ធ្វើជីកំប៉ុស្តិ៍ បច្ចេកទេសចិញ្ចឹមត្រី-មាន់-ជ្រូក បច្ចេកទេសបណ្តុះកូនឈើ បច្ចេកទេសជួសជុលអណ្តូងស្នប់ និងជំនាញផ្សេងៗ ដល់ប្រជាពលរដ្ឋក្រីក្រក្នុងសហគមន៍ ស្ត្រីមេម៉ាយ ក្មេងបោះបង់ការសិក្សា

ដើម្បីលើកកម្ពស់ជីវភាព និងកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន បានចំនួន **១៦៦**លើក អ្នកទទួលបានសេវា ចំនួន **១២.៦០២**នាក់ ស្រី **៦.៧៧៦**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាពថ្នាក់ក្រោមជាតិ | ចំនួនលើក | អ្នកទទួលសេវា | ស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តសៀមរាប | ៤៣ | ៨.៦៧៤ | ៤.៣១៧ |
| ២ | ខេត្តប៉ៃលិន | ២៩ | ១.២៩៣ | ៨២៣ |
| ៣ | ខេត្តកំពង់ឆ្នាំង | ០៣ | ៩០ | ៧៥ |
| ៤ | ខេត្តព្រះសីហនុ | ០៤ | ៣៧៣ | ៩៤ |
| ៥ | ខេត្តកំពង់ចាម | ១០ | ៤១២ | ៤០៣ |
| ៦ | ខេត្តមណ្ឌលគិរី | ០២ | ៩៥ | ៦៧ |
| ៧ | ខេត្តកំពង់ស្ពឺ | ២០ | ៤០០ | ១៤១ |
| ៨ | ខេត្តបន្ទាយមានជ័យ | ០២ | ២០០ | ២០០ |
| ៩ | ខេត្តស្វាយរៀង (សហការ ១៩ក្រុមហ៊ុន) | ៥៣ | ១.០៦៥ | ៦៥៦ |
| សរុប | | **១៦៦ លើក** | **១២.៦០២ នាក់** | **៦.៧៧៦ នាក់** |

❖ **ការផ្តល់ឥណទានសម្រាប់បង្កើនមុខរបរការងារ**

▪ **ក្រសួងអភិវឌ្ឍន៍ជនបទ៖** ការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ គឺជាកម្លាំងចលករមួយកំពុងរួមចំណែកយ៉ាងសកម្មក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជននៅជនបទ តាមរយៈការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការបង្កើតមុខរបរខ្នាតតូច និងការផ្តល់ឥណទានខ្នាតតូច។ ក្រសួងបានរៀបចំតាំងពិព័រណ៍ផលិតផលជនបទចំនួន ១លើក, បានចុះតាមដានការអនុវត្តឥណទានសហគមន៍សន្សំប្រាក់ និងរៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ ជោគជ័យ និងបញ្ហាប្រឈមរបស់សហគមន៍សន្សំប្រាក់។ គិតត្រឹមឆ្នាំ២០២៥ ក្រសួងមានទ្រព្យសកម្មសរុបចំនួន **២ ២០៥ ៣៥២ ៨០៨** រៀល ដែលបានផ្តល់ឥណទានជូនប្រជាពលរដ្ឋចំនួន **១៥៩**នាក់ ស្រី **៩៦**នាក់ ក្នុងភូមិគោលដៅចំនួន ៤៣ភូមិ ២២ឃុំ និង ១២ស្រុក ក្នុងខេត្តគោលដៅចំនួន៩។ ក្រសួងបានបណ្តុះបណ្តាល និងសិក្ខាសាលាពង្រឹងសមត្ថភាពប្រជាពលរដ្ឋ និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបានចំនួន **១.៥០២**លើក មានអ្នកចូល រួមចំនួន **៦៦.៨៥៨**នាក់ លើជំនាញចម្រុះរួមមាន៖ ទឹកស្អាតនិងអនាម័យជនបទ, គោលគំនិតនៃការអភិវឌ្ឍសហគមន៍, ជំនាញមូលដ្ឋានសួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត,ការត្រៀមបង្ការកាត់បន្ថយគ្រោះមហន្តរាយ, ការបង្កើតការកែច្នៃផលិតផលសហគមន៍ជនបទ, ការធ្វើសិប្បកម្មផលិតសាប៊ូ, ជំនាញមិនមែនក្សេត្រកម្ម, ការវេចខ្ចប់ផលិតផលសហគមន៍ជនបទ, ការជំរុញចងក្រងសហគមន៍ធុរកិច្ច, កិច្ចបញ្ជីការគ្រប់គ្រងហិរញ្ញវត្ថុក្នុងអាជីវកម្មភាពជាសហគ្រិន លើការគ្រប់គ្រងអាជីវកម្មខ្នាតតូច, ការគាំទ្រដំណើរការសហគមន៍សន្សំប្រាក់, ការប្រើប្រាស់និងគាំទ្រផលិតផលក្នុងស្រុក និងការអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិច។

### ក.៧. ការសិក្សាស្រាវជ្រាវ

▪ **អង្គការវើលដ៏វីសិនអន្តរជាតិប្រចាំកម្ពុជា** បានធ្វើការសិក្សាស្រាវជ្រាវ ស្តីពី«តួនាទីរបស់ ឪពុកម្តាយ និងអ្នកមើលថែ ក្នុងការការពារ ទប់ស្កាត់ឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា តាមរយៈការពិភាក្សាក្រុម និងការសម្ភាសអ្នកផ្តល់ព័ត៌មានជាគន្លឹះ មានអ្នកចូលរួមចំនួន **១១៦**នាក់ ស្រី **៦៦**នាក់។

# ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## ខ.១. ការងារអនុវត្តច្បាប់

### ❖ ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

**ក្រុមការងារអនុវត្តច្បាប់ នៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន **២៧២**ករណី (ធៀបនឹងឆ្នាំ២០២៤ ចំនួន ១៩៨ករណី កើន **៧៤**ករណី) ស្មើនឹង **៣៧,៣៧%** ៖

- **ឃាត់ខ្លួនជនសង្ស័យ**បញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន **៤១០**នាក់/**២៧៣**នាក់ (ស្រី **៥៣**នាក់) ជនបរទេស **៤៣**នាក់(ស្រី០១នាក់) រួមមាន៖ ចិន**៣៣**នាក់ វៀតណាម**០៥**នាក់ ថៃ ០៤នាក់ ម៉ាឡេស៊ី០១នាក់។
- **សង្គ្រោះជនរងគ្រោះ**ចំនួន **៩៩៤**នាក់/**៥២៣**នាក់(ស្រី**៦២៤**នាក់) មានអាយុក្រោម១៥ឆ្នាំ **១៤៩**នាក់ (ស្រី១៣១) អាយុ១៥-១៧ឆ្នាំ **១៧០**នាក់(ស្រី១៥១នាក់) អាយុ១៨ឆ្នាំឡើង **៦៧៥**នាក់(ស្រី៣៤២នាក់) (បញ្ជូនទៅមន្ទីរសង្គមកិច្ច **៣៣១**នាក់ អន្តោប្រវេសន៍ **៣០**នាក់ និងគ្រួសារ **៦៣៣**នាក់)។ ក្នុងនោះចែកជា៖

#### ✚ ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន **១២៨/៥៣**ករណី (កើន **៧៥**ករណី) **ឃាត់ខ្លួនជនសង្ស័យ ២០៩**នាក់(ស្រី **១៥**នាក់) ជនបរទេស**១៧**នាក់(ចិន**១៣**នាក់ ថៃ០៤នាក់)។ **សង្គ្រោះជនរងគ្រោះ ៦០៩**នាក់(ស្រី**២៤៧**នាក់) មានអាយុក្រោម១៥ឆ្នាំ **២៧**នាក់(ស្រី១០នាក់) អាយុ១៥-១៧ឆ្នាំ **៣៣**នាក់(ស្រី១៤នាក់) អាយុ១៨ឆ្នាំឡើង **៥៤៩**នាក់ (ស្រី២២៣នាក់) និងបានបញ្ជូនទៅសង្គមកិច្ច **៦៣**នាក់ អន្តោប្រវេសន៍ **៣០**នាក់ និងគ្រួសារ **៥១៦**នាក់។

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| បទល្មើស | មាត្រា | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|---|
| ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៩ | ០៤ | ០៦ | | ០៥(០៤) |
| ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០ | ០៣ | ០៤ | | ០៤(០៤) |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ៦២ | ៨៩ | ថៃ៤ | ៣៤៦(១៥៩) |
| ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ១២ | ០៣ | ០៤ | ចិន៣ | ២៥ |
| អំពើលក់ដូរមនុស្ស | ១៤ | ០៥ | ១២ | ចិន២ | ១១ |
| ការដឹកជញ្ជូនដោយមានគោលដៅ | ១៧ | ១៣ | ៣៨ | ចិន៦ | ២៥(០៤) |
| អំពើនាំឆ្លងដែន | ១៨ | ០៣ | ០៤ | ចិន២ | ០៨(០១) |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ២០ | ៣២ | ៤៩ | | ១៨២(៧២) |
| ការទិញពេស្យាចារកុមារ | ៣៤ | ០៣ | ០៣ | | ០៣(០៣) |
| សរុប | | ១២៨ | ២០៩ | ១៧ | ៦០៩(២៤៧) |

#### ✚ ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **១៤៤/១៤៥**ករណី (ថយចុះ ០១ករណី) **ឃាត់ខ្លួនជនសង្ស័យ ២០១**នាក់(ស្រី **៣៨**នាក់) ជនបរទេស**២៦**នាក់(វៀតណាម០៥នាក់ ចិន២០នាក់ ម៉ាឡេស៊ី០១នាក់)។ **សង្គ្រោះជនរងគ្រោះ ៣៨៥**នាក់ (ស្រី**៣៧៧**នាក់) មានអាយុក្រោម១៥ឆ្នាំ **១២២**នាក់(ស្រី១២១នាក់) អាយុ១៥-១៧ឆ្នាំ **១៣៧**នាក់ស្រី អាយុ ១៨ឆ្នាំឡើង **១២៦**នាក់(ស្រី១១៩នាក់) និងបានបញ្ជូនទៅមន្ទីរសង្គមកិច្ច **២៦៨**នាក់ និងគ្រួសារ **១១៧**នាក់។

***តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ***

| បទល្មើស | មាត្រា | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|---|
| ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ២១ | ០៣ | ០៩ | ចិន៣ វៀតណាម៤ | ០៥(១) |
| ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬបង្ខាំង) | ២២ | ០៣ | ០៥ | ចិន៥ | ០៣ |
| សញ្ជារកម្ម | ២៦ | ០៦ | ០៧ | វៀតណាម១ | ២១(២១) |
| ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ២៧ | ០២ | ០៣ | ចិន២ | ២៤(២៤) |
| សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨ | ២១ | ៤៥ | | ២០៧(២០៧) |
| ការដឹកនាំគ្រឹះស្ថានពេស្យាចារ | ៣១ | ០១ | ០២ | ចិន២ | ០៧(០៧) |
| រូបភាព និងសម្ភារៈអាសអាភាស | ៣៩ | ១១ | ២២ | ចិន៦ ម៉ាឡេស៊ី១ | ១០(១០) |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១ | ០៧ | ១០ | | ០៩(០៩) |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២ | ៧២ | ៨០ | ចិន២ | ៧៤(៧៣) |
| អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៣ | ១៨ | ១៨ | | ២៥(២៥) |
| សរុប | | ១៤៤ | ២០១ | ២៦ | ៣៨៥(៣៧៧) |

ក្រៅពីនេះ ក្នុងប្រតិបត្តិការ បង្ក្រាបបទល្មើសឆបោកតាមអនឡាញ សមត្ថកិច្ចបានរកឃើញពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួនបីករណី មានមនុស្ស ០៥នាក់ មានមួយសញ្ជាតិ ដែលបានរងគ្រោះដោយបទល្មើសបង្ខាំងមនុស្សខុសច្បាប់ និងអំពើជួញដូរមនុស្ស។

## ២.២. កិច្ចការយុត្តិធម៌

❖ **លទ្ធផលចំណាត់ការផ្តន្ទាទោស**

**ក្រុមការងារកិច្ចការយុត្តិធម៌ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងយុត្តិធម៌** ទិន្នន័យទទួលបានពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

**១. ដំណាក់កាលអយ្យការ-បទល្មើសជួញដូរមនុស្ស**

សំណុំរឿងសរុបចំនួន **៦១១** ក្នុងនោះ(សំណុំរឿងសល់ពីមុន **៣០** និងសំណុំរឿងចូលថ្មី **៥៨១**)៖

-**ជនរងគ្រោះ** សរុបចំនួន **១.០១៩**នាក់(ស្រី**៤២១**នាក់) ក្នុងនោះ៖ នីតិជន**៥០០**នាក់(ស្រី**១៧២**នាក់) អនីតិជន **២៦២**នាក់(ស្រី**២១២**នាក់) និងជនបរទេស **២៥៧**នាក់(ស្រី**៣៧**នាក់)។

-**ជនល្មើស** សរុបចំនួន **១.១៩៦**នាក់(ស្រី **៦៤**នាក់) ក្នុងនោះ៖ នីតិជន **៧១៤**នាក់(ស្រី**៤១**នាក់) អនីតិជន **៨០**នាក់(ស្រី**០៥**នាក់) ជនបរទេស **៣៦៤**នាក់(ស្រី**១៨**នាក់) និងអញ្ញាតជន **៣៨**នាក់។

**តារាងចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

| សំណុំរឿង | | ជនរងគ្រោះ | | | | | | | ជនល្មើស | | | | | | | | សំណុំរឿងចាត់ការរួច | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុបរួម | នីតិជន | | អនីតិជន | | បរទេស | | សរុបរួម | នីតិជន | | អនីតិជន | | បរទេស | | អញ្ញាតជន | សរុបរួម | បញ្ជូនរឿងទៅស៊ើបសួរ | បញ្ជូនរឿងទៅជម្រះ | ទទីដែលបង្ហាញខ្លួនក្លាយ | តម្កល់រឿងទុកឥតចាត់ការ | បញ្ចូលសំណុំរឿង | ផ្ញើរសមត្ថកិច្ច | រឿងសល់កំពុងចាត់ការ |
| | | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | | | | |
| ចាស់ | 30 | | | | | | | | | | | | | | | | | | | | | | | |
| ថ្មី | 581 | | 328 | 172 | 50 | 212 | 220 | 37 | | 673 | 41 | 75 | 5 | 346 | 18 | | | | | | | | | |
| សរុប | 611 | 1019 | 500 | | 262 | | 257 | | 1196 | 714 | | 80 | | 364 | | 38 | 554 | 507 | 3 | 0 | 41 | 2 | 1 | 57 |

## ២. ដំណាក់កាលស៊ើបសួរ-បទល្មើសជួញដូរមនុស្ស

សំណុំរឿងសរុបចំនួន **៦៩០** ក្នុងនោះ(សំណុំរឿងសល់ពីមុន **១៨៤** និងសំណុំរឿងចូលថ្មី **៥០៦**)

-**ជនរងគ្រោះ**សរុបចំនួន **៦៥០**នាក់(ស្រី **៣៦៧**នាក់) ក្នុងនោះ នីតិជន **១៩៩**នាក់(ស្រី **៨៦**នាក់) អនីតិជន **២៣៣**នាក់(ស្រី**២៣០**នាក់) និងជនបរទេស **២១៨**នាក់(ស្រី **៥១**នាក់)។

-**ជនត្រូវចោទ**សរុបចំនួន **១.០៤២**នាក់(ស្រី**៩១**នាក់) ក្នុងនោះ នីតិជន **៦៤០**នាក់(ស្រី **៥៦**នាក់) អនីតិជន **៩១**នាក់(ស្រី**១៦**នាក់) និងជនបរទេស **៣១១**នាក់(ស្រី**១៩**នាក់)។

**តារាងចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត**

| **សំណុំរឿង** | | **ជនរងគ្រោះ** | | | | | | | **ជនត្រូវចោទ** | | | | | | | | | | **សំណុំរឿងចាត់ការរួច** | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | **សរុប** | នីតិជន | | អនីតិជន | | បរទេស | | **សរុប** | នីតិជន | | អនីតិជន | | បរទេស | | ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ | | | **សរុប** | បញ្ជូនរឿងទៅជំនុំជម្រះ | លើកលែងចោទប្រកាន់ | បញ្ឈប់រឿង | ផ្ទេរសមត្ថកិច្ច | រឿងកំពុងចាត់ការ | បញ្ជីរឿងខ្ទង់ណ៍ |
| | | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ចំនួនរឿង | មនុស្ស ៣ ប្រុស | ស្រី | | | | | | | |
| ចាស់ | 184 | | | | | | | | | | | | | | | | | | | | | | | | |
| ថ្មី | 506 | | 113 | 86 | 3 | 230 | 167 | 51 | | 584 | 56 | 75 | 16 | 292 | 19 | | | | | | | | | | |
| សរុប | 690 | 650 | 199 | | 233 | | 218 | | 1042 | 640 | | 91 | | 311 | | 3 | 7 | 1 | 374 | 365 | 9 | 0 | 0 | 316 | 1 |

## ៣. ដំណាក់កាលជំនុំជម្រះ-បទល្មើសជួញដូរមនុស្ស

សំណុំរឿងសរុបចំនួន **៣៧៥** ក្នុងនោះ(សំណុំរឿងសល់ពីមុន **៨២** និងសំណុំរឿងចូលថ្មី **២៩៣**)៖

-**ជនរងគ្រោះ**សរុបមានចំនួន **៣៨៥**នាក់(ស្រី**២៦៥**នាក់) ក្នុងនោះ នីតិជន**១០៤**នាក់(ស្រី **៦៧**នាក់) អនីតិជន **២០៩**នាក់(ស្រី**១៩៤**នាក់) និងជនបរទេស **៧២**នាក់(ស្រី**០៤**នាក់)។

-**ជនជាប់ចោទ**សរុបមានចំនួន **៥៦៩**នាក់(ស្រី**៥០**នាក់) ក្នុងនោះ នីតិជន **៤៣៣**នាក់(ស្រី**៤០**នាក់) អនីតិជន **៦៨**នាក់(ស្រី**០៤**នាក់) និងជនបរទេស **៦៦**នាក់(ស្រី**០៦**នាក់)។

**តារាងដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត**

| **សំណុំរឿង** | | **ជនរងគ្រោះ** | | | | | | | **ជនជាប់ចោទ** | | | | | | | | **សំណុំរឿងចាត់ការរួច** | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | **សរុប** | នីតិជន | | អនីតិជន | | បរទេស | | **សរុប** | នីតិជន | | អនីតិជន | | បរទេស | | អញ្ញាតជន | បានជំនុំជម្រះ | ផ្ទេរសមត្ថកិច្ច | រួចផុតបទចោទ | | | ផ្តន្ទាទោស | | | | ទោសព្យួរ | | | សរុបចាត់ការរួច | រឿងកំពុងចាត់ការ | បញ្ជីរឿងខ្ទង់ណ៍ |
| | | | | | | | | | | | | | | | | | | | សំណុំរឿង | មនុស្ស | | ពិន័យជាប្រាក់ | ដាក់ពន្ធនាគារ | មនុស្ស | | ព្យួរទោសទាំងស្រុង | មនុស្ស | | | | |
| | | | ប | ស | ប | ស | ប | ស | | ប | ស | ប | ស | ប | ស | | | | | ប | ស | | | ប | ស | | ប | ស | | | |
| ចាស់ | 82 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ថ្មី | 293 | | 37 | 67 | 15 | 194 | 68 | 4 | | 393 | 40 | 64 | 4 | 60 | 6 | | | | | 4 | 4 | | | 208 | 28 | | 20 | 2 | | | |
| សរុប | 375 | 385 | 104 | | 209 | | 72 | | 569 | 433 | | 68 | | 66 | | 2 | 265 | 5 | 5 | 8 | | 24 | 242 | 236 | | 26 | 22 | | 270 | 105 | 4 |

## គ. កិច្ចការពារជនរងគ្រោះ

### គ.១ ការទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ ក្នុងប្រទេស និងពីក្រៅប្រទេស

ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ ដោយអំពើជួញដូរមនុស្សក្នុងប្រទេស និងក្រៅប្រទេស ចំនួន**៣៥៥**នាក់(ប្រុស១៩នាក់ ស្រី២៥២នាក់ កុមារា១៣នាក់ កុមារី៧១នាក់)។

- បានទទួលនៅក្នុងប្រទេស ចំនួន **៩១នាក់**(ប្រុស ០៦នាក់ ស្រី៥៨នាក់ កុមារា០៦នាក់ កុមារី២១នាក់) ក្នុងនោះមាន៖

-ជនជាតិខ្មែរ **៦៥នាក់**(ប្រុស០៤នាក់ ស្រី២៤នាក់ កុមារា០៦នាក់ កុមារី២១នាក់) រួមមានករណីអាពាហ៍ពិពាហ៍ផ្ទុយពីធម្មតា ០១នាក់ ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ៤៤នាក់ សញ្ញាកម្ម ១៩នាក់ រំលោភបំពានផ្លូវភេទ ០១នាក់(កុមារាសញ្ជាតិខ្មែរ-បារាំង)។

-ជនបរទេស **២៦នាក់**(ប្រុស០២នាក់ ស្រី២៤នាក់) ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម០៥នាក់(ថៃ ០២នាក់ ចិន០២នាក់ កូរ៉េ០១នាក់) ករណីសញ្ញាកម្ម២១នាក់(ឡាវ១៦នាក់ វៀតណាម០៤នាក់ ថៃ០១នាក់)។

- បានទទួលពីបរទេស ចំនួន **២៦៤នាក់**(ប្រុស១៣នាក់ ស្រី១៩៤នាក់ កុមារា០៧នាក់ កុមារី៥០នាក់) ក្នុងនោះមកពី៖

-ប្រទេសចិន ២២៣នាក់(ស្រី១៧៩នាក់ កុមារី៤៤នាក់) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធម្មតា

-ប្រទេសម៉ាឡេស៊ី ០១នាក់ ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម

-ប្រទេសមីយ៉ាន់ម៉ា ០១នាក់កុមារី ករណីអាជីវកម្មផ្លូវភេទ

-ងាយរងគ្រោះ ០១នាក់កុមារា

-ប្រទេសថៃ ៣៨នាក់(ប្រុស១៣នាក់ ស្រី១៤នាក់ កុមារា០៦នាក់ កុមារី០៥នាក់) ករណីកេងប្រវ័ញ្ចកម្លាំង ពលកម្ម២៥នាក់(ប្រុស០៨នាក់ ស្រី០៨នាក់ កុមារា០៦នាក់ កុមារី០៣នាក់) និងបុគ្គលសង្ស័យថារងគ្រោះ ១៣នាក់(ប្រុស០៥នាក់ ស្រី០៦នាក់ កុមារី០២នាក់)។

- ***ជនរងគ្រោះក្រោយពីទទួលការបានកំណត់អត្តសញ្ញាណដោយមន្ត្រីនគរបាលយុត្តិធម៌ជំនាញ*** មានចំនួន **៣៣១**នាក់(ប្រុស១២នាក់ ស្រី២៣៩នាក់ កុមារា១១នាក់ កុមារី៦៩នាក់)។

### គ.២.ការផ្តល់សេវាគាំទ្រនិងស្តារនីតិសម្បទា

បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះទៅស្តារនីតិសម្បទានៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ ចំនួន **៣៥៥**នាក់ (ប្រុស១៩នាក់ ស្រី២៥២នាក់ កុមារា១៣នាក់ កុមារី៧១នាក់)។ បានបញ្ជូនទៅទទួលសេវាពីអង្គការមានដូចជា៖ អង្គការកៅរីតាសកម្ពុជា៧៩នាក់(ស្រី៦៨ កុមារី៩) អង្គការរតនៈអ៊ីនធឺណេសិនណល៨៦នាក់(ស្រី៧៤ កុមារី១១) អង្គការមូលនិធិហាការអន្តរជាតិ២៧នាក់(ស្រី២៣ កុមារី៣) អង្គការសម្ព័ន្ធចាប់ដៃ២០នាក់(ស្រី៨ កុមារី១២) អង្គការCWCC ៥៦នាក់(ស្រី៤៤ កុមារី១២) អង្គការIJM ០២នាក់(ស្រី១) អង្គការម៉ារីស៊ី១៤នាក់(កុមារី) អង្គការអាដហុក០៧នាក់(ស្រី) អង្គការមេត្រីអន្តរជាតិ០៤នាក់កុមារី អង្គការដើម្បីភាពញញឹមនៃកុមារ(PSE) ០១នាក់កុមារា មណ្ឌលកុមារកំព្រាភ្នំពេញ ០៤នាក់កុមារា មជ្ឈមណ្ឌលស្តារនីតិសម្បទាប៉ោយប៉ែត ៤៧នាក់(ស្រី២០ កុមារី៦) ផ្ញើកិច្ចសន្យាប្រគល់ទៅគ្រួសារ០៥នាក់(ស្រី៤) និងអភិបាលខេត្តកណ្តាលយកទៅ០៣នាក់(ស្រី)។

### គ.៣.ការធ្វើសមាហរណកម្មជនរងគ្រោះ

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ ត្រឡប់ទៅសហគមន៍វិញសរុប **២០០**នាក់(ស្រី១៥៦នាក់ និងកុមារី៣៥នាក់)។

### គ.៤.ការធ្វើមាតុភូមិនិវត្តន៍

បានធ្វើមាតុភូមិនិវត្តន៍ជនបរទេសទៅប្រទេសដើមវិញ សរុបចំនួន **២៨**នាក់(ស្រី២៤នាក់) ជនជាតិឥណ្ឌា០២នាក់ ស្រីលង្កា០២នាក់ វៀតណាម០៦នាក់ ឡាវ១៦នាក់ ថៃ០១នាក់ និងជនជាតិចិន០១នាក់។

### គ.៥.ការតាមដានជនរងគ្រោះ

បានតាមដានជនរងគ្រោះ ចំនួន **៤៣៦**នាក់(ប្រុស២៦នាក់ ស្រី២៤៩នាក់ កុមារា១៩នាក់ កុមារី ១៤២នាក់)

### គ.៦.ការបិទករណីជនរងគ្រោះ

បានបិទករណីជនរងគ្រោះ ចំនួន **១០៧**នាក់(ប្រុស០១នាក់ ស្រី៩១នាក់ និងកុមារី១៥នាក់)។

## ឃ. ការរៀបចំច្បាប់ គោលនយោបាយ សន្ធិសញ្ញា កិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

### ឃ.១. លិខិតបទដ្ឋានគតិយុត្ត

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - បានប្រកាសដាក់ឱ្យប្រើប្រាស់ ផែនការជាតិ អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (NIP/GCM)
  - បានប្រកាសដាក់ឱ្យប្រើប្រាស់ សៀវភៅណែនាំ ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។
  - បានប្រកាសដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពី «បទដ្ឋានអប្បបរមា ដើម្បីផ្តល់ សេវាសមាហរណកម្ម និងសេវាបញ្ជូន» សម្រាប់មណ្ឌលទទួលពលករកំរៀង
  - បានបន្តរៀបចំ និងបញ្ចប់ឯកសារក្របខ័ណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រ(MEL) សម្រាប់ការតាមដាន វាយតម្លៃ ការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ និងត្រៀមប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**
  - បានចេញប្រកាសលេខ០៨១/២៥ ក.ប/ប្រ.ក.ម.ហ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៥ ស្តីពីការបង្កើតគណៈកម្មាធិការប្រឹក្សាយោបល់ នៃគម្រោងការពារសិទ្ធិស្ត្រី និងកុមារក្នុងបរិបទទេសន្តរប្រវេសន៍ការងារនៅក្នុងប្រទេសកម្ពុជា
  - បានចេញសេចក្តីសម្រេចលេខ០០៣/២៥ ក.ប/ស.ស.រ.ក.ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការបង្កើតក្រុមការងារលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ
  - បានចេញសេចក្តីសម្រេចលេខ១៤៤/២៥ក.ប/ស.ស.រ.ក.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ ស្តីពីការបង្កើតក្រុមការងារអនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចអន្តរាគមន៍ស្នូល ដើម្បីទប់ស្កាត់ ការពារ និងបន្ធូរគាំពារកុមារងាយរងគ្រោះ និងពលកម្មកុមារ
  - បានចេញសេចក្តីជូនដំណឹង ស្តីពីការស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៦
  - បានចេញសេចក្តីជូនដំណឹង ស្តីពីការស្នើសុំពន្យាសុពលភាពបណ្ណការងារ និងសៀវភៅ ការងារជនបរទេសឆ្នាំ២០២៥ និងសេចក្តីជូនដំណឹង ស្តីពីការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស ឆ្នាំ២០២៦
  - បានចេញសេចក្តីជូនដំណឹង ស្តីពីការប្រុងប្រយ័ត្នមុនពេលសម្រេចចិត្តទៅធ្វើការនៅបរទេស

- បានចេញសេចក្តីជូនដំណឹងទៅទីភ្នាក់ងារជ្រើសរើសឯកជន ស្តីពីការពង្រឹងការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស
- បានចេញសេចក្តីជូនដំណឹងទៅទីភ្នាក់ងារជ្រើសរើសឯកជន ស្តីពីការពង្រឹងការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស
- បានរៀបចំសេចក្តីព្រាងសេចក្តីណែនាំ ស្តីពីសុពលភាពនៃការចុះបញ្ជីកាកិច្ចសន្យាការងារជនបរទេស
- បាននិងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីទេសន្តរប្រវេសន៍ការងារ ឆ្នាំ២០២៥-២០៣៤
- បាន និងកំពុងរៀបចំសេចក្តីព្រាងកែសម្រួលប្រកាសលេខ ០៤៦ ស្តីពីដំណើរការជ្រើសរើស និងការណែនាំតម្រង់ទិសពលករមុនចេញដំណើរ
- បាន និងកំពុងរៀបចំសេចក្តីព្រាងកែសម្រួលប្រកាសលេខ ២៥១ ស្តីពីការលើកសរសើរនិងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន
- បាន និងកំពុងរៀបចំរបាយការណ៍វាយតម្លៃ ការអនុវត្តគោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១៧-២០២៥
- បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាង គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០២៦-២០៣៥។

▪ **ក្រសួងកិច្ចការនារី ៖**

- ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "គោលការណ៍ណែនាំ ស្តីពីការរៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ" រួមទាំងស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស
- បានរៀបចំពិនិត្យលើសេចក្តីព្រាងផែនការមហាអនុតំបន់ SPA V និងសូចនាកររួម និងឯកសារពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងភាគីចិន ចំនួន ២លើក ក្នុងគោលបំណងដើម្បីធ្វើកំណត់ហេតុកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (RTF) និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីត (SOM16) ដែលបានរៀបចំនៅប្រទេសចិនកន្លងមក សេចក្តីព្រាងផែនការមហាអនុតំបន់ SPA V ២០២៥-២០៣០ សូចនាកររួមសម្រាប់ការកំណត់អត្តសញ្ញាណនៃអំពើជួញដូរមនុស្ស និងជម្រើសលេខាធិការដ្ឋានខមមីតថ្នាក់តំបន់។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានប្រកាសដាក់ឱ្យប្រើប្រាស់ សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដោយបានសហការជាមួយអង្គការតេនៈអ៊ីនធីណេសិនណល អង្គការ IOM និង ASEAN-ACT។

▪ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖** បានដាក់ចេញនូវគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២៤-២០២៨ ដែលមានចក្ខុវិស័យយូរអង្វែង ដើម្បីបន្តធានាបាននូវសន្តិសុខស្បៀងប្រកបដោយនិរន្តរភាព ចូលរួមចំណែករក្សាកំណើនសេដ្ឋកិច្ចជាតិ និងការការពារបរិស្ថាន ព្រមទាំងបានកំណត់នូវទិសដៅច្បាស់លាស់ក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ជាពិសេសការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋកម្ពុជា។

▪ **ក្រសួងទេសចរណ៍៖**

- សេចក្តីប្រកាសលេខ០៧៦ប្រក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ «គ.ស.ក.ទ»

- សេចក្ដីណែនាំជំរុញការត្រួតពិនិត្យ និងពង្រឹងយន្ដការគ្រប់គ្រងអាជីវកម្ម ក្លឹបកម្សាន្ដ ខារ៉ាអូខេ វង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន ដើម្បីធានាបាននូវសន្ដិសុខ សុវត្ថិភាពភ្ញៀវ ទប់ស្កាត់បញ្ហាអគ្គីភ័យ ការជួញដូរគ្រប់ទម្រង់ និងសកម្មភាពខុសច្បាប់គ្រប់ប្រភេទ ក្នុងមូលដ្ឋានអាជីវកម្មខេត្តគោលដៅចំនួន ១១ ក្នុងនោះមាន៖ ខេត្តកំពង់ឆ្នាំង តាកែវ កំពង់ស្ពឺ ព្រះសីហនុ កណ្ដាល ពោធិ៍សាត់ សៀមរាប កំពត ត្បូងឃ្មុំ បាត់ដំបង និងខេត្តកំពង់ចាម ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តតាមរយៈ សេចក្ដីណែនាំលេខ០០៥ សណន ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ ស្ដីពីការពង្រឹងយន្ដការគ្រប់គ្រងអាជីវកម្មមណ្ឌលកម្សាន្ដទេសចរណ៍មនុស្សពេញវ័យ។

▪ **ខេត្តត្បូងឃ្មុំ៖** យោងលិខិតលេខ ០៥៦/២៥ សជណ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រកាសចេញដីកាអមលេខ ០៤៤/២៥ ដកអ.តឃ ជូនដំណឹងទៅប្រធានមន្ទីរអង្គភាពជុំវិញខេត្ត ដើម្បីធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងទេសន្ដរប្រវេសន៍ខុសច្បាប់ និងត្រូវឱ្យពួកគាត់មានការប្រុងប្រយ័ត្ន ក្នុងការចាញ់ជនឆបោកជាមេខ្យល់ ដែលបានអូសទាញប្រជាពលរដ្ឋ ឬតាមរយៈសារ ឬព័ត៌មានដែលមិនពិតតាមគណនីអនឡាញគ្រប់ប្រភេទជាដើម។

▪ **ខេត្តកោះកុង៖** បានចេញសេចក្ដីសម្រេចកែសម្រួលសមាសភាពក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត លេខ១១៨ ចុះថ្ងៃទី២៨ ខែវិច្ឆកា ឆ្នាំ២០២៥ ចំនួន០១ច្បាប់។

▪ **ខេត្តកំពង់ឆ្នាំង៖** បានចេញសេចក្ដីសម្រេចលេខ ០០១/២៥ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥ ស្ដីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ)។

▪ **ខេត្តមណ្ឌលគិរី៖** រៀបចំសេចក្ដីសម្រេច កែសម្រួលសមាសភាពលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ)។

### ឃ.២. កិច្ចសហប្រតិបត្តិការ

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**

- បានចុះអនុស្សរណៈ នៃការយោគយល់ ជាមួយអង្គការ ការីតាស់ស្វីស (CARITAS SWITZERLAND) ស្ដីពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទម្រង់ផ្សេងទៀត នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក ជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ស្ដីពីសកម្មភាពបង្ការទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ក្នុងបរិបទទេសន្ដរប្រវេសន៍ ២០២៥-២០២៨ និងជាមួយ អង្គការម៉ារីស៊ី ស្ដីពីការរួមចំណែកក្នុងសកម្មភាពមនុស្សធម៌សម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

▪ **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖**

- បានដាក់ចេញផែនការសកម្មភាពរួម ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ ដំណាក់កាលទី២ (២០២៥-២០២៨) កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៥
- បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការ នៃវិស័យការងាររវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥
- បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិទេសន្ដរប្រវេសន៍ (IOM) ប្រចាំកម្ពុជា ស្ដីពីការពង្រឹងទេសន្ដរប្រវេសន៍ការងារនៅកម្ពុជា កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥

- បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃរដ្ឋអ៊ីស្រាអែល ស្តីពីការងារបណ្តោះអាសន្នរបស់ពលករខ្មែរក្នុងវិស័យទីផ្សារការងារជាក់លាក់នៅរដ្ឋអ៊ីស្រាអែល កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥
- បានចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីគាំទ្រប្រជាពលករខ្មែរត្រឡប់មកកម្ពុជាវិញ កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥។

▪ **ក្រសួងកិច្ចការនារី៖** បានបន្តចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយអង្គការណូមីណេតវ៉ើកកម្ពុជា (NOMINETWORK CAMBODIA) លើការអនុវត្តគម្រោងអភិវឌ្ឍន៍បំណិនជីវិត និងជំនាញបច្ចេកទេសដល់ស្ត្រីសម្រាប់ការងារ និងការប្រកបមុខរបររយៈពេល ៣ឆ្នាំ (២០២៦-២០២៨) ដើម្បីរួមចំណែកលុបបំបាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចក្នុងចំណោមស្ត្រីក្រុមគោលដៅ។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** បានចុះអនុស្សរណៈជាមួយ អង្គការម៉ារីស៊ី ស្តីពីការរួមចំណែកក្នុងសកម្មភាពមនុស្សធម៌សម្រាប់ការងារប្រឆាំងអំពើជួញដូរមនុស្ស។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ **ការបណ្តុះបណ្តាលក្នុងប្រទេស**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាព គ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ បានចំនួន **២៩៤**វគ្គ មានសិក្ខាកាមចូលរួមចំនួន **១០.៩៩៥**នាក់ ស្រី **៥.០១៨**នាក់ ដូចមានក្នុងតារាងខាងក្រោម៖ ***(ឧបសម្ព័ន្ធ)***

| សកម្មភាពបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនសិក្ខាកាម | ចំនួនស្ត្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១១៤ | ៣.៥៩៥ | ១.៥៣២ |
| ក្រសួងកិច្ចការនារី | ០៤ | ១៧៧ | ១២៧ |
| ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ អង្គការ APLE | ០២ | ៩០ | ៤៥ |
| កាកបាទក្រហមកម្ពុជា | ០៧ | ២៤២ | ៣៦ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ១១ | ៨៩០ | ៣៥៥ |
| **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** សហការអង្គការមេត្រីអន្តរជាតិ អង្គការម៉ារីស៊ី | ១៣ | ១.១៩៨ | ៣៦០ |
| **សរុប** | **១៥១** | **៦.១៩២** | **២.៤៥៥** |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបន្ទាយមានជ័យ (HAGAR) | ០៩ | ៥៤៦ | ៣១០ |
| ខេត្តកំពង់ឆ្នាំង | ០២ | ១៣៦ | ០៨ |
| ខេត្តបាត់ដំបង (CCT, អង្គការហ្វូលន៍អន្តរជាតិ, សាម៉ារីតាន់ភឺស, HAGAR) | ១៣ | ៨៦១ | ៤៩៧ |

| | | | |
|---|---|---|---|
| ខេត្តកំពង់ស្ពឺ (HAGAR) | ០៨ | ៣៨២ | ១៨៥ |
| ខេត្តត្បូងឃ្មុំ (JICA, CHABDAI) | ០៥ | ៤៥៥ | ២២០ |
| ខេត្តក្រចេះ (APLE) | ០១ | ៦៥ | ៣៦ |
| ខេត្តរតនគិរី | ០១ | ១១២ | ៤៦ |
| ខេត្តសៀមរាប (A21, Friend International, IJM, TLC, HAGAR, CHABDAI) | ១៥ | ៦៥៤ | ៣៣៩ |
| ខេត្តកណ្តាល (APLE) | ០១ | ១២៥ | ៥១ |
| ខេត្តព្រះសីហនុ | ០១ | ៤១ | ១២ |
| ខេត្តព្រៃវែង | ០២ | ១៨ | ១០ |
| អង្គការមូលនិធិហាការ(HAGAR) (ភ្នំពេញ, ប៉ៃលិន, កំពង់ធំ, ស្វាយរៀង, តាកែវ) | ១០ | ៤៣០ | ២៥៤ |
| អង្គការ ERIKSJLPEN(អង្គការពន្លឺកម្ពុជា, អង្គការសម្ពន្ធគ្រីស្ទបរិស័ទកម្ពុជា, អង្គការគាំពារភូមិយើង, អង្គការម្លប់ឫស្សី) (ភ្នំពេញ, ព្រៃវែង, កំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, តាកែវ, សៀមរាប, ស្វាយរៀង, កំពង់ស្ពឺ) | ៧៥ | ១.០១៨ | ៥៩៥ |
| **សរុប** | **១៤៣** | **៤.៨០៣** | **២.៥៦៣** |
| **សរុបថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ** | **២៩៤ វគ្គ** | **១០.៩៩៥ នាក់** | **៥.០១៨ នាក់** |

❖ **ការចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស**

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** លោកជំទាវ ឧត្តមសេនីយ៍ទោ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកម្មវិធី បណ្តុះបណ្តាល "The International Management of Serious Crime XVIII (IMOSC XVIII) នៅទីក្រុងសេម៉ារ៉ង់ ប្រទេសឥណ្ឌូនេស៊ី រៀបចំដោយ AFP សហការជាមួយ JCLEC ដែលមានអ្នកចូលរួមជាមន្ត្រីប៉ូលិសចម្រុះស្ថាប័ន ចំនួន ១៤ប្រទេស(អូស្ត្រាលី ទីម័រ ថៃ វៀតណាម ឥណ្ឌូនេស៊ីឥណ្ឌា ម៉ាឡេស៊ី ស្រីលង្កា ប៉ាពួញូវហ្គីណេ អារ៉ាប់អេមីរេត កម្ពុជា ញូវហ្សេលែន ប៉ាគីស្ថាន និងបង់ក្លាដែស)។ លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ ដដែល បានចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាលស្តីពី "ឧត្តមភាពមេដឹកនាំប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សក្នុងតំបន់អាស៊ាន ( CTIP LEAP) ដែលជាការឧបត្ថម្ភនិងគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី អង្គការASEAN-ACT។ វគ្គបណ្តុះបណ្តាលមានរយៈពេល ១២ខែ ដោយមានការចូលរួមពី សិក្ខាកាចំនួន២០រូប ពីប្រទេសកម្ពុជា ឡាវ វៀតណាម ហ្វីលីពីន និងថៃ ។ ដំណើរការវគ្គបណ្តុះបណ្តាលប្រព្រឹត្តដោយការចូលរួមវគ្គផ្ទាល់ នៅទីក្រុងបាងកក ទីក្រុងហាណូយ ទីក្រុងម៉ានីល និងមានការឆ្លងឆ្លើយតាមការសិក្សាពីចម្ងាយចំនួន ៨ដង។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** កម្មវិធីបណ្តុះបណ្តាល ស្តីពី "ការកសាងសមត្ថភាពមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ" ដើម្បីពង្រឹងសមត្ថភាព និងការយល់ដឹងពាក់ព័ន្ធនឹងបរិយាកាសគោលនយោបាយសម្រាប់គាំទ្រដល់ពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្តន៍ឱ្យមានប្រសិទ្ធភាព នៅសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី៨-១២ ខែធ្នូ ឆ្នាំ២០២៥។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជូនមន្ត្រីនគរបាលជាន់ខ្ពស់ចំនួន **១០រូប** ទៅចូលរួមសិក្សា វគ្គបណ្តុះបណ្តាលប្រឆាំងការជួញដូរមនុស្ស (TIP) នៅមហាវិទ្យាល័យប៉ូលិសជាំងស៊ី ទីក្រុងណានឆាង នៃសាធារណរដ្ឋប្រជាមានិតចិន។

## គ.២.សិក្ខាសាលា

### ❖ សិក្ខាសាលាក្នុងប្រទេស

ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការ APLE, JICA, RATANAK INTERNATIONAL រៀបចំសិក្ខាសាលាដើម្បីពិគ្រោះយោបល់ និងផ្សព្វផ្សាយពង្រឹងសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) បានចំនួន **៣៧៥**លើក មានសិក្ខាកាមចូលរួមចំនួន **១៩.៦៤៦**នាក់ ក្នុងនោះមានស្ត្រី **១០.៤៥៥**នាក់ ដូចមានក្នុងតារាងខាងក្រោម៖ *(ឧបសម្ព័ន្ធ)*

| សកម្មភាពរៀបចំសិក្ខាសាលា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣៤៦ | ១៧.៧៣៥ | ៩.៧០១ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (JICA, RATANAK) | ០៥ | ៣៧៦ | ១៨២ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០២ | ១៤០ | ៨៨ |
| ក្រសួងទេសចរណ៍ | ០២ | ១៥៦ | ០០ |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០២ | ០០ | ០០ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (APLE, CHABDAI, HARGA) | ០៧ | ៥៦៧ | ២៦៩ |
| **សរុប** | **៣៦៤** | **១៨.៩៧៤** | **១០.២៤០** |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបន្ទាយមានជ័យ | ០៣ | ៤២ | ៣៧ |
| ខេត្តសៀមរាប | ០២ | ៣០៤ | ៦៣ |
| ខេត្តរតនគិរី | ០១ | ៣៥ | ២៣ |
| ខេត្តព្រៃវែង | ០១ | ៦២ | ២៩ |
| អង្គការ ERIKSJLPEN(អង្គការគាំពារភូមិយើង) (ព្រៃវែង, តាកែវ, កំពង់ស្ពឺ) | ០៤ | ២២៩ | ៦៣ |
| **សរុបថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ** | **៣៧៥** | **១៩.៦៤៦** | **១០.៤៥៥** |

### ❖ សិក្ខាសាលានៅក្រៅប្រទេស

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖ ១**/លោកជំទាវឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ-អន្តរជាតិ ចូលរួមសិក្ខាសាលាដើម្បីពិភាក្សាលើគោលការណ៍ណែនាំ កិច្ចសហប្រតិបត្តិការជាក់ស្តែង នៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្សឆ្លងដែន រៀបចំដោយ UNODC និង SOMTC-ហ្វីលីពីន ប្រទេសម៉ាឡេស៊ី ០១លើក និងចូលរួមសិក្ខាសាលា ស្តីពី REGIONAL VALIDATION WORKSHOP ON THE SUGGESTED LIST OF COMMON INDICATORS ON TRAFFICKING IN PERSONS (TIP) FOR THE PURPOSE OF FORCED CRIMINALITY FACILITATED BY ABUSE OF TECHNOLOGY នៅខេត្ត QUANG NINH នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ០១លើក។ **២**/ឯកឧត្តម ឧត្តមសេនីយ៍ទោ **តែ សុថារេត** អគ្គលេខាធិការរង បានអញ្ជើញទៅចូលរួមសិក្ខាសាលា ពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីដំណោះស្រាយបញ្ហាការធ្វើទេសន្តរប្រវេសន៍មិនប្រក្រតី តាមរយៈយុទ្ធនាការ ផ្សព្វផ្សាយព័ត៌មាន ប្រកបដោយប្រសិទ្ធិភាព បង្ការទប់ស្កាត់ការជួញដូរមនុស្ស និងការរត់ពន្ធមនុស្សឆ្លងដែន នៅក្នុងរដ្ឋសមាជិកនៃ Bali Process នៅប្រទេសឥណ្ឌូនេស៊ី ០១លើក។

## ២. សន្និសីទ កិច្ចប្រជុំ ជំនួបពិភាក្សា និងទស្សនកិច្ច

### ២.១. កិច្ចប្រជុំ

❖ **ការរៀបកិច្ចប្រជុំនៅក្នុងប្រទេស**

គណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រសួង/ស្ថាប័ន ជាសមាជិក នៃគ.ជ.ប.ជ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) សហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំកិច្ចប្រជុំពាក់ព័ន្ធ ដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ សរុបចំនួន **២៧៨**លើក មានអ្នកចូលរួមសរុប **៩.៦៣៨**នាក់ ស្រី **៣.៥៨៣**នាក់ ដូចមានក្នុងតារាងខាងក្រោម៖ (ឧបសម្ព័ន្ធ)

| សកម្មភាពរៀបចំកិច្ចប្រជុំ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០៩ | ២៩៧ | ១០៥ |
| ក្រសួងកិច្ចការនារី | ០៥ | ២៩៩ | ១៤៩ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(JICA-TRUST, IOM, ASEAN-ACT អង្គការរតនៈ) | ០៣ | ២២៥ | ៨៨ |
| ក្រសួងទេសចរណ៍ | ០៤ | ២១៦ | |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០១ | | |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ៦៤ | ១.០៥៥ | ៣០៧ |
| សរុប | ៨៦ លើក | ២.០៩២ នាក់ | ៦៤៩ នាក់ |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តព្រះវិហារ | ០៩ | ១៥៤ | ៥២ |
| ខេត្តសៀមរាប | ១៣៩ | ៤.៣៣៦ | ១.៨២២ |
| ខេត្តកំពង់ចាម | ១៥ | ៧២៣ | ៤៨៩ |
| ខេត្តស្វាយរៀង | ០១ | ៥៧ | ២១ |
| ខេត្តកណ្តាល | ១២ | ១.៣៥០ | ៣៣១ |
| ខេត្តតាកែវ | ០២ | ៣៤ | ០០ |
| ខេត្តបន្ទាយមានជ័យ | ០៣ | ៨៧ | ២៨ |
| ខេត្តឧត្តរមានជ័យ | ០២ | ៤៤ | ២១ |
| ខេត្តក្រចេះ | ០១ | ២៧ | ១៦ |
| ខេត្តកំពង់ធំ | ០២ | ១៤២ | ៣៦ |
| ខេត្តព្រៃវែង | ០៤ | ៤៨៩ | ៤៧ |
| ខេត្តត្បូងឃ្មុំ | ០១ | ៥៧ | ៣៦ |
| ខេត្តរតនគិរី | ០១ | ៤៦ | ៣៥ |
| សរុប | ១៩២ លើក | ៧.៥៤៦ នាក់ | ២.៩៣៤ នាក់ |
| សរុបរួមថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ២៧៨ លើក | ៩.៦៣៨ នាក់ | ៣.៥៨៣ នាក់ |

❖ **ការចូលរួម សន្និសីទ កិច្ចប្រជុំ នៅក្រៅប្រទេស**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

• លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងថ្នាក់ដឹកនាំក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានទៅចូលរួមកិច្ចប្រជុំ នៅក្រៅប្រទេស ចំនួន ០៤លើក គឺ៖

១-កិច្ចប្រជុំនៅប្រទេសថៃ ចំនួន ០២លើក គឺ៖ កិច្ចប្រជុំលើកទី២ នៃការពិនិត្យឡើងវិញការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលរៀបចំដោយ UN-ESCAP ចំនួន០១លើក និងកិច្ចប្រជុំ កិច្ចសន្ទនាលម្អិតលើកទី៣ របស់ការិយាល័យគាំទ្រប្រចាំតំបន់ នៃដំណើរការបាលី (Third RSO Constructive Dialogue) ចំនួន០១លើក។

២-បានដឹកនាំគណៈប្រតិភូ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ ដែលមានតំណាងមកពីស្ថានទូតកម្ពុជាប្រចាំនៅហ្វីលីពីន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ទៅចូលរួមកិច្ចសន្ទនាថ្នាក់តំបន់ និងការផ្លាស់ប្តូរចំណេះដឹងរវាងកម្ពុជា និងហ្វីលីពីន The Regional Dialogue and Knowledge Exchange Between Cambodia and the Philippines " នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ចំនួន០១លើក។

៣-កិច្ចប្រជុំ «The Regional Meeting on Countering People Smuggling and Related Transnational Crime» នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ចំនួន០១លើក។

៤-កិច្ចប្រជុំថ្នាក់តំបន់លើកទី៣ នៃគណៈកម្មាធិការជាតិអាស៊ីអាគ្នេយ៍ប្រឆាំងការជួញដូរមនុស្ស ដែលភាគីកម្ពុជា មានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅហ្វីលីពីន លេខាទី២ នៃស្ថានទូតកម្ពុជាប្រចាំនៅហ្វីលីពីន និងប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ រៀបចំឡើងដោយ ក្រុមប្រឹក្សាអន្តរស្ថាប័នថ្នាក់ជាតិប្រឆាំងអំពើជួញដូរមនុស្ស ហ្វីលីពីន (IACAT) នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១-បានចូលរួមកិច្ចប្រជុំ លទ្ធផលនៃកិច្ចសន្ទនាកម្រិតខ្ពស់លើកទី១ ស្តីពីការរៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីការពារកុមារទេសន្តរប្រវេសន៍ ០១លើក នៅប្រទេសថៃ

២-បានចូលរួមកិច្ចប្រជុំទ្វេភាគីកម្ពុជា-ជប៉ុន ប្រចាំឆ្នាំលើកទី៧ ស្តីពីការអនុវត្តកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស នៅប្រទេសជប៉ុន កាលពីថ្ងៃទី១៨-១៩ ខែវិច្ឆិកា ឆ្នាំ២០២៥។

▪ **ក្រសួងកិច្ចការនារី៖** បានចូលរួមកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (RTF) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៦ (IMM6) នៅប្រទេសវៀតណាម ក្នុងគោលបំណង ១.ការពិនិត្យបញ្ចប់ និងអនុម័តសេចក្តីព្រាងនៃផែនការសកម្មភាព Sub-Regional Plan of Action IV (SPAV) ២.កំណត់ សកម្មភាពជាក់លាក់៣ ដែលប្រទេសនីមួយៗផ្តល់អាទិភាពក្នុងរយៈពេល៣ឆ្នាំដំបូងនៃការអនុវត្ត SPA5 ៣.អនុម័តទៅលើសេចក្តីថ្លែងការរួម Joint Statement របស់ប្រទេសទាំង៦ នៃក្រុមការងារខមមីត។

▪ **អគ្គលេធិការដ្ឋាន គ.ជ.ប.ជ៖**

១-លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ បានចូលរួមកិច្ចប្រជុំ លើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការកិច្ចការពារកុមារ ដែលរងផលប៉ះពាល់ដោយការធ្វើទេសន្តរប្រវេសន៍ រវាងប្រទេសថៃ និងប្រទេសកម្ពុជា នៅប្រទេសថៃ ចំនួន០១លើក។

២-លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំជាលក្ខណៈអន្តរជាតិនៅនៅប្រទេសម៉ាឡេស៊ី៖ (១)ថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី២៥ និងកិច្ចប្រជុំពាក់ព័ន្ធ (25th SOMTC and Its Related Meetings)។ (២)កិច្ចប្រជុំថ្នាក់រដ្ឋ

មន្ត្រីអាស៊ាន SOMTC ត្រៀមសម្រាប់ AMMTC លើកទី១៩ និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ លោកជំទាវ **វីរក្ស វិជ្ជតា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តំណាងប្រធាន SOMTC កម្ពុជា និង អ្នកចូលរួម AMS ទាំង១០ប្រទេស រួមទាំងទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា+៣ ចិន ជប៉ុន កូរ៉េ សរុបចំនួន **១៨០រូប**។ **(៣)**បើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៩ (AMMTC) និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន SOMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស និងប្រទេសទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា+៣ ចិន ជប៉ុន កូរ៉េ អ្នកអង្កេតការណ៍ សរុបចំនួន **៥០០រូប**។ **(៤)**កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១ (AMMTC) និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន AMMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស និងប្រទេសទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា+៣ ចិន ជប៉ុន កូរ៉េ អ្នកអង្កេតការណ៍ ចំនួន **២៣០រូប**។ **(៥)**ក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា អំពីតួនាទី ភារកិច្ច របស់ក្រុមការងារកាត់ផ្តាច់បណ្តាញឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការរត់ពន្ធមនុស្ស និងអំពើជួញដូរមនុស្ស (DWG) នៃដំណើរការ Bali Process នៅទីក្រុងបាងកក ប្រទេសថៃ ចំនួន០១លើក។

៣-ឯកឧត្តមឧត្តមសេនីយ៍ទោ **តែ សុថារេត** អគ្គលេខាធិការរង ទៅចូលរួមកិច្ចប្រជុំ "Regional Consultation Workshops on Strengthening the Non-Punishment Principle in Trafficking in Persons Cases of Forced Criminality" នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ ដោយមានការចូលរួមពីបណ្តារប្រទេសចំនួន១២ (កម្ពុជា ឡាវ ហ្វីលីពីន ថៃ ភូមា ឥណ្ឌូនេស៊ី វៀតណាម ប្រ៊ុយណេ ម៉ាឡេស៊ី សាំងហ្គាពួរ ទីម័រឡេស អូស្ត្រាលី) និងអង្គការអន្តរជាតិភាគីពាក់ព័ន្ធដូចជា ASEAN Sectoral Bodies, AICHR, SOMTC, OHCHR, UNODC, IOM និងCSOs សរុបចំនួន ៤៨នាក់ ស្ត្រី ២៩នាក់។

**៥.** លោកស្រី វរសេនីយ៍ឯក **ថោង សុវត្ថិ** ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួម **កិច្ចសន្ទនាសិទ្ធិមនុស្សអាស៊ានលើកទី៧ និងពិធីប្រារព្ធខួបសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន** នៅទីស្នាក់ការលេខាធិការដ្ឋានអាស៊ាន នាទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ។

- **ខេត្តសៀមរាប៖** លោកស្រីស្នងការរងនគរបាលខេត្ត និងជាប្រធានក្រុមការងារកិច្ចការអនុវត្តច្បាប់ បានអញ្ជើញចូលរួមកិច្ចសន្ទនាថ្នាក់តំបន់ស្តីពី ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្រោមប្រធានបទ កិច្ចសហប្រតិបត្តិការទៅជាសកម្មភាព នៅប្រទេសឥណ្ឌូនេស៊ី ចំនួន ០១លើក។
- **ខេត្តស្វាយរៀង៖** បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការនគរបាលខេត្តតៃនិញ និងស្នងការនគរបាលខេត្តស្វាយរៀង និងត្បូងឃ្មុំ ក្នុងការទប់ស្កាត់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅខេត្តតៃនិញ ប្រទេសវៀតណាម ចំនួន ០១លើក ។

### ខ.២. ទស្សនកិច្ច

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** បានដឹកនាំគណៈប្រតិភូម្ចាស់ជំនួយនៃអង្គការគោរីតាសស្វីស ប្រចាំនៅកម្ពុជា ធ្វើទស្សនកិច្ចនៅមណ្ឌលទទួលពលករកំរៀង ច្រកទ្វារអន្តរជាតិដូង ច្រកទ្វារអន្តរជាតិផ្សារព្រំ ខេត្តបាត់ដំបង ព្រមទាំងបានពិនិត្យស្ថានភាពពលករ និងជួបសំណេះសំណាល ជាមួយពលករដែលត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃ។
- **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើទស្សនកិច្ចនៅមណ្ឌលថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស (TIP Center) ដែលគ្រប់គ្រងដោយ ក្រុមប្រឹក្សាអន្តរស្ថាប័នថ្នាក់ជាតិប្រឆាំងអំពើជួញដូរមនុស្ស ហ្វីលីពីន (IACAT) នៅប្រទេសហ្វីលីពីន។

## ២.៣. ជំនួបពិភាក្សា

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**

- ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតឱ្យលោកស្រី NELLIE GHUSAYINA ប្រធានបេសកកម្មនៃអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ប្រចាំកម្ពុជាចូលជួបសម្តែងការគួរសម និងពិភាក្សា អំពីលទ្ធផលការងារក្នុងកិច្ចសហប្រតិបត្តិការរវាង អង្គការ IOM និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ទីស្តីការក្រសួងមហាផ្ទៃ។

- លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជំនួបពិភាក្សាជាមួយ៖

១-លោកស្រី NELLIE GHUSAYINA ប្រធានបេសកកម្មប្រចាំនៅកម្ពុជា នៃអង្គការ IOM ប្រចាំនៅកម្ពុជា និងបានផ្តល់យោបល់តាមការស្នើសុំ ដើម្បីតម្រង់ទិសសកម្មភាពគម្រោងបន្តរបស់អង្គការ និងស្វែងយល់ ដកស្រង់បទពិសោធន៍ នៃការអនុវត្តគម្រោងកែលម្អសេវាសុខភាព សម្រាប់ជនទេសន្តរប្រវេសន៍ វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការ និងការវាយតម្លៃលទ្ធផលគម្រោងរបស់អង្គការ IOM និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលបានអនុវត្តកន្លងមក

២-តំណាងស្ថានទូតអាម៉េរិក ដើម្បីពិភាក្សាអំពីការបញ្ជូនរបាយការណ៍ឆ្លើយតបទៅក្រសួងការបរទេស សហរដ្ឋអាម៉េរិក

៣-អង្គការ IJM ស្តីពីការងារប្រយុទ្ធប្រឆាំងបទល្មើសជួញដូរពលកម្មឆ្លងដែន ដើម្បីតម្រង់ទិសគម្រោង និងស្តីពីការកសាងគម្រោងពង្រឹងសមត្ថភាព ដល់ គ.ខ.ប.ជ និងក្រុមការងារអន្តរមន្ទីរអង្គភាព នៃខេត្តគោលដៅទាំង៦ នៅទីស្តីការក្រសួងមហាផ្ទៃ

៤-អង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិ (WHI) លើការងារត្រៀមរៀបចំសិក្ខាសាលា ស្តីពីការថែទាំដែលយល់ដឹងពីការប៉ះទង្គិចផ្លូវចិត្តកុមារ ដែលរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ»និងបានផ្តល់យោបល់តាមការស្នើសុំដើម្បីតម្រង់ទិសសកម្មភាពគម្រោងបន្តរបស់អង្គការ នៅបន្ទប់ការងារ នៃទីស្តីការក្រសួងមហាផ្ទៃ

៥-ប្រតិភូក្រសួងការបរទេសអូស្ត្រាលី ដឹកនាំដោយ លោកស្រី Lynn Bell ជា Australian Ambassador to Counter Modern Slavery អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៦-លោកស្រី Sonja Loosli នាយិកាប្រចាំកម្ពុជា នៃអង្គការការីតាសស្វីស ដើម្បីពិភាក្សាការងារដើម្បីស្វែងយល់បន្ថែមអំពីស្ថានភាពទេសន្តរប្រវេសន៍នៅកម្ពុជា ជាពិសេសនៅតំបន់គោលដៅនៃគម្រោង ដែលមានមណ្ឌលទទួលពលករកំរៀងជាទីតាំងស្នូលក្នុងការអនុវត្តសកម្មភាព និងបានផ្តល់យោបល់តាមការស្នើសុំដើម្បីតម្រង់ទិសសកម្មភាពគម្រោងបន្តរបស់អង្គការ នៅបន្ទប់ការងារ នៃទីស្តីការក្រសួងមហាផ្ទៃ

៧-ឯកឧត្តម **ងួន រតនៈ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ស្តីពីគម្រោងកា រងារដឹកនាំចុះតាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ នៃខេត្តជាប់ព្រំដែនថៃ នៅទីស្តីការក្រសួងមហាផ្ទៃ

៨-ប្រតិភូសាធារណៈរដ្ឋឥណ្ឌូនេស៊ី ដឹកនាំដោយ ឧត្តមសេនីយ៍ទោ **ស្លាម៉ិត ហាឌី ស៊ូប្រាប់តូយ៉ូ** តំណាងប្រធានការិយាល័យវិទ្យាស្ថានអប់រំ និងបណ្ដុះបណ្ដាលមន្ត្រីជាន់ខ្ពស់នគរបាលជាតិឥណ្ឌូនេស៊ី ដើម្បីចែករំលែកបទពិសោធន៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

៩-ប្រធានអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ពិភាក្សាការងារ ស្តីពីកិច្ចសហការក្នុងការអនុវត្តគម្រោងពង្រឹងសមត្ថភាព គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) ដើម្បីការពារពលករចំណាកស្រុក

១០-តំណាងក្រុមហ៊ុន YHS Cambodia ដឹកនាំដោយ លោកស្រី **ហេង សុទ្ធារី** អគ្គនាយិកា ដើម្បីពិនិត្យ និងពិភាក្សាការងារសម្រាប់កិច្ចសហការក្នុងការអនុវត្តសកម្មភាពមនុស្សធម៌ និងការងារសង្គម របស់សមាគមនារីក្រសួងមហាផ្ទៃ នៅបន្ទប់ប្រជុំទីស្ដីការក្រសួងមហាផ្ទៃ

១១-តំណាង អង្គការសម្ព័ន្ធចាប់ដៃ ផ្ដល់ការណែនាំសម្រាប់ការរៀបចំសិក្ខាសាលា ស្ដីពី«កិច្ចពិភាក្សាពិគ្រោះយោបល់ថ្នាក់ជាតិ ក្នុងការលើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការអនុវត្តនីតិវិធីសំណងរដ្ឋប្បវេណី» នៅបន្ទប់ប្រជុំទីស្ដីការក្រសួងមហាផ្ទៃ

១២-លោកស្រី **គ្រីស្ទីន ប៉ាកកូ** នាយិកាប្រតិបត្តិអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ប្រចាំនៅប្រទេសស្រីលង្កា ដើម្បីពិភាក្សាការងារត្រៀមរៀបចំទស្សនៈកិច្ច របស់គណៈប្រតិភូស្រីលង្កា នៅទីស្ដីការក្រសួងមហាផ្ទៃ។

១៣-គណៈប្រតិភូប្រទេសស្រីលង្កា ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ទៅវិញទៅមក លើការងារពាក់ព័ន្ធនឹងកតិកាសញ្ញាពិភពលោក GCM នៅទីស្ដីការក្រសួងមហាផ្ទៃ។

១៤-គណៈប្រតិភូប្រទេសបង់ក្លាដេស ដែលមកបំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសកម្ពុជា ជួបសម្ដែងការគួរសម និងចែករំលែកបទពិសោធន៍ អំពីកិច្ចខិតខំប្រឹងប្រែងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្ដីការក្រសួងមហាផ្ទៃ។

១៥-តំណាងអង្គការ AusCam ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

១៦-តំណាងអង្គការ HAGAR ដើម្បីប្រជុំពិភាក្សាអំពី ការត្រៀមរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៥ និងកិច្ចពិគ្រោះយោបល់លើកម្មវិធី ការផ្ដល់ភាពអង់អាច ការស្តារឡើងវិញជនរងគ្រោះ និងការបង្ការទប់ស្កាត់

១៧-ប្រតិភូនៃអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ដឹកនាំដោយលោកស្រី Nellie Ghusayni ប្រធានបេសកកម្ម នៃអង្គការ IOM ប្រចាំនៅកម្ពុជា ស្ដីពីការស្វែងរកកិច្ចសហការបន្ថែម រវាងរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមរដ្ឋជ័យលាភីនៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្ដីពីចំណាកស្រុកដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)។

▪ **ខេត្តកំពង់ធំ៖** ប្រធានលេខាធិការដ្ឋាន និងមន្ត្រីបង្គោល បានជួបពិភាក្សាជាមួយតំណាងអង្គការ IJM ស្ដីពីកិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

▪ **ខេត្តសៀមរាប៖** តំណាងលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយ៖ **១**/អង្គការ ARM ស្ដីពីការស្វែងយល់អំពីការស្នាក់នៅ ការថែទាំ និងតម្រូវការចាំបាច់នានា ដល់ជនរងគ្រោះក្នុងមណ្ឌល។ **២**/តំណាងមន្ទីរអប់រំ យុវជននិងកីឡា និងអង្គការមូលនិធិអេ២១ ស្ដីពីការរៀបចំផែនការចុះអប់រំផ្សព្វផ្សាយ អំពីការបង្ការទប់ស្កាត់គ្រប់រូបភាព និងការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដល់សិស្សនិស្សិត នៅតាមសាកលវិទ្យាល័យ វិទ្យាល័យ និងប្រជាពលរដ្ឋនៅតាមសហគមន៍។ **៣**/ អង្គការមូលនិធិអេ២១ អង្គការសម្ព័ន្ធចាប់ដៃ និងក្រុមយុវជនស្ម័គ្រចិត្ត ស្ដីពីការអនុវត្តសកម្មភាពរួមគ្នារវាងគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត និងអង្គការ ការផ្ដល់សេវាដល់ករណីរំលោភបំពានតាមអនឡាញ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការលើកកម្ពស់ដល់យុវជនស្ម័គ្រចិត្ត ក្នុងរៀបចំវេទិកាសាធារណៈពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ។ **៤**/អង្គការទស្សនៈពិភពលោក ស្ដីពីយន្តការនៃការរាយការណ៍ និងការបញ្ជូននៅសហគមន៍ដើម្បីចុះផ្សព្វផ្សាយបន្តតាមឃុំ។ **៥**/តំណាងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មន្ទីរកិច្ចការនារី រដ្ឋបាលស្រុកស្វាយលើ ស្រុកអង្គរធំ ស្រុកស្រីស្នំ និងស្រុកបន្ទាយស្រី បានទទួលជួបពិភាក្សាការងារ និងផ្ដល់បទសម្ភាសន៍ប្រមូលធាតុចូល ជាមួយអង្គការភ្លែនអន្តរជាតិ អំពីស្ថានភាពទូទៅរបស់គ្រួសារពលករ

ចំណាកស្រុក ដែលវិលត្រឡប់មកវិញ បានចំនួន ០៨លើក។ ៦/ តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារជាមួយអង្គការ ILO ស្តីពីកិច្ចគាំពារផ្នែកច្បាប់ដល់ពលករលើទូកនេសាទ បានចំនួន ១លើក តាមរយៈប្រព័ន្ធបញ្ចូនរូបភាព Zoom។ ៧/ ស្នងការដ្ឋាននគរបាលខេត្ត បានជួបប្រជុំពិភាក្សា ស្តីពី Hotline Group Meeting លើកទី១៧ ជាមួយឯកឧត្តមអគ្គកុងស៊ុលសាធារណៈរដ្ឋកូរ៉េប្រចាំខេត្តសៀមរាប មានការចូលរួមពីអស់លោក-លោកស្រីប្រធានកុងស៊ុលប្រចាំស្ថានទូត បានចំនួន ០១លើក។ ៨/ តំណាងលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារស្តីពី ការអនុវត្តសកម្មភាពរួមគ្នារវាង គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត និងអង្គការសម្ព័ន្ធចាប់ដៃ , បានទទួលជួបការសម្តែងការគួរសម និងពិភាក្សាការងារជាមួយអង្គការ PLAN អន្តរកម្មវិធីកិច្ចការពារជំនាន់ថ្មី កម្មវិធីរៀនពេញមួយជីវិត និងកម្មវិធីក្មេងស្រីជាអ្នកដឹកនាំ, បានទទួលជួបពិភាក្សាការងារជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ការសិក្សានិងពិគ្រោះយោបល់ក្នុងការកសាងគម្រោងពង្រឹងសមត្ថភាព ដល់ គ.ខ.ប.ជ និងក្រុមការងារបច្ចេកទាំង៦និង ការអនុវត្តសកម្មភាពរួមគ្នា ដើម្បីពង្រឹងសមត្ថភាព និងផ្លាស់ប្តូរបទពិសោធន៍ បានចំនួន ៣លើក នៅសាលាខេត្ត, បានទទួលប្រជុំពិភាក្សាជាមួយអង្គការមជ្ឈមណ្ឌលធនធានស្ត្រី ស្តីពី ការរៀបចំទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១១៤ ឆ្នាំ២០២៥ ដោយបានធ្វើការរំលេចនូវសារអប់រំពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងបានទទួលជួបពិភាក្សាជាមួយអង្គការមូលនិធិអន្តរជាតិហាការ ស្តីពី ការអនុវត្តគម្រោងក្នុងផែនការសកម្មភាពប្រចាំឆ្នាំ។ ៩/ លោកនាយករងរដ្ឋបាលសាលាខេត្ត និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានទទួលជួបផ្តល់បទសម្ភាសន៍ជាមួយអ្នកវាយតម្លៃឯករាជរបស់អង្គការអន្តរជាតិខាងការងារ (ILO) អំពីការអនុវត្តគោលនយោបាយជាតិ ស្តីពី មុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥។

▪ **ខេត្តកំពង់ចាម៖** ប្រធានលេខាធិការដ្ឋាន ដឹកនាំតំណាងក្រុមការងារជំនាញទាំង ៦ នៃ គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំជំនួបពិភាក្សាជាមួយ អង្គការ IJM ដើម្បីពិគ្រោះយោបល់ក្នុងការកសាងគម្រោងពង្រឹងសមត្ថភាពដល់ គ.ខ.ប.ជ និងគណៈប្រតិភូមកពីស្ថានទូតអាម៉េរិក ដើម្បីស្វែងយល់ពីស្ថានភាពពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម និងដើម្បីការពារពលករក្នុងបរិបទទេសន្តរប្រវេសន៍។

▪ **ខេត្តក្រចេះ៖** ប្រធានលេខាធិការដ្ឋាន បានទទួលជួបពិភាក្សាការងារជាមួយ អង្គការសកម្មភាពដើម្បីកុមារ (APLE) ដើម្បីប្រមូលទិន្នន័យ និងលទ្ធផលគម្រោងរយៈពេល០៣ឆ្នាំ(២០២៣-២០២៥)។

## គ. ការខារសម្របសម្រួល

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយអង្គការដៃគូ បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗ ដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិទាំងបួន (ការបង្ការទប់ស្កាត់ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងអំពើជួញដូរមនុស្ស ការការពារ និងជួយជនរងគ្រោះ និងការពង្រឹងកិច្ចសហប្រតិបត្តិការ) សរុបចំនួន **៦៣៣**លើក ដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាពចូលរួមរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | ចំនួនលើក |
|---|---|
| **ថ្នាក់ជាតិ** | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ១៨៦ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥២ |
| ក្រសួងអប់រំ យុវជន និងកីឡា | ២៨ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤៣ |
| ក្រសួងព័ត៌មាន | ០៩ |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១១ |

| | |
|---|---|
| អគ្គស្នងការដ្ឋាននគរបាលជាតិ | ៩១ |
| **សរុបថ្នាក់ជាតិ** | **៤២០ លើក** |
| **ថ្នាក់ក្រោមជាតិ** | |
| រាជធានីភ្នំពេញ | ១០ |
| ខេត្តកណ្តាល | ០៦ |
| ខេត្តឧត្តរមានជ័យ | ០៣ |
| ខេត្តបន្ទាយមានជ័យ | ១៤ |
| ខេត្តបាត់ដំបង | ២៦ |
| ខេត្តប៉ៃលិន | ២៨ |
| ខេត្តកោះកុង | ០៩ |
| ខេត្តសៀមរាប | ២៤ |
| ខេត្តកំពង់ធំ | ០៣ |
| ខេត្តពោធិ៍សាត់ | ០៣ |
| ខេត្តក្រចេះ | ០៨ |
| ខេត្តកំពង់ចាម | ១៣ |
| ខេត្តតាកែវ | ០៣ |
| ខេត្តមណ្ឌលគិរី | ០៦ |
| ខេត្តត្បូងឃ្មុំ | ០៥ |
| ខេត្តកំពង់ស្ពឺ | ០៤ |
| ខេត្តស្វាយរៀង | ០៤ |
| ខេត្តព្រៃវែង | ១៣ |
| ខេត្តកំពង់ឆ្នាំង | ០៩ |
| ខេត្តព្រះសីហនុ | ០៤ |
| ខេត្តកំពត | ០៣ |
| ខេត្តកែប | ០៣ |
| ខេត្តព្រះវិហារ | ០៣ |
| ខេត្តរតនគិរី | ០៦ |
| ខេត្តស្ទឹងត្រែង | ០៣ |
| **សរុបថ្នាក់ក្រោមជាតិ** | **២១៣ លើក** |
| **សរុបរួម ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | **៦៣៣ លើក** |

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ...ដែលធ្វើឱ្យការបូកសរុបទាំងបរិមាណ និងគុណភាពមិនទាន់ស៊ីចង្វាក់គ្នា

- ត្រូវការរៀបចំកែលម្អ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ដោយយកចិត្តទុកដាក់បន្ថែមលើការជួញដូរ ដែលពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ ដែលមានភាពស្មុគស្មាញ ដើម្បីឱ្យការធ្វើសកម្មភាព និងទិន្នន័យមានសង្គតិភាព និងកាន់តែជាក់លាក់
- ជនល្មើសមានកលល្បិចខ្ពស់ ក្នុងការធ្វើសកម្មភាពខុសច្បាប់ ជាប្រព័ន្ធ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់ ជាពិសេស នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ខ្វះការផ្សព្វផ្សាយអំពីលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលឆ្លើយតបទៅនឹងការចោទប្រកាន់ ជាពិសេស ករណីជនបរទេស
- ខ្វះវិធីសាស្ត្រសមស្រប និងសង្គតិភាពនៃសារអប់រំ ផ្សព្វផ្សាយ និងគម្រោងសកម្មភាពនានា ដែលអាចធ្វើឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរ គ្រប់ទម្រង់ ទទួលបានប្រសិទ្ធភាព ដែលអាចឱ្យមនុស្សផ្លាស់ប្តូរឥរិយាបទ មិនធ្វើទេសន្តរប្រវេសន៍ ដោយប្រថុយប្រថាន និងគ្រោះថ្នាក់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសឆបោកតាមអនឡាញ មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ជនល្មើស និងជនរងគ្រោះ អាចជាមនុស្សតែមួយ ដែលធ្វើឱ្យការកំណត់អត្តសញ្ញាណ មានការលំបាក និងប្រើពេលយូរ ។

ករណីឆបោកតាមអនឡាញ មានពាក់ព័ន្ធនឹងសកម្មភាពជួញដូរមនុស្ស និងបទល្មើសទ្រហ្មទណ្ឌផ្សេងទៀត ជាច្រើនទម្រង់ មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត ការបង្ខំឱ្យធ្វើការងារខុសច្បាប់ គំនុំសងសឹកទំនាស់ការងារ អំពើហិង្សា ឃាតកម្មការងារដោយបង្ខំ ខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលត្រូវយកចិត្តទុកដាក់ខ្ពស់ និងចាំបាច់ត្រូវមានការចូលរួមពីបណ្តាក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចៀសភាពរងគ្រោះ និងកាត់បន្ថយ សក្តានុពលនៃបទល្មើស។ ការបង្កើនការបង្ការទប់ស្កាត់ នឹងអាចការពារ មនុស្សគ្រប់វ័យ តាំងពីដំណាក់កាលដំបូង ដោយមិនរង់ចាំបទល្មើសកើតឡើង និងមានអ្នករងគ្រោះ ទើបធ្វើការស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប សង្គ្រោះ ផ្តន្ទាទោស ផ្តល់កិច្ចការពារ... ដែលជាខាតបង់ដ៏ច្រើនលើសលុប ទាំងធនធានមនុស្ស ធនធានថវិកា កេរ្តិ៍ឈ្មោះ កិត្តិយស សេចក្តីថ្លៃថ្នូរ សុខភាពរាងកាយ ផ្លូវចិត្ត រហូតដល់អាយុជីវិត ពេលវេលា ទំនាក់ទំនងសង្គម និង ជាឧបសគ្គក្នុងការអភិវឌ្ឍគ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រមក្នុងការទទួលខុសត្រូវតាមវិស័យជំនាញនីមួយៗ ក៏ដូចជាការកសាងទំនុកចិត្តរវាងគ្នាដើម្បីបង្កើតជាបណ្តាញសមត្ថកិច្ចដ៏រឹងមាំការពារសុវត្ថិភាពប្រជាពលរដ្ឋ និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេស

ពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់ មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីចាត់តាំងមន្ត្រីឱ្យទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ដើម្បីទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល ការងាររបាយការណ៍ ការងារផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងទទួលបានការបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចដែល ឆ្លើយតបទៅនឹងការងារប្រឆាំងអំពើជួញដូរមនុស្ស
- ពង្រឹងរបបប្រជុំ ឱ្យបានទៀងទាត់ ដើម្បីបូកសរុប និងតាមដានការងារលទ្ធផលការងារ ដែលអនុវត្តផ្អែកលើផែនការ និងយុទ្ធសាស្ត្រដែលបានកំណត់ ពង្រឹងប្រសិទ្ធភាពឬកែលម្អចំណុចខ្វះខាត ក្នុងក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងផ្ញើមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឱ្យបានទាន់ពេលវេលា។

## V. ទិសដៅបន្ត ឆ្នាំ ២០២៦

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅអនុវត្តសម្រាប់ឆ្នាំ២០២៦ ដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយជាមួយបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន ដើម្បីបន្តអនុវត្តវិធានការបង្ការទប់ស្កាត់ ដែលឈានដល់ការផ្លាស់ប្តូរឥរិយាបថសង្គម ប្រឆាំងការជួញដូរមនុស្ស តាមរយៈការបង្កើតសកម្មភាពរួមគ្នា ដែលបង្កើនភាពជឿជាក់ពីប្រជាពលរដ្ឋ ជាពិសេសក្រុមជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីប្រទេសថៃ និងក្រុមប្រជាជន ដែលភៀសសឹក និងបែងចែកការកិច្ច ពង្រាយកម្លាំងអនុវត្ត ឆ្ពោះទៅកាន់តំបន់គោលដៅជាអាទិភាព

២. ត្រៀមវាយតម្លៃ ពាក់កណ្តាលអណត្តិនៃ «ផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨» និងរៀបចំកែលម្អ ផែនការសកម្មភាព ពាក់កណ្តាលអណត្តិទី២ នៃផែនការយុទ្ធសាស្ត្រ ដោយប្រើក្របខណ្ឌ នៃឯកសារ តាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL)

៣. ត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីចូលរួមកិច្ចប្រជុំ ខមមីត រវាងក្រុមប្រទេសក្នុងមហាអនុតំបន់មេគង្គ នៅសាធារណរដ្ឋប្រជាមានិតឡាវ ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកទិន្នន័យ មតិយោបល់ ក្នុងការអនុវត្តផែនការ SPA 5 ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងមហាអនុតំបន់មេគង្គ

៤. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីពាក់ព័ន្ធ ពង្រឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារអន្តរក្រសួងស្ថាប័នទាំង០៦ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៥. ចូលរួមកិច្ចប្រជុំបច្ចេកទេស កិច្ចប្រជុំកំពូល និងកិច្ចប្រជុំផ្សេងៗ នៅថ្នាក់តំបន់ និងជាអន្តរជាតិ ព្រមទាំងត្រៀមការចូលរួមវាយតម្លៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (IMRF2) នៅអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក

៦. បន្តពង្រីកការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព ការបញ្ជ្រាបកិច្ចពិភាក្សា តាមវេទិកាសាធារណៈ នៃគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព តាមព្រឹត្តិការណ៍នានា កម្មវិធីបុណ្យជាតិ យុទ្ធនាការ លើកកម្ពស់សុវត្ថិភាពឌីជីថល (១០កុម្ភៈ) ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស (២០សីហា) ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (១២ធ្នូ)ព្រមទាំងផលិតសម្ភារៈ ឧបករណ៍ អប់រំផ្សព្វផ្សាយ គ្រប់ប្រភេទ ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្សគ្រប់ទម្រង់

៧. បណ្ដុះបណ្ដាលមន្ត្រីពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ដីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្ដល់សេវាសមស្រប តាមឯកសារដែលបានកែលម្អឡើងវិញ និងបញ្ជ្រាបការយល់ដឹងដល់មន្ត្រីស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ដើម្បីអនុវត្តសកម្មភាពគាំពារជនរងគ្រោះ ឲ្យមានសង្គតភាព

៨. លើកកម្ពស់គុណភាពនៃការផ្ដល់សេវាគាំពារជនរងគ្រោះ ដោយអំពើជួញដូរមនុស្សឲ្យកាន់តែប្រសើរឡើង

៩. ពង្រឹងការតាមដានសុវត្ថិភាពពលករ ដែលត្រូវបានបញ្ជូនទៅធ្វើការនៅក្រៅប្រទេស តាមរយៈក្រុមហ៊ុនឯកជន ដោយអនុវត្តឲ្យបានម៉ឺងម៉ាត់តាមគោលនយោបាយជាតិ ក្នុងការការពារឧត្តមប្រយោជន៍ពលករកម្ពុជា

១០. ការពង្រឹងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ៖

- ពិនិត្យ លទ្ធភាព ក្នុងការធ្វើវិសោធនកម្ម ច្បាប់ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបនឹងភាពចាំបាច់
- ពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ និងនីតិវិធីក្នុងការទទួលបានសំណងបដិទានរបស់ជនរងគ្រោះ

១១. បន្តដោះស្រាយ ឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីបង្កើនប្រាក់ចំណូល តាមវិធីសាស្ត្រ ជំនាញ និងគោលនយោបាយ នៃវិស័យពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនភៀសសឹក

១២. ពង្រឹងការគ្រប់គ្រងការវិលត្រឡប់របស់ពលករកម្ពុជាពីប្រទេសថៃ ដែលនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយបង្កឱកាសឲ្យពលករទាំងនោះ បានទទួលការអប់រំណែនាំ ព័ត៌មាន និងសេវាចាំបាច់មួយចំនួន នៅមណ្ឌលទទួលពលករកំរៀង ឬមណ្ឌលសំចតប៉ោយប៉ែត ឬក្រុមមន្ត្រីដែលមានការចាត់តាំងតាមបណ្ដាច្រកដើម្បីបានប្រមូលទិន្នន័យ និងក្ដាប់បាននូវសំណូមពរ និងសភាពការណ៍ប្រែប្រួលនានា ក្នុងប្រទេសគោលដៅ

១៣. បន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្ដាប្រទេសគោលដៅ ព្រមទាំងដៃគូពាក់ព័ន្ធ ដើម្បីការពារ លើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗរបស់ពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេស

១៤. បន្តសិក្សា និងពង្រីកទីផ្សារការងារដែលមានលក្ខខណ្ឌការងារល្អ នៅតាមបណ្ដាប្រទេសអភិវឌ្ឍ ដើម្បីបង្កឱកាសដល់យុវវ័យដែលមានតម្រូវការការងារ

១៥. បន្តសិក្សាស្រាវជ្រាវ និងរៀបចំចងក្រង សេចក្តីព្រាងក្របខណ្ឌគោលនយោបាយ និងរៀបចំគោលការណ៍ណែនាំ ស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារក្នុងវិស័យការងារប្រកបដោយគ្រោះថ្នាក់

១៦. បន្តពង្រឹងសមត្ថភាព និងវិធានការនានា ដល់មន្ត្រី ម្ចាស់រោងចក្រសហគ្រាស សហជីព និងភាគីពាក់ព័ន្ធស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ

១៧. បន្តចុះត្រួតពិនិត្យវាយតម្លៃលក្ខខណ្ឌការងារ និងប្រភេទការងារសម្រាប់កម្មករនិយោជិតវ័យក្មេង នៅតាមទីកន្លែងការងារ

១៨. បន្តកិច្ចសហការរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ

១៩. បង្កើនការផ្សព្វផ្សាយ តាមរយៈមន្ទីរព័ត៌មានរាជធានី ខេត្ត ជាពិសេសខេត្តដែលនៅជាប់ព្រំដែន និងស្ថាប័នពាក់ព័ន្ធ អំពីព័ត៌មានទាន់ហេតុការណ៍ ដើម្បីសុវត្ថិភាពប្រជាពលរដ្ឋ គោលនយោបាយជាតិ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល បញ្ហាទេសន្តរប្រវេសន៍ និងការប្រុងប្រយ័ត្នអំពើជួញដូរមនុស្ស ឆ្លងកាត់ព្រំដែន ចៀសវាងការធ្វើចំណាកស្រុកដោយប្រថុយប្រថានជាដើម

២០. ជំរុញឱ្យមានការចូលរួមផលិតមាតិកាសំខាន់ៗឱ្យបានច្រើនទាក់ទងនឹងបញ្ហាទេសន្តរប្រវេសន៍

២១. រៀបចំជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល ស្តីពីទេសន្តរប្រវេសន៍ ជាមួយអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាផ្សេងៗ ក៏ដូចជាមន្ត្រីព័ត៌មាន ដើម្បីជំរុញការផ្សព្វផ្សាយបន្តឱ្យមានប្រសិទ្ធភាព ។

ថ្ងៃ អង្គារ ១កើត ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កម្ភៈ ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**“ដើម្បីគោរពជូនជាសេចក្តីរាយការណ៍”**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ គ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**“ដើម្បីជូនជ្រាប”**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

(ឧបសម្ព័ន្ធទី ១) លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំ ឆ្នាំ២០២៥)
គិតពីថ្ងៃទី ០១-០១-២០២៥ ដល់ថ្ងៃទី ៣១-១២-២០២៥

| ល.រ | ប្រភេទបទល្មើស | មាត្រា | ផ្ទន្ទាទោស | ករណី | ជនល្មើស | | | | ជនរងគ្រោះ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | រួម | ស្រី | បរទេស | | សរុប | | -១៥ | | ១៥-១៧ | | ១៨+ | | នីតិវិធី | | |
| | | | | | | | រួម | ស្រី | រួម | ស្រី | រួម | ស្រី | រួម | ស្រី | រួម | ស្រី | សង្គមកិច្ច | អន្តោប្រវេសន៍ | គ្រួសារ |
| I | **ជួញដូរមនុស្ស** | | | 128 | 209 | 15 | 17 | | 609 | 247 | 27 | 10 | 33 | 14 | 549 | 223 | 63 | 30 | 516 |
| 1 | ការនាំយកអនីតិជន ជាអាទិ៍ចេញដោយមិនស្របច្បាប់ | មាត្រា៩ | ២-៥ | 4 | 6 | 2 | | | 5 | 4 | 4 | 3 | 1 | 1 | | | | | 5 |
| 2 | ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | មាត្រា១០ | ៧-១៥/១៥-២០ | 3 | 4 | 2 | | | 4 | 4 | | | 1 | 1 | 3 | 3 | 3 | | 1 |
| 3 | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | មាត្រា១១ | ៧-១៥/១៥-២០ | 62 | 89 | 6 | 7 | | 346 | 159 | 14 | 6 | 13 | 8 | 319 | 145 | 30 | | 316 |
| 4 | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | មាត្រា១២ | ៧-១៥/១៥-២០ | 3 | 4 | | 2 | | 25 | | 3 | | 3 | | 19 | | 3 | 22 | |
| 5 | អំពើលក់ដូរមនុស្ស | មាត្រា១៤ | ២-៥ | 5 | 12 | | 4 | | 11 | | | | | | 11 | | 4 | | 7 |
| 6 | អំពើលក់ដូរមនុស្សដោយមានគោលដៅ | មាត្រា១៥ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 7 | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | មាត្រា១៦ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 8 | ការដឹកជញ្ជូនដោយមានគោលដៅ | មាត្រា១៧ | ៧-១៥/១៥-២០ | 13 | 38 | | 4 | | 25 | 4 | | | 6 | | 19 | 4 | 17 | | 8 |
| 9 | អំពើនាំឆ្លងដែន | មាត្រា១៨ | ៧-១៥/១៥-២០ | 3 | 4 | 2 | | | 8 | 1 | | | | | 8 | 1 | | 1 | 7 |
| 10 | ការទទួលយកមនុស្សដោយមានគោលដៅ | មាត្រា១៩ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 11 | ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | មាត្រា២០ | ២-៥/៥-១០ | 32 | 49 | 3 | | | 182 | 72 | 6 | 1 | 6 | 1 | 170 | 70 | 6 | 7 | 169 |
| 12 | ការទិញពេស្យាចារកុមារ | មាត្រា៣៤ | ២-៥/៧-១៥ | 3 | 3 | | | | 3 | 3 | | | 3 | 3 | | | | | 3 |
| 13 | អំពើអូសទាញពេស្យាចារកុមារ | មាត្រា៣៥ | ២-៥/៥-១០ | | | | | | | | | | | | | | | | |
| 14 | ការអោយខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | មាត្រា៣៦ | ៥-១០ | | | | | | | | | | | | | | | | |
| 15 | កិច្ចសន្យានៃអំពើពេស្យាចារកុមារ | មាត្រា៣៧ | ៥-១០ | | | | | | | | | | | | | | | | |
| 16 | កិច្ចសន្យាសំរាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | មាត្រា៤៥ | | | | | | | | | | | | | | | | | |
| II | **អាជីវកម្មផ្លូវភេទ** | | | 144 | 201 | 38 | 26 | 1 | 385 | 377 | 122 | 121 | 137 | 137 | 126 | 119 | 268 | | 117 |
| 1 | ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | មាត្រា២១ | ៣-៥/៥-១០ | 3 | 9 | | 7 | | 5 | 1 | | | | | 5 | 1 | 4 | | 1 |
| 2 | ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | មាត្រា២២ | ១ជីវិត | 3 | 5 | | 5 | | 3 | | | | | | 3 | | | | 3 |
| 3 | អំពើអូសទាញសញ្ចារកម្ម | មាត្រា២៤ | ១ថ្ងៃ-៦ថ្ងៃ | | | | | | | | | | | | | | | | |
| 4 | សញ្ចារកម្ម | មាត្រា២៦ | ២-៥ | 6 | 7 | 3 | 1 | 1 | 21 | 21 | | | 9 | 9 | 12 | 12 | 21 | | |
| 5 | ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | មាត្រា២៧ | ៥-១០ | 2 | 3 | 1 | 2 | | 24 | 24 | | | | | 24 | 24 | 24 | | |
| 6 | សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | មាត្រា២៨ | ៧-១៥ | 21 | 45 | 33 | | | 207 | 207 | 18 | 18 | 123 | 123 | 66 | 66 | 207 | | |
| 7 | សញ្ចារកម្មដោយមានការធ្វើទារុណកម្ម | មាត្រា២៩ | ១០-២០ | | | | | | | | | | | | | | | | |
| 8 | ការដឹកនាំពេស្យាចារ | មាត្រា៣០ | ២-៥ | | | | | | | | | | | | | | | | |
| 9 | ការដឹកនាំគ្រឹះស្ថានពេស្យាចារ | មាត្រា៣១ | ២-៥ | 1 | 2 | | 2 | | 7 | 7 | | | | | 7 | 7 | 7 | | |
| 10 | ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | មាត្រា៣២ | ២-៥ | | | | | | | | | | | | | | | | |
| 11 | បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | មាត្រា៣៣ | ៧-១៥ | | | | | | | | | | | | | | | | |
| 12 | រូបភាព និងសម្ភារៈអាសអាភាស | មាត្រា៣៩ | ៧ថ្ងៃ-១ខែ/១ខែ-១ឆ្នាំ | 11 | 22 | | 7 | | 10 | 10 | | | 1 | 1 | 9 | 9 | | | 10 |
| 13 | រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | មាត្រា៤១ | ២-៥/៥-១០/១០-២០ | 7 | 10 | 1 | | | 9 | 9 | 5 | 5 | 4 | 4 | | | | | 9 |
| 14 | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | មាត្រា៤២ | ៥-១០ | 72 | 80 | | 2 | | 74 | 73 | 74 | 73 | | | | | | | 74 |
| 15 | អំពើអាសគ្រាមនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | មាត្រា៤៣ | ១-៣ | 18 | 18 | | | | 25 | 25 | 25 | 25 | | | | | 5 | | 20 |
| | **សរុបរួម** | | | 272 | 410 | 53 | 43 | 1 | 994 | 624 | 149 | 131 | 170 | 151 | 675 | 342 | 331 | 30 | 633 |

(ឧបសម្ព័ន្ធទី ២)

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ
នាយកដ្ឋានកិច្ចការបច្ចេកទេស និងទំនើបកម្មរដ្ឋបាលតុលាការ
លេខ................កយ.បទ/៧៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ជំណាក់កាលស៊ើបសួរ-បទល្មើសជួញដូរមនុស្ស
## ប្រចាំឆ្នាំ២០២៥ (ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥)

| ល.រ | ប្រភេទបទល្មើស | មាត្រា | សំណុំរឿង: សល់ពីមុន | សំណុំរឿង: ចូលថ្មី | សំណុំរឿង: សរុប 6=4+5 | ជនរងគ្រោះ: សរុបរួម 7=8+10+12 | ជនរងគ្រោះ: នីតិជន សរុប | ជនរងគ្រោះ: នីតិជន ស្រី | ជនរងគ្រោះ: អនីតិជន សរុប | ជនរងគ្រោះ: អនីតិជន ស្រី | ជនរងគ្រោះ: ជនបរទេស សរុប | ជនរងគ្រោះ: ជនបរទេស ស្រី | ជនត្រូវចោទ: សរុបរួម 14=15+17+19 | ជនត្រូវចោទ: នីតិជន សរុប | ជនត្រូវចោទ: នីតិជន ស្រី | ជនត្រូវចោទ: អនីតិជន សរុប | ជនត្រូវចោទ: អនីតិជន ស្រី | ជនត្រូវចោទ: ជនបរទេស សរុប | ជនត្រូវចោទ: ជនបរទេស ស្រី | ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ: ចំនួនរឿង | ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ: មនុស្ស សរុប | ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ: មនុស្ស ស្រី | រឿងចាត់ការរួច: បញ្ជូនរឿងទៅជំនុំជម្រះ | រឿងចាត់ការរួច: លើកលែងចោទប្រកាន់ | រឿងចាត់ការរួច: បញ្ចូលរឿង | រឿងចាត់ការរួច: ផ្ញើរសមត្ថកិច្ច | រឿងចាត់ការរួច: សរុប 28=24+...+27 | រឿងកំពុងចាត់ការ 29=6-28 | បណ្តឹងឧទ្ធរណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 1 | ការនាំយកចេញដោយមិនស្របច្បាប់ | | 3 | 16 | 19 | 13 | 9 | 4 | 3 | 2 | 1 | 0 | 29 | 18 | 6 | 9 | 2 | 2 | 0 | 0 | 0 | 0 | 10 | 0 | 0 | 0 | 10 | 9 | 0 |
| 2 | ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | | 5 | 6 | 11 | 3 | 0 | 0 | 2 | 2 | 1 | 0 | 23 | 21 | 5 | 0 | 0 | 2 | 0 | 0 | 0 | 0 | 6 | 0 | 0 | 0 | 6 | 5 | 0 |
| 3 | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេញប្រវ័ញ្ច | | 2 | 1 | 3 | 59 | 16 | 6 | 0 | 0 | 43 | 25 | 5 | 3 | 2 | 0 | 0 | 2 | 0 | 0 | 0 | 0 | 3 | 0 | 0 | 0 | 3 | 0 | 0 |
| 4 | ផលិតរូបភាព និងសម្ភារអាសអាភាស | | 10 | 28 | 38 | 39 | 27 | 23 | 12 | 12 | 0 | 0 | 41 | 36 | 1 | 5 | 1 | 0 | 0 | 0 | 0 | 0 | 29 | 1 | 0 | 0 | 30 | 8 | 0 |
| 5 | អំពើលក់-ដូរមនុស្ស | | 3 | 23 | 26 | 46 | 0 | 0 | 0 | 0 | 46 | 8 | 109 | 71 | 2 | 0 | 0 | 38 | 2 | 0 | 0 | 0 | 8 | 0 | 0 | 0 | 8 | 18 | 0 |
| 6 | អំពើលក់-ដូរមនុស្សដោយមានគោលដៅ | | 0 | 7 | 7 | 2 | 1 | 0 | 0 | 0 | 1 | 0 | 21 | 20 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 5 | 0 | 0 | 0 | 5 | 2 | 0 |
| 7 | ការដឹកជញ្ជូនដោយមានគោលដៅ | | 3 | 16 | 19 | 26 | 10 | 2 | 1 | 0 | 15 | 1 | 89 | 73 | 1 | 0 | 0 | 16 | 0 | 0 | 0 | 0 | 10 | 1 | 0 | 0 | 11 | 8 | 0 |
| 8 | ការទទួលយកមនុស្សដោយមានគោលដៅ | | 1 | 30 | 31 | 52 | 6 | 3 | 0 | 0 | 46 | 1 | 80 | 57 | 1 | 2 | 0 | 21 | 1 | 2 | 2 | 0 | 16 | 2 | 0 | 0 | 18 | 13 | 0 |
| 9 | សញ្ញាកម្មទាក់ទងនឹងពេស្យាចារកុមារ | | 8 | 16 | 24 | 54 | 34 | 28 | 17 | 17 | 3 | 3 | 46 | 30 | 10 | 11 | 11 | 5 | 0 | 0 | 0 | 0 | 11 | 0 | 0 | 0 | 11 | 13 | 0 |
| 10 | ការទិញពេស្យាចារកុមារ | | 1 | 15 | 16 | 35 | 1 | 0 | 34 | 34 | 0 | 0 | 16 | 15 | 4 | 1 | 1 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0 | 0 | 9 | 7 | 0 |
| 11 | ការទិញពេស្យាចារកុមារក្រោមអាយុ ១៥ឆ្នាំ (អនីតិជន) | | 0 | 3 | 3 | 2 | 0 | 0 | 2 | 2 | 0 | 0 | 5 | 5 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | 2 | 1 | 0 |
